Mekong River Commission
For Sustainable Development

# ផែនការមេអំពីទឹកជំនន់ និងគ្រោះរាំងស្ងួតសម្រាប់ អនុអាងសម្រាប់ 9C-9T

គណៈកម្មការទន្លេមេគង្គ - គម្រោងរួមគ្នាគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត

ខែធ្នូ ឆ្នាំ ២០២១



ឯកសារនេះត្រូវបានរៀបចំដោយគណៈកម្មការទន្លេមេគង្គ (MRC) ជាមួយការគាំទ្រពីប្រទេសអាល្លឺម៉ង់ដើម្បីកិច្ចសហប្រតិបត្តិការអន្តរជាតិ (GIZ) ក្នុងនាមក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ ប្រទេសអាល្លឺម៉ង់ (BMZ) និង (ICEM) – មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន ក្រុមហ៊ុនទីប្រឹក្សាបច្ចេកវិទ្យា (COT) និងក្រុមហ៊ុនទីប្រឹក្សាអន្តរជាតិភ្នំពេញ (PPIC) សម្រាប់គម្រោង៖ *គណៈកម្មការទន្លេមេគង្គ – គម្រោងរួមគ្នាដើម្បីគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត*។

ផែនការមេនេះ រួមមានទាំង ផែនទី និងរូបភាពដែលបង្ហាញនៅទីនេះ ពុំផ្តល់ជាការវិនិច្ឆ័យអំពីសិទ្ធិតាមច្បាប់អន្តរជាតិរបស់ កម្ពុជា និងថៃ ដែលទាក់ទងនឹងព្រំដែនគោកឡើយ។

| | |
|---|---|
| រៀងរៀងដោយ | ក្រុមការងារថ្នាក់ជាតិសម្រាប់កម្ពុជា និងក្រុមការងារថ្នាក់ជាតិសម្រាប់ប្រទេសថៃនៃគម្រោងរួមគ្នាសម្រាប់អនុអាង 9C-9T។<br>បានទទួលការគាំទ្រពីក្រុមការងារគម្រោងរួមគ្នាដោយ MRCS-GIZ ជាអាទិ៍ បណ្ឌិត ធីម លី ប្រធានផែនការអាងទន្លេនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ; Bertrand Meinier នាយកកម្មវិធីនៃ MRC-GIZ; Barbara Schweiger នាយកកម្មវិធីនៃ MRC-GIZ, Nittana Southiseng នាយករងគម្រោង នៃ MRC-GIZ សេត សុបញ្ញា ទីប្រឹក្សាបច្ចេកទេសប្រចាំតំបន់នៃ MRC-GIZ; Nike Hestermann ទីប្រឹក្សាអភិវឌ្ឍន៍ នៃ MRC-GIZ, Richard Muller ទីប្រឹក្សាអភិវឌ្ឍន៍ នៃ MRC-GIZ។<br>បានទទួលការគាំទ្រពីក្រុម ICEM/COT/PPIC ជាអាទិ៍ Jeremy Carew-Reid, Hubert Lohr, Nguyen Huy Trung, Khan Ra, Sanidda Tiewtoy, Toy Monireth, Wannee Lattitawanich, Leila Macadam និង Nguyen Thi Phuong Thao ។ |
| គួរធ្វើសេចក្តីយោងបែបនេះ៖ | MRC. 2021. Flood and Drought Master Plan for 9C-9T Sub-basin. Joint Project on Flood and Drought Management. Mekong River Commission. Vientiane, Lao PDR |
| ព័ត៌មានបន្ថែម៖ | http://www.mrcmekong.org/<br>Unit 18, Ban Sithane Neua, Sikhottabong District, Vientiane 01000, Lao PDR<br>Tel: +856 21 263 263. |
| រូបថតក្របមុខ | ICEM |

# មាតិកា

**សេចក្តីសង្ខេបប្រតិបត្តិ ........ 1**
**១. សេចក្តីផ្តើម ........ 5**
**២ .គោលបំណង និងវិសាលភាព ........ 7**
**៣ .ការវាយតម្លៃស្ថានភាព ........ 8**
៣.១ កិច្ចសហប្រតិបត្តិការគម្រោងរួមគ្នា ........ 8
៣.២ ស្ថានភាពអាង ........ 8
៣.៣ កត្តាជម្រុញហានិភ័យនៃទឹកជំនន់ និងគ្រោះរាំងស្ងួត ........ 14
៣.៤ ការឆ្លើយតប និងកាលានុវត្តភាព ........ 17
**៤ .ក្របខ័ណ្ឌយុទ្ធសាស្រ្ត និងផែនការសកម្មភាព ........ 22**
៤.១ ហេតុផល 22
៤.២ ទិដ្ឋភាពទូទៅនៃការប្តេជ្ញាចិត្តដែលមានស្រាប់ខាងគោលនយោបាយ ........ 22
៤.៣ ចក្ខុវិស័យ និងសេចក្តីថ្លែងការណ៍បេសកកម្ម ........ 30
៤.៤ អាទិភាពយុទ្ធសាស្រ្ត និងលទ្ធផលសម្រាប់ទឹកជំនន់ និងគ្រោះរាំងស្ងួត ........ 31
៤.៥ សេចក្តីអធិប្បាយអំពីអាទិភាពយុទ្ធសាស្រ្តនិងលទ្ធផលនៃផែនការមេ 9C-9T ........ 34
៤.៦ ផែនការសកម្មភាព ........ 40
៤.៧ ការអនុវត្ត 58
**ឧបសម្ព័ន្ធ ១. ការបន្សុីធាតុចេញជាមួយអាទិភាពយុទ្ធសាស្រ្តជាតិរួមទាំង៦ ...... 74**
**ឧបសម្ព័ន្ធ ២ .អត្តសញ្ញាណកម្មទីជម្រាល និងចំណាត់ថ្នាក់ ........ 94**
វិធីសាស្រ្តកំណត់អាង ........ 94
ការវិភាគពហុលក្ខណៈវិនិច្ឆ័យ ........ 95
លក្ខណៈវិនិច្ឆ័យ និងការជ្រើសរើស ........ 95
ចំណាត់ថ្នាក់រួមនៃអាង ........ 98
តំបន់អាទិភាពសម្រាប់គម្រោងបង្ហាញ ........ 100

## តារាង

តារាងទី ១. អាទិភាពយុទ្ធសាស្ត្រសម្រាប់សកម្មភាពជន់នឹងទឹកជំនន់និងគ្រោះរាំងស្ងួតក្នុងអនុអាង9C-9T....3
តារាងទី ២. អាទិភាពយុទ្ធសាស្ត្រ លទ្ធផល អន្តរាគមន៍ និងសន្ទស្សន៍ថវិកា នៃផែនការសកម្មភាព.............41
តារាងទី ៣៖ តារាងលម្អិតវិភាគទានថវិកាជាតិ និងអន្តរជាតិ......................................................47
តារាងទី ៤ ស្ថាប័នដែលចូលរួមក្នុងក្រុមការងារថ្នាក់ជាតិកម្ពុជាសម្រាប់អនុអាង 9C-9T...............................60
តារាងទី ៥ ស្ថាប័នដែលចូលរួមក្នុងក្រុមការងារថ្នាក់ជាតិថៃ សម្រាប់អនុអាង 9C-9T...................................61
តារាងទី ៦. ក្របខ័ណ្ឌសូចនាករសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃផែនការមេអនុអាង 9C-9T..........65
តារាងទី ៧. ម៉ាទ្រីសពិន្ទុសម្រាប់អនុអាង (អនុអាងដែលមានអាទិភាពខ្ពស់សម្រាប់ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតត្រូវបានរំលេចជាពណ៌បៃតង)..........................................................................99
តារាងទី ៨. ទីតាំងចុះពិនិត្យ នៅក្នុងអនុអាងដែលបានកំណត់ជាអាទិភាព.......................................101

## រូបភាព

រូបភាពទី ១. ព្រំប្រទល់ និងតំបន់រយៈកំពស់នៃអនុអាង 9C-9T..........................................................9
រូបភាពទី ២. ស្ថានភាពភូមិសាស្ត្រសំខាន់ៗនៅក្នុងអនុអាង 9C-9T.....................................................10
រូបភាពទី ៣. ព្រំប្រទល់រដ្ឋបាលនៃអនុអាង9C-9T.............................................................................11
រូបភាពទី ៤. ការប្រែប្រួលរបាយទឹកភ្លៀងក្នុងរដូវប្រាំងនៅឆ្នាំ ២០៥០ ក្នុងអនុអាង 9C-9T..........................13
រូបភាពទី ៥. របាយទឹកភ្លៀងក្នុងរដូវវស្សា នៅក្នុងអនុអាង 9C-9T គិតត្រឹមឆ្នាំ ២០៥០.............................14
រូបភាពទី ៦. ហេដ្ឋារចនាសម្ព័ន្ធទឹកក្នុងអនុអាង 9C-9T..................................................................16
រូបភាពទី ៧. កិច្ចព្រមព្រៀងអនុសញ្ញាទាំងបីនៅទីក្រុងរីយ៉ូសម្រាប់ការស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ .........22
រូបភាពទី ៨. រចនាសម្ព័ន្ធផែនការមេទឹកជំនន់និងគ្រោះរាំងស្ងួតសម្រាប់អនុអាង9C-9T នៅកម្រិតលទ្ធផល.............33
រូបភាពទី ៩. ការដាក់ពិន្ទុ និងការកំណត់ជ្រើសរើសអនុទីជម្រាល.....................................................37
រូបភាពទី ១០. រចនាសម្ព័ន្ធអភិបាលកិច្ចសម្រាប់គម្រោងរួម...............................................................59
រូបភាពទី ១១. អនុអាង នៅក្នុងអាង 9C-9T....................................................................................94
រូបភាពទី ១២. ដំណើរការចាត់ថ្នាក់រួម ដែលនាំទៅដល់ការកំណត់អត្តសញ្ញាណកន្លែងអនុវត្ត....................95
រូបភាពទី ១៣. ការដាក់ពិន្ទុហានិភ័យគ្រោះរាំងស្ងួតតាមអនុអាង.......................................................96
រូបភាពទី ១៤. ការដាក់ពិន្ទុហានិភ័យទឹកជំនន់ តាមអនុអាង.............................................................96
រូបភាពទី ១៥. ការដាក់ពិន្ទុហានិភ័យសំណឹកដី តាមអនុអាង............................................................97
រូបភាពទី ១៦. ការដាក់ពិន្ទុហានិភ័យបាត់បង់ជីវៈចម្រុះ និងព្រៃឈើ តាមអនុអាង.....................................97
រូបភាពទី ១៧. ការដាក់ពិន្ទុលើសារៈសំខាន់ខាងសេដ្ឋកិច្ចសង្គម តាមអនុអាង.........................................98
រូបភាពទី ១៨. ការដាក់ពិន្ទុអនុអាង និងការជ្រើសរើស...................................................................100

# សេចក្តីសង្ខេបប្រតិបត្តិ

ផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួតសម្រាប់អនុអាង 9C-9T គឺជាក្របខណ្ឌវិនិយោគមួយ ដែលកំណត់ការវិនិយោគ និងសកម្មភាពរួមគ្នា រវាងកម្ពុជា និងថៃ ដើម្បីពង្រឹងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតរួមគ្នា នៅក្នុងអនុអាង 9C-9T ជាមួយការគាំទ្រពីគណៈកម្មការទន្លេមេគង្គ (MRC) និងដៃគូអន្តរជាតិ។ អនុអាង 9C-9T គឺជាបណ្តាញស្ទឹងរួមគ្នាដែលហូរចុះទៅបឹងទន្លេសាប ជាអាទិ៍ តំបន់ដែលនៅកម្ពុជាហៅថា អាងស្ទឹងមង្គលបូរី និងតំបន់ ដែលនៅថៃហៅថា អាងទន្លេសាប។ គឺផ្នែកទាំងពីរនៃអនុអាងនេះ ដែលនាំឱ្យប្រទេសទាំងពីរនេះមានចំណងទាក់ទងជាមួយគ្នាទាំងលើបញ្ហាប្រឈម និងដំណោះស្រាយ សម្រាប់ការគ្រប់គ្រងរួមគ្នានៃប្រទេសទាំងពីរ។ ការកាត់បន្ថយទឹកជំនន់ និងគ្រោះរាំងស្ងួត គឺជាគោលបំណងទូលំទូលាយមួយ ដោយសារតែផលប៉ះពាល់ដ៏ធំធេងនៃទឹកជំនន់ និងគ្រោះរាំងស្ងួត មកលើគ្រប់ទិដ្ឋភាពនៃការរស់នៅក្នុងអនុអាង 9C-9T ជាមួយហានិភ័យដែលកាន់តែធ្ងន់ធ្ងរ នៅក្រោមឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ ជាការឆ្លើយតប ផែនការមេនេះ ផ្តល់ចក្ខុវិស័យយុទ្ធសាស្ត្រសម្រាប់រយៈពេល ២០ឆ្នាំ ផែនការសកម្មភាពរយៈពេល ១៥ឆ្នាំ និងកម្មវិធីកាលវិភាគរយៈពេល ៥ឆ្នាំ ព្រមទាំងសន្ទស្សន៍ថវិកាសម្រាប់ឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៦។

## វិសាលភាព

ផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួតនេះ ជំរុញឱ្យមានក្របខ័ណ្ឌយុទ្ធសាស្ត្រ អមជាមួយការវិនិយោគនៅលើអភិក្រមចម្រុះសម្រាប់ការរៀបចំផែនការអាងទន្លេ។ វិស័យអាទិភាពជាយុទ្ធសាស្ត្រ លទ្ធផល និងធាតុចេញនៃផែនការសកម្មភាព ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ននៃអនុអាង 9C-9T។ ការផ្តោតជាសំខាន់គឺ ការស្តារឡើងវិញនូវទីជម្រាលទូទាំងអាងទន្លេទាំងមូល តាមរយៈដំណោះស្រាយផ្អែកលើធម្មជាតិ និងចម្រុះ ដែលពង្រឹងជាបន្ថែម ព្រមទាំងប្រើប្រាស់ការវិនិយោគដែលមានស្រាប់លើហេដ្ឋារចនាសម្ព័ន្ធរឹងដែលបានគ្រោងទុក។ ហេដ្ឋារចនាសម្ព័ន្ធរឹងផ្ទាល់ មិនត្រូវបានរាប់បញ្ចូលក្នុងដំណាក់កាលដំបូងនៃផែនការមេនេះទេ។ ប្រការនេះអាចនឹងផ្លាស់ប្តូរ ក្រោយមានការពិនិត្យ និងកែសម្រួលផែនការនេះ នៅក្នុងវដ្តខាងមុខនៃផែនការនេះ ប៉ុន្តែប្រការចាំបាច់គឺ ត្រូវមានការប្តេជ្ញាចិត្តប្រកបដោយតម្លាភាព ដែលផ្អែកលើភស្តុតាង នៅក្នុងការវាយតម្លៃគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងអភិក្រមចម្រុះនៃការកសាងផែនការ ដែលរួមទាំង ការវាយតម្លៃឱ្យបានគ្រប់គ្រាន់នូវសក្តានុពលនៃផលប៉ះពាល់បរិស្ថាន សង្គម និងឆ្លងដែន។ ផែនការមេនេះ មានបញ្ចូលការពង្រីកហេដ្ឋារចនាសម្ព័ន្ធជលសាស្ត្រ-ឧតុនិយម ដើម្បីបង្កើនការយល់ដឹងពីធនធានទឹកនៅក្នុងអនុអាង 9C-9T។

## ចក្ខុវិស័យរួម

ចក្ខុវិស័យអាងទឹករួមគឺៈ

*អនុអាង 9C-9T ជាប្រព័ន្ធដែលមានសុខភាពល្អ ស្អាត និងផលិតភាពខ្ពស់ ដែលទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី កាត់បន្ថយហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួត និងផ្តល់សេវាកម្មដ៏មានតម្លៃសម្រាប់ទាំងអស់គ្នា ទាំងក្នុងពេលបច្ចុប្បន្ន និងពេលអនាគត។*

សេចក្តីថ្លែងការណ៍បេសកកម្មសម្រាប់ផែនការមេនេះគឺ ប្រយុទ្ធប្រឆាំងនឹងទឹកជំនន់ និងគ្រោះរាំងស្ងួត នៅក្នុងអនុអាង 9C-9T ដោយការកែលំអ និងធ្វើឱ្យអាងនេះប្រសើរឡើងវិញ តាមរយៈការពង្រឹងស្ថាប័ននិងយន្តការរួមគ្នា ជាមួយព័ត៌មាន និងការប្រកាសផ្តល់ព័ត៌មានជាមុន ដើម្បីគាំទ្រដល់សុខុមាលភាពរបស់មនុស្ស និងរបបចិញ្ចឹមជីវិតដែលងាយរងការ

ប៉ះពាល់ដោយសារទឹក និងតាមរយៈ សកម្មភាពសម្របសម្រួលដល់ការវិនិយោគលើបណ្ដាញតជាប់គ្នានៃការបន្សាំ ដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី រួមជាមួយដំណោះស្រាយផ្អែកលើធម្មជាតិ និងចម្រុះ នៅទូទាំងអនុអាងដែលគ្រប់គ្រងហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួត ព្រមទាំងសន្តិសុខទឹកទាំងមូល ក្នុងក្របខ័ណ្ឌអភិក្រមចម្រុះសម្រាប់ទីជម្រាលឆ្លងដែន។

ផែនការនេះដោះស្រាយភាពងាយរងគ្រោះរបស់សហគមន៍កម្ពុជា និងថៃ នៅក្នុងអនុអាង 9C-9T តាមព្រំដែន នៅចំពោះមុខផលប៉ះពាល់នៃទឹកជំនន់ និងគ្រោះរាំងស្ងួតដែលកើតមានកាន់តែញឹកញាប់ និងកាន់តែខ្លាំង នៅក្រោមសម្ពាធនៃការកើនឡើងនៃចំនួនប្រជាជន ការប្រែប្រួលអាកាសធាតុ និងការរេចរឹលនៃទីជម្រាល។

## ការបន្ស៊ីគោលនយោបាយ

ផែនការមេនេះត្រូវបានបង្កើតឡើងស្របតាមសន្ទស្សន៍ផែនការជាតិ(NIP)២០២១-២០២៥ ដែលប្រទេសនីមួយៗរៀបចំឡើង ដើម្បីទាញយកប្រយោជន៍ពីកិច្ចសហប្រតិបត្តិការក្នុងតំបន់ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ (BDS) សម្រាប់អាងទន្លេមេគង្គឆ្នាំ ២០២១-២០៣០ និងផែនការយុទ្ធសាស្ត្រនៃ MRC ២០២១-២០២៥។ ផែនការមេនេះ ក៏ជួយឱ្យសម្រេចកិច្ចព្រមព្រៀងអន្តរជាតិ ដូចដែលប្រទេសទាំងពីរបានចុះហត្ថលេខា ដែលរួមទាំង អនុសញ្ញាសហប្រជាជាតិស្តីពីជីវចម្រុះ(CBD) អនុសញ្ញាសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងវហោស្ថានកម្ម(UNCCD) និងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC) ក្របខ័ណ្ឌសេនដាយ ២០១៥-២០៣០ អនុសញ្ញារ៉ាមសារស្តីពីតំបន់ដីសើម និងរបៀបវារៈឆ្នាំ ២០៣០ សម្រាប់អភិវឌ្ឍន៍ដោយចីរភាព។ ប្រការសំខាន់បំផុតគឺ ផែនការនេះត្រូវបានរៀបចំឡើងដើម្បីជម្រុញវិស័យចំនួនប្រាំមួយនៃសកម្មភាពរួមគ្នា ដែលជាអាទិភាពយុទ្ធសាស្ត្រជាតិរបស់កម្ពុជា និងថៃ និងដែលរួមចំណែកដល់ការគ្រប់គ្រងធនធានទឹកចម្រុះ។ វិស័យរួមទាំងប្រាំមួយនោះគឺៈ

១. **ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់**

២. **ការកសាងសន្តិសុខទឹកក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម ដែលរួមទាំង ប្រព័ន្ធស្រោចស្រព**

៣. **ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត**

៤. **ការគ្រប់គ្រងគុណភាពទឹក និងការអភិរក្សធនធានទឹក**

៥. **ការស្ដារឡើងវិញនូវទីជម្រាល និងព្រៃឈើរេចរិល ដើម្បីនិរន្តរភាពទឹក**

៦. **ការកសាងប្រព័ន្ធគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានប្រកបដោយប្រសិទ្ធភាព**

នេះជាការបង្ហាញពីការកែប្រែ ដែលធ្លាប់តែផ្តោតលើការរៀបចំផែនការគម្រោងហេដ្ឋារចនាសម្ព័ន្ធនិងការវិនិយោគ ឱ្យទៅជាការកសាងផែនការបុរេសកម្មទូទាំងអាងទន្លេ ការស្ដារឡើងវិញនិងការអនុវត្តអភិក្រម IWRM តាមរយៈសកម្មភាពអន្តរវិស័យ សម្រាប់ដោះស្រាយបញ្ហាប្រឈមខាងទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលកើតមានចំពោះប្រទេសទាំងពីរ។ ការចូលរួមចំណែកនៃជាតុចេញពីផែនការមេនេះ ត្រូវបានគូសបញ្ជាក់សម្រាប់វិស័យរួមគ្នាទាំងប្រាំមួយដូចក្នុងឧបសម្ព័ន្ធ ១។

# អាទិភាពយុទ្ធសាស្ត្រ

ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃផែនការមេនេះ ពង្រីកការវិនិយោគលើភាពធន់នឹងទឹកជំនន់និងគ្រោះរាំងស្ងួត ក្នុងវិស័យយុទ្ធសាស្ត្រចំនួនប្រាំ ពោលគឺ ការរៀបចំផែនការអាងទន្លេ ការកសាងសមត្ថភាពក្នុងតំបន់ ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅតាមទីក្រុង និងទីជនបទ ការប្រកាសផ្តល់ព័ត៌មានជាមុន និងការចែករំលែកទិន្នន័យទ្វេភាគីរវាងប្រទេសទាំងពីរអំពីស្ថានភាពជលសាស្ត្រ-ឧតុនិយម។ អាទិភាពយុទ្ធសាស្ត្រទាំងប្រាំនេះ និងធាតុចេញដែលពាក់ព័ន្ធសម្រាប់សកម្មភាពពីឆ្នាំ ២០២២-២០២៦ មានបង្ហាញក្នុងតារាងទី ១។

**តារាងទី ១. អាទិភាពជាយុទ្ធសាស្ត្រសម្រាប់សកម្មភាពលើភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងអនុអាង 9C-9T**

| អាទិភាពយុទ្ធសាស្ត្រ ឆ្នាំ ២០២២-២០២៦ | |
|---|---|
| អាទិភាពយុទ្ធសាស្ត្រ ១.<br>**ពិនិត្យ ធ្វើបច្ចុប្បន្នភាព និងអនុវត្តផែនការមេអាងទន្លេ** | **លទ្ធផល ១.១៖** បានបន្សុំក្របខណ្ឌច្បាប់ និងការអនុវត្តសម្រាប់ការគ្រប់គ្រងធនធានទឹកឆ្លងដែនដើម្បីគាំទ្រដល់ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។ |
| | **លទ្ធផល ១.២៖** បានពង្រឹងយន្តការ ដើម្បីកែលម្អការរៀបចំផែនការ IWRM និងការគ្រប់គ្រងចម្រុះអាងទន្លេ សម្រាប់ទឹកជំនន់ និងគ្រោះរាំងស្ងួត។ |
| | **លទ្ធផល ១.៣៖** ការផ្តល់ហិរញ្ញប្បទានដោយនិរន្តរភាពនៃវិធានការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ីសម្រាប់ភាពធន់នឹងទឹកជំនន់និងគ្រោះរាំងស្ងួត។ |
| អាទិភាពយុទ្ធសាស្ត្រ ២.<br>**គ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅទីក្រុង និងជនបទ ដើម្បីកាត់បន្ថយហានិភ័យ** | **លទ្ធផល ២.១៖** បានពង្រឹងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងទីក្រុង តាមរយៈការអនុវត្តឧបករណ៍កសាងផែនការបែបនវានុវត្តន៍ និងផ្អែកលើប្រព័ន្ធអេកូឡូស៊ី ព្រមទាំង អន្តរាគមន៍បន្សាំ។ |
| | **លទ្ធផល ២.២៖** បានពង្រឹងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅតាមជនបទ តាមរយៈឧបករណ៍កសាងផែនការដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងអន្តរាគមន៍បន្សាំ។ |
| | **លទ្ធផល ២.៣៖** បានកែលំអអាងនៅតំបន់ក្បាលទឹក និងតំបន់ដីសើម ដើម្បីបង្កើនសន្តិសុខទឹកនិងភាពធន់នឹងអាកាសធាតុ តាមរយៈអន្តរាគមន៍បន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី។ |
| អាទិភាពយុទ្ធសាស្ត្រ ៣.<br>**ផ្លាស់ប្តូរព័ត៌មាន និងចំណេះដឹង** | **លទ្ធផល ៣.១៖** ភាពធន់នឹងទឹកជំនន់និងគ្រោះរាំងស្ងួត និង IWRM ដែលគិតគូរពីអាកាសធាតុ តាមរយៈការចែករំលែកចំណេះដឹង។ |
| | **លទ្ធផល ៣.២៖** ពង្រីកការអនុវត្តល្អ និងចែករំលែកមេរៀនដែលបានរៀនពីគម្រោងរួម 9C-9T នៅក្នុងអាងទន្លេមេគង្គក្រោម។ |
| អាទិភាពយុទ្ធសាស្ត្រ ៤.<br>**ពង្រឹងបណ្តាញជលសាស្ត្រ-ឧតុនិយម និងការប្រកាសផ្តល់ព័ត៌មានអំពីទឹកជំនន់ និងគ្រោះរាំងស្ងួត** | **លទ្ធផល ៤.១៖** បានពង្រឹងពិធីសាររួមគ្នាសម្រាប់ការត្រួតពិនិត្យនិងការប្រកាសផ្តល់ព័ត៌មានអំពីជលសាស្ត្រ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ និងគ្រោះរាំងស្ងួត។ |

| | |
|---|---|
| **អាទិភាពយុទ្ធសាស្ត្រ ៥.** **កសាងសមត្ថភាពនៅក្នុងតំបន់** | **លទ្ធផល ៥.១៖** បានពង្រឹងសមត្ថភាពកែលំអ និងថែទាំអាងទន្លេ តាមរយៈវិធានការធម្មជាតិ និងចម្រុះ។ |
| | **លទ្ធផល ៥.២៖** បានពង្រឹងសមត្ថភាពរៀបចំផែនការអាងទន្លេ និងការគ្រប់គ្រងឆ្លងដែន។ |
| | **លទ្ធផល ៥.៣៖** បានពង្រឹងសមត្ថភាពបង្កើតម៉ូដែលទឹកជំនន់ និងគ្រោះរាំងស្ងួត ការបកស្រាយ និងការប្រាស្រ័យទាក់ទងអំពីលទ្ធផល។ |

## តម្រូវការនៅទូទាំងអាង

អនុអាង 9C-9T ត្រូវបានបែងចែកជា ១៨អាងផ្ទៃរងទឹកភ្លៀង ដើម្បីអាចកំណត់តំបន់ប្រឈមសម្រាប់ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត។ ភាគច្រើននៃផ្ទៃរងទឹកភ្លៀងទាំងនោះត្រូវបានកំណត់ថាជា តំបន់ងាយជន់លិច ឬ រាំងស្ងួត ប៉ុន្តែវាក៏ជាតំបន់ខ្សែទឹកខាងលើ និងតំបន់ក្បាលទឹកប្រកបដោយស្ថានភាពព្រៃឈើរេចរិល ដែលកំពុងបង្កបញ្ហាទឹកជំនន់ និងគ្រោះរាំងស្ងួតសម្រាប់តំបន់ខ្សែទឹកខាងក្រោមផងដែរ។ ការគ្រប់គ្រងតំបន់ទាំងនេះដោយប្រសិទ្ធភាព មានតួនាទីយ៉ាងសំខាន់ក្នុងកាត់បន្ថយវិសាលភាព និងកម្រិតធ្ងន់ធ្ងរនៃជំនន់ និងគ្រោះរាំងស្ងួតនៅទូទាំងអាងទឹក 9C-9T។ បណ្តាញទីតាំងចំនួន ១២ ដែលស្នើសម្រាប់វិធានការពង្រឹងភាពធន់ ត្រូវបានដៅលើផែនទី ជាចំណុចចាប់ផ្តើមរូបវន្តសម្រាប់ការវិនិយោគ និងការអនុវត្តនាពេលអនាគត។

## ការអនុវត្ត

កិច្ចសហប្រតិបត្តិការអន្តរវិស័យ និងពហុកម្រិតនៅថ្នាក់ជាតិ និងទ្វេភាគី មានសារៈសំខាន់ណាស់ដើម្បីអនុវត្តឱ្យបានជោគជ័យនូវការងារគ្រប់គ្រងធនធានទឹកចម្រុះ ការរៀបចំផែនការអាងទន្លេ និងភាពធន់ឆ្លងដែន ឆ្លើយតបនឹងបញ្ហាទឹកជំនន់ និងគ្រោះរាំងស្ងួត។ ស្ថាប័នពាក់ព័ន្ធនៃរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់ ទាំងសងខាងនៃព្រំដែនត្រូវរួមចំណែកក្នុងការកែសម្រួល និងអនុវត្តផែនការសកម្មភាពនៅទូទាំងយុទ្ធសាស្រ្តរយៈពេល២០ឆ្នាំ។ ដូច្នេះ ការចាត់ចែងស្ថាប័នសម្រាប់អនុវត្តផែនការមេនេះ នឹងជួយរក្សា និងពង្រីករចនាសម្ព័ន្ធអភិបាលកិច្ចដែលមានស្រាប់ ដែលបានបង្កើតឡើងសម្រាប់អនុអាង 9C-9T ជាមួយកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងថៃ ដែលសម្របសម្រួលដោយគណៈកម្មការទន្លេមេគង្គ។

ការអនុវត្តផែនការមេនេះ ត្រូវធ្វើឡើងស្របជាមួយការពិនិត្យ និងវាយតម្លៃជាប្រចាំ(M&E) ធៀបនឹងក្របខ័ណ្ឌយុទ្ធសាស្ត្រ ដែលស្ថិតក្រោមការចាត់ចែងនៃរចនាសម្ព័ន្ធអភិបាលកិច្ចនេះ។ នៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តផែនការមេនេះ នឹងមានការអធិប្បាយលំអិតអំពីសូចនាករពាក់ព័ន្ធ ជាមួយការពិចារណាអំពីអាទិភាពយុទ្ធសាស្រ្តរួមនៃប្រទេសទាំងពីរ និងសូចនាករអនុវត្តល្អជាសកលផ្សេងទៀតដែលពាក់ព័ន្ធសម្រាប់ធ្វើការវាយតម្លៃភាពជោគជ័យ។

ភាគច្រើននៃធាតុចេញតម្រូវឱ្យមានដំណាក់កាលដំបូងដើម្បីចែងលំអិតជាសកម្មភាពគម្រោង តាមរយៈការពិគ្រោះយោបល់ និងការចូលរួមជាមួយភាគីពាក់ព័ន្ធជាច្រើន នៅពេលចាប់ផ្តើមអនុវត្តផែនការមេនេះ។ ភាគីពាក់ព័ន្ធនានាត្រូវបន្តចូលរួមឱ្យបានច្រើន ដើម្បីជូនជាព័ត៌មានសម្រាប់ការរចនាប្លង់លម្អិត និងជាដៃគូសម្រាប់ការអនុវត្ត។ អ្នកពាក់ព័ន្ធទាំងនេះត្រូវបានកំណត់អត្តសញ្ញាណ ជាអាទិ៍ សាធារណៈជននៃតំបន់គោលដៅ មេដឹកនាំសហគមន៍ និងសង្គមស៊ីវិល គ្រឹះស្ថានសិក្សានិងស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធក្នុងវិស័យឯកជន។ ជាពិសេស មុនអនុវត្តសកម្មភាពនីមួយៗ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាននៅតំបន់ជុំវិញ និងជាពិសេសនៅតំបន់ខ្សែទឹកខាងក្រោម ដើម្បីឱ្យមានការមូលមតិជាមុន ដោយគ្មានការបង្ខិតបង្ខំ ទន្ទឹមនឹងការទទួលបានព័ត៌មានគ្រប់គ្រាន់។

យុទ្ធសាស្ត្រកៀរគរមូលនិធិសម្រាប់ផែនការមេនេះ ត្រូវផ្អែកលើវិភាគទានពីថវិកាជាតិ តាមរយៈថវិកាតាមវិស័យ និងតាមស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជានិងរាជរដ្ឋាភិបាលថៃ។ ការប្តេជ្ញាចិត្តនេះមានសារៈសំខាន់ជាសារវន្ត ចំពោះនិរន្តរភាពនៃសកម្មភាពគម្រោង។ មូលនិធិជាតិនេះនឹងត្រូវបានបំពេញបន្ថែមដោយមូលនិធិទ្វេភាគី និងមូលនិធិសកល ដើម្បីបង្កើនសន្ទុះ និងវិសាលភាពនៃការអនុវត្តផែនការសកម្មភាពដែលបានកំណត់សម្រាប់រយៈពេលខ្លីដល់រយៈពេលមធ្យម។ ឱកាសផ្តល់មូលនិធិពីខាងក្រៅត្រូវបានកំណត់អត្តសញ្ញាណ ជាអាទិ៍ មូលនិធិបរិស្ថានសកល គណៈកម្មការទន្លេមេគង្គ ក្រសួងសហព័ន្ធអាល្លឺម៉ង់ដើម្បីកិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ) និងក្រសួងសហព័ន្ធអាល្លឺម៉ង់ដើម្បីបរិស្ថានការអភិរក្សធម្មជាតិ និងសុវត្ថិភាពនុយក្លេអ៊ែរ (BMU) តាមរយៈកិច្ចផ្តួចផ្តើមអាកាសធាតុអន្តរជាតិ(IKI) មូលនិធិបន្សុំាតាមប្រព័ន្ធអេកូឡូស៊ីនិងមូលនិធិដើម្បីសកម្មភាពជាតិសមស្របសម្រាប់កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់(NAMA)។

ហានិភ័យនៃការអនុវត្តត្រូវបានពិនិត្យជាមួយនឹងវិស័យសំខាន់ៗចំនួនបួន ដែលត្រូវបានកំណត់សម្រាប់បុរេសកម្មភាពគ្រប់គ្រងដោយប្រទេសកម្ពុជា និងប្រទេសថៃ៖

១. ភាពខ្វះខាត ឬភាពយឺតយ៉ាវក្នុងការប្តេជ្ញាចិត្តផ្តល់វិភាគទានពីថវិកាជាតិនៃប្រទេសទាំងពីរ។
២. ខាតខ្វះខាត ឬភាពយឺតយ៉ាវក្នុងការប្តេជ្ញាចិត្តផ្តល់ការគាំទ្រពីមូលនិធិអន្តរជាតិ។
៣. ការមិនបានបំពេញតាមពិធីសារចែករំលែកទិន្នន័យឱ្យទាន់ពេលវេលា ដើម្បីជួយសម្រួលដល់ការវាយតម្លៃចម្រុះរួមគ្នាការកសាងផែនការ និងការប្រកាសផ្តល់ព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់។ និង
៤. ការចូលរួមនៃវិស័យនានាមិនទាន់ពេលវេលា នៅក្នុងការអនុវត្តផែនការមេដែលមានលក្ខណៈចម្រុះឱ្យបានទូទាំងអាង។

អភិក្រមបែបបន្សុំានឹងត្រូវប្រើប្រាស់ជាការណែនាំសម្រាប់ការអនុវត្ត ជាមួយធនធានដែលមាន និងការគាំទ្រពីលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ(MRCS)។

# ១. សេចក្តីផ្តើម

ផែនការមេសម្រាប់ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងអនុអាង 9C-9T បង្ហាញពីចក្ខុវិស័យយុទ្ធសាស្ត្ររយៈពេល ២០ ឆ្នាំ ផែនការសកម្មភាព ១៥ ឆ្នាំ និងកម្មវិធីកាលវិភាគរយៈពេល ៥ ឆ្នាំ និងសន្ទស្សន៍ថវិកាសម្រាប់ឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៦។ ផែនការនេះផ្តល់ក្របខ័ណ្ឌសម្រាប់ការកៀរគរធនធាន និងការអនុវត្តសកម្មភាពរបស់កម្ពុជា និងថៃ ដើម្បីពង្រឹងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងអនុអាងរួមនៃប្រទេសទាំងពីរ។ ផែនការមេនេះនឹងត្រូវពិនិត្យឡើងវិញ និងកែសម្រួលរៀងរាល់ប្រាំឆ្នាំម្តងក្នុងអំឡុងពេលអនុវត្ត ដើម្បីធានាថា វានៅតែឆ្លើយតបទៅនឹងអាទិភាព និងតម្រូវការរបស់ប្រទេសទាំងពីរ។ វដ្តនៃការកសាងផែនការអនុអាង 9C-9T ចាំបាច់ត្រូវបន្សុីគ្នាជាមួយផែនការអភិវឌ្ឍន៍ជាតិ វិស័យ និងមូលដ្ឋាន និងវដ្តថវិការបស់ប្រទេសកម្ពុជា និងថៃ។ ស្ថាប័នពាក់ព័ន្ធរដ្ឋាភិបាល និងភាគីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ទាំងសងខាងនៃព្រំដែន ត្រូវរួមចំណែកក្នុងការពិនិត្យឡើងវិញ និងអនុវត្តផែនការសកម្មភាពនៅទូទាំងយុទ្ធសាស្ត្រ ២០ ឆ្នាំ។

អនុអាង 9C-9T មានឈ្មោះចម្លែកសម្រាប់បណ្តាញស្ទឹងរួមគ្នាដែលហូរចុះមកបឹងទន្លេសាប។ នេះជាអាងស្ទឹងដ៏សំខាន់មួយ ប៉ុន្តែឈ្មោះនេះបានមកពីទីតាំងនៃអាងនេះ នៅក្នុងឋានានុក្រមនៃប្រព័ន្ធជលសាស្ត្រទន្លេមេគង្គ ដែលមានដៃស្ទឹងយ៉ាងច្រើន។ ផ្នែកនៃអនុអាង 9C-9T នៅកម្ពុជា ត្រូវគេហៅថា អាងស្ទឹងមង្គលបូរី និងនៅក្នុងប្រទេសថៃ ហៅថាអាងទន្លេសាប។ ផ្នែកទាំងពីរនៃអនុអាងនេះ និងនៃប្រទេសទាំងពីរនេះ មានបញ្ហាប្រឈម និងដំណោះស្រាយដែលជាប់ទាក់ទងជាមួយការគ្រប់គ្រងរួមគ្នានៃប្រទេសទាំងពីរ។ ការកាត់បន្ថយទឹកជំនន់ និងគ្រោះរាំងស្ងួត គឺជាគោលបំណងសំខាន់មួយដោយសារតែផលប៉ះពាល់ដ៏ធំធេង មកលើគ្រប់ទិដ្ឋភាពនៃជីវភាពនៅក្នុងអនុអាង 9C-9T ជាមួយការគំរាមកំហែងកាន់តែ

ធ្ងន់ធ្ងរ នៅក្រោមឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ កត្តាជំរុញសំខាន់ៗនៃទឹកជំនន់ និងគ្រោះរាំងស្ងួត(ជំពូក ២.៣) គឺកំណើនចំនួនប្រជាជន និងសម្ពាធដែលពាក់ព័ន្ធ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹង ដែលច្រើនតែគ្មានការសម្របសម្រួលរវាងគ្នា ដែលធ្វើឱ្យប្រែប្រួលមុខងារជលសាស្ត្រ ហើយការប្រែប្រួលអាកាសធាតុធ្វើឱ្យទីជម្រាលនេះរេចរឹលកាន់តែធ្ងន់ធ្ងរ។ ការឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ តម្រូវឱ្យប្រទេសទាំងពីរធ្វើការរួមគ្នា ដើម្បីស្តារស្ថានភាពសុខភាពអេកូឡូស៊ីសម្រាប់អនុអាងរួមនេះ ដែលបានធ្លាក់ចុះដល់កម្រិតដែលកំពុងរារាំងដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសុខុមាលភាព សង្គម។

កម្ពុជា និងថៃបានផ្តួចផ្តើមបង្កើតរចនាសម្ព័ន្ធអភិបាលកិច្ចសហការគ្នាមួយ សម្រាប់អនុអាង 9C-9T ក្នុងឆ្នាំ ២០១៨ ក្រោមការឧបត្ថម្ភរបស់គណៈកម្មការទន្លេមេគង្គ ដោយមានក្រុមការងារអន្តរវិស័យនៅថ្នាក់ជាតិ ដែលបានបង្កើតឡើងនៅក្នុងប្រទេសទាំងពីរ និងគណៈកម្មាធិការតម្រង់ទិសជាន់ខ្ពស់នៅថ្នាក់តំបន់ ដែលមានសហប្រធានមកពី ក្រសួងធនធានទឹក និងឧតុនិយម(MOWRAM)កម្ពុជា និងការិយាល័យធនធានទឹកជាតិ(ONWR)នៃប្រទេសថៃ។ ផែនការមេនេះត្រូវបានរៀបចំឡើងតាមរយៈរចនាសម្ព័ន្ធនៃកិច្ចសហការនេះ ដើម្បីឆ្លុះបញ្ចាំង និងរួមបញ្ចូលការងារនៃប្រទេសទាំងពីរមកទល់បច្ចុប្បន្ន ជាមួយផែនការច្បាស់លាស់សម្រាប់ការអនុវត្តចាប់ពីឆ្នាំ ២០២២តទៅ។ ផែនការមេនេះផ្តល់ក្របខ័ណ្ឌយុទ្ធសាស្ត្រ ដើម្បីពង្រីកការវិនិយោគដើម្បីភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនៃអនុអាង 9C-9T វិស័យយុទ្ធសាស្ត្រចំនួនប្រាំនៃផែនការមេនេះគឺ ការកសាងផែនការអាងទន្លេ ការកសាងសមត្ថភាពក្នុងតំបន់ ភាពធន់នឹងទឹកជំនន់និងគ្រោះរាំងស្ងួត ការប្រកាសផ្តល់ព័ត៌មានជាមុន និងការចែករំលែកទិន្នន័យទ្វេភាគីរវាងប្រទេសទាំងពីរអំពីស្ថានភាពជលសាស្ត្រ-ឧតុនិយម។

ផែនការមេនេះ គឺជាក្របខណ្ឌសម្រាប់ការវិនិយោគនិងសកម្មភាពរួមគ្នា ដែលគាំទ្រដោយគណៈកម្មការទន្លេមេគង្គ (MRC) និងដៃគូអន្តរជាតិ។ ផែនការមេត្រូវបានរៀបចំឡើង ដោយបន្សុីជាមួយសន្ទស្សន៍ផែនការជាតិ(NIP)ឆ្នាំ ២០២១-២០២៥ ដែលរៀបចំដោយប្រទេសនីមួយៗ ដើម្បីទាញយកប្រយោជន៍ពីកិច្ចសហប្រតិបត្តិការក្នុងតំបន់ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍អាង(BDS) សម្រាប់អាងទន្លេមេគង្គឆ្នាំ ២០២១-២០៣០ និងផែនការយុទ្ធសាស្ត្ររបស់ MRC ឆ្នាំ ២០២១-២០២៥។ ទោះជាយ៉ាងណាក៏ដោយ វាជាក្បាលម៉ាស៊ីនដ៏សំខាន់សម្រាប់កិច្ចសហការទ្វេភាគី ការផ្តល់មូលនិធិ និងសកម្មភាពរួមគ្នារវាងកម្ពុជានិងថៃ។ ផែនការមេនេះ ត្រូវបានរៀបចំឡើង ក្នុងគោលដៅសុំការអនុម័តដោយគណៈកម្មាធិការដឹកនាំថ្នាក់តំបន់ក្នុងខែធ្នូ ឆ្នាំ២០២១ និងបន្ទាប់មកដោយគណៈរដ្ឋមន្ត្រីនៃប្រទេសទាំងពីរដែលជាការអនុម័តចាំបាច់កម្រិតកំពូល ដើម្បីផ្តល់សារៈសំខាន់ផ្ទៃក្នុង និងនៅថ្នាក់ជាតិ និងដើម្បីអាចទទួលបានថវិកាជាតិសម្រាប់ការអនុវត្តផែនការមេនេះ។

បន្ទាប់ពីជំពូក ១ - សេចក្តីផ្តើម និងជំពូក ២ - គោលបំណង និងវិសាលភាព ផែនការមេនេះចែកចេញជាពីរផ្នែកធំៗ។ ជំពូក ៣ គឺជាផ្នែកទីមួយ ដែលចែងពីការវាយតម្លៃស្ថានភាពនិងសំណុំលក្ខណៈនៃអនុអាង 9C-9T។ ផ្នែកនេះពិពណ៌នាអំពីកត្តាជំរុញសំខាន់ៗដែលនាំឱ្យមានទឹកជំនន់ និងគ្រោះរាំងស្ងួត និងការឆ្លើយតបបច្ចុប្បន្នរបស់រដ្ឋាភិបាល ដែលជាមូលដ្ឋានគ្រឹះ និងហេតុផលនៃការរៀបចំផែនការមេនេះ។ បន្ទាប់មក ជំពូក៤ ចែងពីក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់កសាងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត ស្របតាមអាទិភាពយុទ្ធសាស្ត្រជាតិសម្រាប់ធនធានទឹក ដែលមានជាធម្មតាសម្រាប់ប្រទេសទាំងពីរ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាង ២០២១-២០៣០ និងការប្តេជ្ញាជាអន្តរជាតិ ទាក់ទងនឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។ ផែនការនេះចែងពីសេចក្តីថ្លែងការណ៍ចក្ខុវិស័យ អាទិភាពយុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុក បន្តដោយផែនការសកម្មភាពពិស្តារសម្រាប់អនុអាង 9C-9T។ នៅក្នុងផែនការនេះ ក៏មានផ្តល់ការណែនាំលើការអនុវត្ត សម្រាប់ការចាត់ចែងស្ថាប័ន ការផ្តល់មូលនិធិ និងការពិនិត្យតាមដាននិងការវាយតម្លៃ លើកិច្ចប្រឹងប្រែងរបស់ប្រទេសទាំងពីរ ក្នុងការសម្រេចគោលបំណងនៃផែនការនេះផងដែរ។

# ២ .គោលបំណង និងទិសាលភាព

ផែនការមេនេះ រួមបញ្ចូលកិច្ចសហការលើការងារភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត រវាងកម្ពុជា និងថៃ ចាប់តាំងពីពេលចាប់ផ្តើមនៃគម្រោងរួមនៅឆ្នាំ ២០១៨។ ផែនការមេនេះតម្រូវឱ្យប្រទេសទាំងពីរមានការប្តេជ្ញាចំពោះវិស័យអាទិភាពជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលភ្ជាប់មកជាមួយ ដូចបានកំណត់តាមរយៈដំណើរការរៀបចំផែនការរួមគ្នានេះ ដើម្បីស្តារឡើងវិញនូវទីជម្រាលក្នុងអនុអាង 9C-9T ដែលជាមូលដ្ឋានគ្រឹះសម្រាប់ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។ ការចែងពិស្តារអំពីធាតុចេញនៃផែនការសកម្មភាព ប្រតិភូកម្មការទទួលខុសត្រូវក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចទ្វេភាគី និងការរៀបចំការសិក្សាលទ្ធភាពដែលពាក់ព័ន្ធ សុទ្ធសឹងជាកិច្ចការដែលត្រូវធ្វើឡើងក្នុងដំណាក់កាលអនុវត្ត។ កិច្ចការនេះរាប់បញ្ចូល ការសិក្សាលម្អិតអំពីផលប៉ះពាល់ឆ្លងដែន និងការរៀបចំ និងការអនុម័តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ទៅតាមលក្ខខណ្ឌតម្រូវនៃច្បាប់ជាតិរបស់ប្រទេសនីមួយៗ។

វិស័យអាទិភាពយុទ្ធសាស្ត្រ លទ្ធផល និងធាតុចេញក្នុងផែនការសកម្មភាព ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ននៃអនុអាង 9C-9T។ ការផ្តោតសំខាន់គឺ ការស្តារឡើងវិញនូវទីជម្រាលទាំងមូលតាមរយៈដំណោះស្រាយផ្អែកលើធម្មជាតិ និងចម្រុះ ដែលពង្រឹង និងប្រើប្រាស់ការវិនិយោគដែលមានស្រាប់ និងដែលបានគ្រោងទុក សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរឹង។ ព័ត៌មានលម្អិតបន្ថែមអំពីហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និងដែលបានគ្រោងទុក នឹងត្រូវបញ្ចូលក្នុងសៀវភៅផែនទីអាង 9C-9T ដែលជាកម្រងទិន្នន័យរួម ដែលគូសបញ្ជាក់ពីការរៀបចំផែនការមេនេះ ដោយផ្អែកលើមូលដ្ឋាននៃការវិវឌ្ឍជាបន្តបន្ទាប់ នៅពេលបានទទួលទិន្នន័យចាំបាច់ពីប្រទេសទាំងពីរ។

ផែនការមេអំពីទឹកជំនន់និងគ្រោះរាំងស្ងួតនេះ ជំរុញឱ្យមានក្របខណ្ឌយុទ្ធសាស្ត្រមួយ និងការវិនិយោគដែលភ្ជាប់មកជាមួយ ដូចដែលបានកំណត់នៅក្នុងអភិក្រមផែនការអាងទន្លេចម្រុះ។ ទោះបីផែនការមេអាងទន្លេនេះអាចមានប្រយោជន៍សម្រាប់ការបញ្ចូលហេដ្ឋារចនាសម្ព័ន្ធទាំងអស់ដែលកំពុងស្ថិតក្នុងការពិចារណាក៏ដោយ វដ្តផែនការប្រាំឆ្នាំដំបូងនេះ ផ្តោតតែលើការកែលំអអាងនេះឡើងវិញ តាមរយៈសកម្មភាពផ្អែកលើធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់ក្បាលទឹក និងនៅក្នុងតំបន់ទេសភាពទីក្រុង និងជនបទប៉ុណ្ណោះ។ ផែនការមេនេះ មិនបញ្ចូលការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹងឡើយ។ នៅក្នុងវដ្តនៃផែនការរយៈពេលប្រាំឆ្នាំជាបន្ទាប់ ព័ត៌មានលម្អិតនៃផែនការនៅក្នុងការគ្រោងទុកសម្រាប់ប្រទេសទាំងពីរ នឹងត្រូវចែករំលែក ពិភាក្សា និងវាយតម្លៃឱ្យបានពេញលេញ អំពីផលប៉ះពាល់បរិស្ថាន សង្គម និងឆ្លងដែន នៅក្នុងអភិក្រមចម្រុះទូទាំងអាងនេះ។ ការវាយតម្លៃបរិស្ថានបែបនេះ ត្រូវបានបញ្ចូលជាធាតុចេញ នៅក្នុងផែនការមេបច្ចុប្បន្ននេះ។ បន្ទាប់មកហេដ្ឋារចនាសម្ព័ន្ធរឹងដែលបានគ្រោងទុក អាចនឹងត្រូវដាក់បញ្ចូលជាបន្តបន្ទាប់នៅក្នុងវដ្តនៃផែនការនាពេលអនាគត។ ផែនការមេនេះ បានបញ្ចូលហេដ្ឋារចនាសម្ព័ន្ធជលសាស្ត្រ-ឧតុនិយម ដែលចាំបាច់ម្រាប់កែលម្អព័ត៌មានសំខាន់ៗអំពីជលសាស្ត្រសម្រាប់អនុអាង 9C-9T។

# ៣ .ការវាយតម្លៃស្ថានភាព

## ៣.១ កិច្ចសហប្រតិបត្តិការគម្រោងរួមគ្នា

ក្នុងឆ្នាំ ២០១៨ រដ្ឋាភិបាលកម្ពុជា និងថៃ បានផ្តួចផ្តើមកិច្ចសហប្រតិបត្តិការទ្វេភាគីក្រោម*គម្រោងរួមសម្រាប់កិច្ចសហប្រតិបត្តិការឆ្លងដែន ដើម្បីគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅតំបន់ព្រំដែនកម្ពុជា និងថៃ* (គម្រោងរួម)។ គម្រោងរួមនេះ គឺជាកិច្ចសហប្រតិបត្តិការទ្វេភាគីលើកដំបូងសម្រាប់ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងអនុអាងឆ្លងដែននៅក្នុងតំបន់មេគង្គ។ គណៈកម្មការទន្លេមេគង្គ បានសម្របសម្រួលកិច្ចសហប្រតិបត្តិការនេះ ជាមួយការគាំទ្រពីប្រទេសអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ GmbH (GIZ) ក្នុងនាមក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍អាល្លឺម៉ង់(BMZ) រហូតដល់ឆ្នាំ ២០២៤។ ប្រទេសនីមួយៗបានបង្កើតក្រុមការងារថ្នាក់ជាតិសម្រាប់អនុអាង 9C-9T ដើម្បីផ្តល់ការណែនាំបច្ចេកទេសដល់គណៈកម្មាធិការតម្រង់ទិសថ្នាក់តំបន់ ដែលមានសមាសភាពចូលរួមពីស្ថាប័នខុសៗគ្នាជាច្រើន និងមាន MOWRAM និង ONWR ជាសហប្រធាន ជាមួយការឧបត្ថម្ភរបស់ MRC។ គម្រោងរួមនេះបានឆ្លុះបញ្ចាំងនៅក្នុងសន្ទស្សន៍ផែនការជាតិ(NIP) ២០២១-២០២៥ សម្រាប់ប្រទេសនីមួយៗ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្ររបស់ MRC ឆ្នាំ ២០២១-២០២៥ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គឆ្នាំ ២០២១-២០៣០។

ដំណាក់កាលទី ១ នៃគម្រោងរួមនេះ បានដំណើរការពីឆ្នាំ ២០១៨ ដល់ ២០១៩ និងបានបង្កើតយន្តការអភិបាលកិច្ចរួម ទន្ទឹមនឹងរៀបចំការវាយតម្លៃអនុអាងនេះ។ របាយការណ៍បច្ចេកទេសចំនួនបីត្រូវបានផលិតឡើង ដើម្បីកំណត់ស្ថានភាពបច្ចុប្បន្ននៃហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួត និងវិស័យអាទិភាពចំនួនប្រាំសម្រាប់សកម្មភាព និងលើកស្នើគោលគំនិតមួយឈុតសម្រាប់បង្កើតគម្រោងកាត់បន្ថយផលប៉ះពាល់ ដែលទាមទារឱ្យមានសមាហរណកម្មពេញលេញរវាងប្រទេសទាំងពីរ ការសម្របសម្រួលសកម្មភាព ឬការអនុវត្តក្នុងមូលដ្ឋាន។ វិស័យអាទិភាព និងចំណាត់ថ្នាក់ទាំងនេះ មានឆ្លុះបញ្ចាំងនៅក្នុងផែនការមេនេះ។ កិច្ចសហប្រតិបត្តិការដំណាក់កាលទី ២ នេះបានចាប់ផ្តើមអនុវត្តរួចហើយនូវវិស័យអាទិភាពចំនួនប្រាំ តាមរយៈការអភិវឌ្ឍន៍វេទិកាចែករំលែកព័ត៌មាន និងទិន្នន័យតាមគេហទំព័រ 9C-9T Basin Atlas ដោយគំនិតនៃបណ្ដាញវិធានការផ្អែកលើធម្មជាតិ ដើម្បីកសាងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងផ្ទៃអាង និងតាមរយៈការរៀបចំផែនទីបង្ហាញផ្លូវរួមគ្នាសម្រាប់ការរៀបចំផែនការមេអាងទន្លេ។

## ៣.២ ស្ថានភាពអាង

គម្រោងនេះផ្តោតលើអនុអាង 9C-9T ដែលលាតសន្ធឹងក្នុងប្រទេសកម្ពុជា និងប្រទេសថៃ (រូបភាពទី ១)។ អនុអាង 9C-9T មានផ្ទៃក្រឡា ១៤.៩៥២ គីឡូម៉ែត្រការ៉េ ក្នុងនោះប្រមាណ២៧,៣%ស្ថិតក្នុងប្រទេសថៃ(ហៅថាអាងទន្លេសាប)។ ផ្នែកធំជាងនៃអនុអាងនេះស្ថិតនៅភាគអាគ្នេយ៍ ដែលមានឈ្មោះថា អាងស្ទឹងមង្គលបូរីនៃប្រទេសកម្ពុជា មានផ្ទៃក្រឡា ១០.៨៦៦ គីឡូម៉ែត្រការ៉េ ឬ ៧២,៧% នៃវិសាលភាពសរុប និងគ្របដណ្តប់តំបន់ "វាលស្រែ" ទាំងមូលនៃខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិនដែលស្ថិតនៅជិតខាង។

---

[1]គណៈកម្មការទន្លេមេគង្គ ២០១៨។ សេចក្តីប្រកាសព័ត៌មាន: គណៈកម្មការទន្លេមេគង្គចាប់ផ្តើមគម្រោងរួមគ្នាដើម្បីគ្រប់គ្រងធនធានអាងទន្លេមេគង្គឱ្យកាន់តែប្រសើរឡើង និងដោះស្រាយបញ្ហាទឹកជំនន់ និងគ្រោះរាំងស្ងួត។ ព័ត៌មាននាថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ គណៈកម្មការទន្លេមេគង្គ វៀងច័ន្ទ។ URL: http://www.mrcmekong.org/news-and-events/news/launches-two-joint-projects-to-better-manage-the-mekong-basin-resources-and-address-flood-and-drought-issues/

*រូបភាពទី ១. ព្រំប្រទល់ និងតំបន់រយៈកំពស់នៃអនុអាង 9C-9T*




ព័ត៌មានគោលពិស្តារអំពីស្ថានភាពអនុអាងនេះ មាននៅក្នុងសៀវភៅផែនទីអនុអាង 9C-9T។ ជំពូករងខាងក្រោមផ្តល់សេចក្តីសង្ខេបអំពីស្ថានភាពសង្គម សេដ្ឋកិច្ច បរិស្ថាន និងការប្រែប្រួលអាកាសធាតុនៃអាងនេះ និងនិន្នាការ ដែលបានស្រង់ចេញពីសៀវភៅផែនទីអនុអាង 9C-9T ក្រៅពីនោះក៏មានការផ្តល់ប្រភពផងដែរសម្រាប់ព័ត៌មានដទៃទៀត។

## *៣.២.១ បរិស្ថាន*

អនុអាងនេះ ជាផ្នែកមួយដ៏សំខាន់មួយក្នុងការទ្រទ្រង់សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងវារីជីវចម្រុះក្នុងបឹងទន្លេសាប។ ឧទ្យានជាតិ (តាប្រាយ៉ា និងប៉ាងស៊ីដា) និងតំបន់ការពារធម្មជាតិផ្សេងទៀត ស្ថិតនៅក្នុងតំបន់ក្បាលទឹកនៃដៃស្ទឹងនានា ដែលភាគច្រើនមានទីតាំងក្នុងខេត្តនានានៃប្រទេសថៃ (រូបភាពទី ២)។ ការកែលំអ និងថែទាំតំបន់ទាំងនោះឱ្យមានប្រសិទ្ធភាព គឺជាកង្វល់ដ៏សំខាន់សម្រាប់ប្រទេសថៃ និងសម្រាប់ប្រទេសកម្ពុជានៅខ្សែទឹកខាងក្រោម។ តំបន់ការពារធម្មជាតិ នៅខ្ពង់រាបខាងលើនៃប្រទេសកម្ពុជា មានជាអាទិ៍ តំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត តំបន់ការពារទេសភាពអាងត្រពាំងថ្ម និងបន្ទាយឆ្មា។ តំបន់សំឡូត ជាតំបន់ប្រភពទឹកដ៏សំខាន់សម្រាប់សត្វក្រៀលដែលជិតផុតពូជនៅលើពិភពលោក។

តំបន់ទាំងនេះ ផ្តល់ទឹកដល់ស្ទឹងជាច្រើន ដែលមានប្រភពនៅទីជម្រាលភាគខាងលើក្នុងប្រទេសកម្ពុជា និងប្រទេសថៃ ហូរឆ្លងកាត់អនុអាង 9C-9T ទៅកាន់តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប នៅជិតច្រកចេញ មុនពេលបន្តហូរចូលទៅក្នុងបឹងទន្លេសាប។ តំបន់ទេសភាពចម្រុះនៃជីវចម្រុះនេះ មានសារៈសំខាន់ជាសាកល និងជាមុខព្រួញសំខាន់នៃការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងអនុអាងនេះឱ្យមានប្រសិទ្ធភាព។ ការប្រែប្រួលលើការប្រើប្រាស់ដី និងការរេចរិលនៃប្រព័ន្ធអេកូឡូស៊ី បានកើតឡើងនៅទូទាំងអនុអាង 9C-9T ជាមួយការបាត់បង់យ៉ាងច្រើននៃព្រៃឈើ និងតំបន់ដីសើម

ក្នុងរយៈពេល ៣០ ឆ្នាំកន្លងមកនេះ។ ការប្រើប្រាស់ដីនៅក្នុងអនុអាងនេះ ច្រើនតែជាការដាំដំណាំ ជាពិសេសនៅក្នុងខេត្តស្រះកែវ នៃប្រទេសថៃ និងទូទាំងតំបន់នេះនៅកម្ពុជា។ ជុំវិញខេត្តបាត់ដំបង គឺជាតំបន់ដំណាំស្រូវដ៏ធំ។ កសិកម្ម គឺជាវិស័យប្រើប្រាស់ទឹកដ៏សំខាន់នៅក្នុងអនុអាងនេះ ហើយងាយរងគ្រោះបំផុត ដោយសារគ្រោះរាំងស្ងួតផងដែរ។

គុណភាពទឹកនៅទូទាំងអនុអាង 9C-9T មានលក្ខណៈខុសគ្នា ដោយសារការអភិវឌ្ឍដែលមិនអាចគ្រប់គ្រងបាន និងការបំពុលទឹកនៅក្នុងតំបន់ទីក្រុង ការប្រើប្រាស់សារធាតុគីមីកសិកម្ម ការបាត់បង់គម្របរុក្ខជាតិភាគច្រើន ដែលអាចផ្តល់ជាចម្រោះធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់សម្រាប់ការគ្រប់គ្រងសំណល់រាវ និងសំណល់រឹង។ ទឹកជំនន់ធ្វើឱ្យទឹកកខ្វក់សាយភាយចូលក្នុងតំបន់កសិកម្ម ហើយក្នុងអំឡុងពេលមានគ្រោះរាំងស្ងួត សំណល់រាវបានប្រមូលផ្តុំក្នុងព្រែក ស្ទឹង និងអាងស្តុកទឹកនានា។

*រូបភាពទី ២. ស្ថានភាពភូមិសាស្ត្រសំខាន់ៗនៅក្នុងអនុអាង* ***9C-9T***




## ៣.២.២ សេដ្ឋកិច្ច

អត្រាកំណើនផ.ស.ស ជាមធ្យមប្រចាំឆ្នាំក្នុងប្រទេសថៃ មាន ៣,៦៨% ពីឆ្នាំ ១៩៩៤ ដល់ ២០១៩។ នៅឆ្នាំ ២០១១ ប្រទេសនេះបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។ កម្ពុជាបានបញ្ចប់ស្ថានភាពជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបនៅឆ្នាំ ២០១៥ និងមានអត្រាកំណើនមធ្យមថេរ ៨% រវាងឆ្នាំ ១៩៩៨ និង ២០១៨ ដែលធ្វើឱ្យកម្ពុជាស្ថិតក្នុងចំណោមសេដ្ឋកិច្ចលូតលាស់លឿនបំផុតលើពិភពលោក។ នៅឆ្នាំ២០១៩កំណើននៅតែមាន៧,១%។

អ្នកស្រុកភាគច្រើននៅក្នុងអនុអាង 9C-9T ប្រកបរបរចិញ្ចឹមជីវិតដែលផ្សារភ្ជាប់ទៅនឹងផលិតកម្មកសិកម្ម។ បាត់ដំបង និងបន្ទាយមានជ័យនៃប្រទេសកម្ពុជា ស្ថិតក្នុងចំណោមខេត្តដែលផលិតស្រូវច្រើនជាងគេ ហើយបាត់ដំបង គឺជាខេត្តនាំមុខសម្រាប់ពោត និងដំឡូងមី។ វិស័យទេសចរណ៍ រួមទាំង តំបន់ធម្មជាតិដែលផ្ដល់ភាពទាក់ទាញ ឧទ្យានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយទៀតនៃសេដ្ឋកិច្ច របស់ប្រទេសទាំងពីរ។

អនុអាង 9C-9T មានសារៈសំខាន់ខាងសេដ្ឋកិច្ច ជាមួយតំបន់សេដ្ឋកិច្ចពិសេសចំនួនពីរ ដែលតាំងនៅព្រំដែនកម្ពុជា-ថៃ ពោលគឺ ក្រុងប៉ោយប៉ែតនៃកម្ពុជា និងអារញ្ញប្រាថេត ក្នុងប្រទេសថៃ។ ព្រំដែនរវាងតំបន់ទាំងពីរនេះ គឺជាច្រកឆ្លងកាត់ដ៏មមាញឹកបំផុតរវាងកម្ពុជា និង ថៃ ដោយតភ្ជាប់ទីក្រុងសៀមរាប និងបាត់ដំបង ជាមួយទីក្រុងបាងកក។ ផ្លូវជាតិ ពីសៀមរាប គឺជាផ្នែកមួយនៃច្រករបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គខាងត្បូង ដែលជួបជាមួយផ្លូវជាតិដ៏ធំពីបាត់ដំបង នៅកណ្ដាលក្រុងសិរីសោភ័ណ។ តំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែត និងអារញ្ញប្រាថេត គឺជាតំបន់ដែលមានការពង្រីកយ៉ាងឆាប់រហ័សសម្រាប់ការអភិវឌ្ឍ និងជាមជ្ឈមណ្ឌលសំខាន់ៗនៅក្នុងខេត្តទាំងនេះ។ ទីប្រជុំជនមួយទៀតនៅខាងភាគីថៃ ដែលមានប្រជាជនប្រហាក់ប្រហែលនឹងក្រុងអារញ្ញប្រាថេត គឺទីរួមខេត្តស្រះកែវ។

រូបភាពទី ៣ បង្ហាញពីច្រករបៀងសេដ្ឋកិច្ច និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែននៃប្រទេសទាំងពីរ។

*រូបភាពទី ៣. ព្រំប្រទល់រដ្ឋបាលនៃអនុអាង 9C-9T*



### ៣.២.៣ បញ្ហាសង្គម

អនុអាង 9C-9T មានប្រជាជន ១,៤ លាននាក់។ ប្រជាជនចំនួន ០,៣៥ លាននាក់ រស់នៅក្នុងតំបន់នៃប្រទេសថៃក្នុងខេត្តស្រះកែវនៅភាគខាងជើង និងខេត្តចាន់ថាបុរីនៅភាគខាងត្បូង។ នៅខាងកម្ពុជា មានប្រជាពលរដ្ឋចំនួន ១,០៥លាននាក់។ ប្រជាជនភាគច្រើនប្រមូលផ្តុំតាមច្រករបៀងដឹកជញ្ជូនសំខាន់ៗ តំបន់ទីក្រុងធំៗ និងតាមព្រំដែននៃប្រទេសទាំងពីរ។

ស្រុកនៅជាប់ព្រំដែនអន្តរជាតិក្នុងប្រទេសថៃមានអត្រាខ្ពស់នៃពលករចំណាកស្រុក។ ពលរដ្ឋកម្ពុជាយ៉ាងច្រើន ដែលភាគច្រើនជាបុរស បានធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើនៅប្រទេសថៃ។ ផលប៉ះពាល់បរិស្ថានមាននាទីជំរុញការធ្វើចំណាកស្រុកនេះផងដែរ ជាពិសេសបន្ទាប់ពីគ្រោះរាំងស្ងួត និងការបាត់បង់ដំណាំ ទោះបីជាលក្ខខណ្ឌប្រាក់ឈ្នួលល្អប្រសើរ និងកង្វះកម្មសិទ្ធិដីធ្លី ក៏ជាកត្តាជំរុញផងដែរក៏ដោយ។

ស្ត្រីនៅជនបទ គឺជាតួអង្គសំខាន់នៅក្នុងសេដ្ឋកិច្ចជនបទ រួមចំណែកផ្តល់ ៨០% នៃផលិតកម្មស្បៀង។ ស្ត្រីមានអត្រា ៥១% នៃកម្លាំងពលកម្មបឋម នៅក្នុងវិស័យកសិកម្មសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ និង ៥៤% នៃកម្លាំងពលកម្មនៅក្នុងវិស័យកសិកម្មសម្រាប់លក់នៅទីផ្សារ។

ទោះបីមានការអភិវឌ្ឍសេដ្ឋកិច្ចឆាប់រហ័សនៅកម្ពុជា និង ថៃក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះក៏ដោយ អត្រានៃភាពក្រីក្រនៅក្នុងអនុអាង9C-9T នៅតែខ្ពស់។ ផែនទីអត្រាភាពក្រីក្រនៅកម្រិតឃុំ ក្នុងប្រទេសកម្ពុជាគិតត្រឹមឆ្នាំ ២០១៥ បង្ហាញថា យ៉ាងហោចណាស់ ១៥% នៃគ្រួសារនៅក្នុងតំបន់ 9C លើកលែងតែឃុំនានាក្នុងខេត្តបាត់ដំបង និងក្រុងសិរីសោភ័ណ។ ប្រទេសថៃមានអត្រាភាពក្រីក្រដែលបានរាយការណ៍នៅថ្នាក់ជាតិប្រមាណ ៩% នៅឆ្នាំ ២០១៧[2] ប៉ុន្តែផែនទីថ្នាក់ខេត្តបង្ហាញថា ខេត្តស្រះកែវនិងចាន់ថាបុរី មានអត្រាគ្រួសារក្រីក្រខ្ពស់ជាងខេត្តជុំវិញ ពោលគឺ១៥-២០%។

### ៣.២.៤ ការប្រែប្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុ គឺជាការប្រែប្រួលកម្រិតញឹកញាប់ និងភាពធ្ងន់ធ្ងរនៃគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត និងការបង្កើតឱ្យមានបញ្ហាប្រឈមថ្មីៗចំពោះសន្តិសុខទឹក។ ការធ្វើនិទស្សន៍អំពីការប្រែប្រួលអាកាសធាតុរបស់ MRC បានប្រើប្រាស់ម៉ូដែលចរន្តសកល(GCMs)ចំនួនបី និងសេណារីយ៉ូជាច្រើនសម្រាប់អាងទន្លេមេគង្គក្រោម។ ម៉ូដែល IPSL-CM5A-MR បង្ហាញលទ្ធផលដែលប្រែប្រួលខ្លាំងបំផុតតាមរដូវកាល និងត្រូវបានពិពណ៌នានៅទីនេះដោយប្រើសេណារីយ៉ូ RCP 8.5 រហូតដល់ឆ្នាំ ២០៥០។ ការប្រែប្រួលអាកាសធាតុក្នុងអនុអាង 9C-9T ទំនងបំផុតថា ស្ថិតក្នុងរង្វង់នៃរបាយនិទស្សន៍នេះ។

ផលប៉ះពាល់ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុមកលើកំពស់ទឹកភ្លៀង ទំនងជាសភាពខុសប្លែកគ្នា នៅទូទាំងអនុអាង 9C-9T និងតាមរដូវ។ កំពស់ទឹកភ្លៀងនៅរដូវប្រាំងត្រឹមឆ្នាំ ២០៥០ (រូបភាពទី ៤) ត្រូវបាននិទស្សន៍ថា នឹងថយចុះនៅតាមកន្លែងភាគច្រើននៃភូមិភាគកណ្តាល និងភាគខាងលិចនៃអនុអាងនេះ ដោយមានការថយចុះខ្លាំងបំផុតប្រហែល១១% នៅភាគខាងជើង។ ទន្ទឹមនឹងនេះ សីតុណ្ហភាពអតិបរិមាជាមធ្យមក្នុងរដូវប្រាំង ត្រូវបាននិទស្សន៍ថា នឹងកើនឡើងគួរឱ្យកត់សម្គាល់ ប្រមាណ ២,៤°C នៅទូទាំងអនុអាងនេះ។

[2] ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម (NESDC) in https://blogs.worldbank.org/eastasiapacific/reducing-poverty-and-improving-equity-thailand-why-it-still-matters

នៅរដូវវស្សា កំពស់ទឹកភ្លៀងក្នុងតំបន់នៃប្រទេសកម្ពុជា ត្រូវបាននិទស្សន៍ថា នឹងកើនឡើង ជាពិសេសនៅទិសខាងកើត រហូតដល់ប្រហែល ៥% (រូបភាពទី ៥)។ ប៉ុន្តែក្នុងទីជម្រាលភាគខាងលើនៃអនុអាងនេះក្នុងប្រទេសថៃ កំពស់ទឹកភ្លៀងនឹងនៅដដែល ឬអាចថយចុះបន្តិចបន្តួច។ គេរំពឹងថា របាយទឹកភ្លៀងកាន់តែលែងស្មើគ្នា និងមានភ្លៀងធ្លាក់កាន់តែខ្លាំង គិតត្រឹមឆ្នាំ ២០៥០។ និន្នាការទាំងនេះបង្ហាញពីព្រឹត្តការណ៍ទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលកាន់តែធ្ងន់ធ្ងរ ស្របជាមួយការប្រែប្រួលអាកាសធាតុ។

*រូបភាពទី ៤. ការប្រែប្រួលរបាយទឹកភ្លៀងក្នុងរដូវប្រាំងនៅឆ្នាំ ២០៥០ ក្នុងអនុអាងវង* 9C-9T




| Scenario / GCM | Unit | BL | 2050s |
|---|---|---|---|
| | | 1960-1990 | 2041-2060 |
| RCP 8.5 | | | |
| IPSL-CM5A-MR | | | |
| Average | mm | 229.7 | 206.9 |
| Percentage of change | % | | -11.0 |

*រូបភាពទី ៥. របាយទឹកភ្លៀងក្នុងរដូវវស្សា នៅក្នុងអាងរង 9C-9T គិតត្រឹមឆ្នាំ ២០៥០*




## ៣.៣ កត្តាជម្រុញហានិភ័យនៃទឹកជំនន់ និងគ្រោះរាំងស្ងួត

ស្ទឹង និងធនធានទឹកសាបនៃអនុអាង 9C-9T ផ្តល់ទឹកស្អាត សេវាប្រព័ន្ធអេកូឡូស៊ី ជីវចម្រុះក្នុងទឹក និងលើដី ដែលជាស្នូលនៃនិរន្តរភាពអេកូឡូស៊ីបឹងទន្លេសាប និងទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ១,៤លាននាក់ តាមរយៈកសិកម្ម ឧស្សាហកម្ម ការនេសាទ ទេសចរណ៍ និងពង្រីកសកម្មភាពពាណិជ្ជកម្ម និងការជួញដូរ។ សកម្មភាពអភិវឌ្ឍន៍ដែលច្រើនតែគ្មានការសម្របសម្រួល បានរួមចំណែកបង្កបញ្ហាប្រឈមធំៗនៃការកើនឡើងនូវទំហំ ភាពញឹកញាប់ និងភាពធ្ងន់ធ្ងរនៃទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងអនុអាងនេះ។ ទាំងការជន់លិចតាមដងស្ទឹង បណ្តាលពីជំនន់ខ្ពស់ជាងមាត់ច្រាំង និងបឹង និងការជន់លិចគំហុកបណ្តាលពីការធ្លាក់ភ្លៀងខ្លាំងនៅតំបន់ជុំវិញគឺជាក្តីកង្វល់នៅក្នុងអាងនេះ។ ពាក់ព័ន្ធនឹងគ្រោះរាំងស្ងួត កម្រិតទឹកទាបក្នុងទន្លេ និងបឹង ដែលបណ្តាលពីគ្រោះរាំងស្ងួតផ្នែកជលសាស្ត្រ និងកម្រិតទាបជាខ្លាំងនៃសំណើមដី ដូចដែលបានកើតឡើង នៅក្នុងគ្រោះរាំងស្ងួតកសិកម្ម គឺជាកង្វល់សំខាន់ដែលត្រូវដោះស្រាយ។ ទឹកជំនន់ឆ្នាំ ២០១១ និង ២០១៣ និងគ្រោះរាំងស្ងួតអែលនីញ៉ូធំៗនៅឆ្នាំ ២០១៥-២០១៦ និងម្តងទៀតនៅឆ្នាំ ២០១៩-២០២០ បានបណ្តាលឱ្យបាត់បង់អាយុជីវិត និងជីវភាពរស់នៅ និងការខូចខាតជាខ្លាំងចំពោះសេដ្ឋកិច្ចក្នុងអនុអាងនេះ។ ការលិចលង់ជាប្រចាំ ក៏កើតមាននៅតំបន់សេដ្ឋកិច្ចពិសេស(SEZ)នៅអារញ្ញប្រាថេត និងប៉ោយប៉ែត ដែលស្ថិតនៅសងខាងព្រំដែនកម្ពុជា-ថៃ នៅតំបន់ខាងលើនៃអនុអាងនេះផងដែរ។ បញ្ហាប្រឈមទាំងនេះបង្ហាញពីសារៈសំខាន់នៃអភិក្រមឆ្លងដែនសម្រាប់ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ដោយប្រទេសទាំងពីរ និងការប្តេជ្ញាដូចគ្នាចំពោះការគ្រប់គ្រងធនធានទឹកចម្រុះផងដែរ។

ដំណាក់កាលទី II នៃគម្រោងរួម 9C-9T បានពង្រីកការវិភាគស្ថានភាពទឹកជំនន់ និងគ្រោះរាំងស្ងួត ការកំណត់សំណុំលក្ខណៈរូបវន្តនៃអាង និងការបង្កើតម៉ូដែលជលសាស្ត្រដែលមានកម្រិតច្បាស់ខ្លាំងជាងមុន។ ផ្អែកលើម៉ូដែលទឹកជំនន់ដែលបង្កើតឡើងនៅក្នុងដំណាក់កាលទី I ការវិភាគនេះបានកំណត់អត្តសញ្ញាណកត្តាជំរុញសំខាន់ៗចំនួនបីនៃហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងអនុអាង 9C-9T៖

(i) សម្ពាធប្រជាជន ដែលរួមទាំង ការទន្ទ្រានយកដីប្រើប្រាស់ និងកំណើនតម្រូវការដីធ្លី។

(ii) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹងដោយគ្មានការសម្របសម្រួល និងមានការវាយតម្លៃតិចតួច។ និង

(iii) ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

កត្តាសំខាន់ៗទាំងបី រួមចំណែកធ្វើឱ្យមានការរេចរិលធ្ងន់ធ្ងរចំពោះទីជម្រាល និងហានិភ័យដែលពាក់ព័ន្ធទាំងសម្រាប់ទឹកជំនន់ និងគ្រោះរាំងស្ងួត។ ទីជម្រាលដែលមានសុខភាពល្អដែលមានគម្របរុក្ខជាតិ មានតួនាទីជាអេប៉ុង ក្នុងការរក្សាទុកទឹកនៅក្នុងទីជម្រាលភាគខាងលើ និងបញ្ចេញទឹកនេះមកទីជម្រាលភាគខាងក្រោមជាបន្តបន្ទាប់។ សម្ពាធនៃកំណើនចំនួនប្រជាជន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹង និងការប្រែប្រួលអាកាសធាតុ កំពុងធ្វើឱ្យសមត្ថភាពនេះថយចុះ ដែលនាំឱ្យអនុអាង 9C-9T បាត់បង់សមត្ថភាពធម្មជាតិក្នុងការជ្រោះ និងស្តុកទឹក ការកើនឡើងនៃបរិមាណទឹកភ្លៀងធ្លាក់ហូរនៅលើផ្ទៃដីទៅក្នុងតំបន់ទំនាប និងការកើនឡើងនៃសំណឹក និងកំណកល្បាប់។ និន្នាការទាំងនេះធ្វើឱ្យគុណភាពទឹកថយចុះ កាត់បន្ថយសន្តិសុខទឹក និងបង្កើនសក្តានុពលទឹកជំនន់។ ស្ថានភាពទាំងនេះកាន់តែធ្ងន់ធ្ងរដោយសារការប្រែប្រួលអាកាសធាតុ។

## *៣.៣.១ កំណើនចំនួនប្រជាជន*

កំណើនចំនួនប្រជាជនកំពុងដាក់សម្ពាធមកលើដីធ្លី និងធនធានទឹកក្នុងអនុអាងនេះ។ ការពង្រីកទីក្រុងយ៉ាងឆាប់រហ័ស និងកំណើនចំនួនប្រជាជននៅក្នុងអនុអាងនេះ ជាពិសេសនៅអារញ្ញប្រាថេតក្នុងប្រទេសថៃ និងប៉ោយប៉ែតក្នុងប្រទេសកម្ពុជា កំពុងបង្កើនករណីជំនន់គំហុកទឹកភ្លៀង និងតម្រូវការទឹក។ កង្វះការរៀបចំផែនការរូបវន្តចម្រុះ ដើម្បីសម្រួលដល់កំណើនចំនួនប្រជាជន កំពុងរួមចំណែកធ្វើឱ្យមានកំណើនការទន្ទ្រានចូលកាន់កាប់តំបន់ធម្មជាតិ ដូចជា ព្រៃឈើ តំបន់ដីសើម និងផ្លូវទឹក។ ស្ថានភាពនេះកាត់បន្ថយសមត្ថភាពនៃប្រព័ន្ធធម្មជាតិទាំងនោះ ក្នុងការទប់ស្កាត់ផលប៉ះពាល់នៃទឹកជំនន់ និងគ្រោះរាំងស្ងួត។

## *៣.៣.២ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹង*

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹងនៅទូទាំងអាងនេះ បានកើតឡើងដោយភាគច្រើនគ្មានការសម្របសម្រួល ក្នុងនោះគម្រោងនានា ត្រូវបានអនុវត្តបែប/ជាលក្ខណៈចំពោះកិច្ចដែលធ្វើឡើងដោយស្ថាប័ននីមួយៗ និងដោយគ្មានការកសាងផែនការនិងការវាយតម្លៃហេតុប៉ះពាល់បណ្តុំនៅទូទាំងទីជម្រាលឡើយ។ អភិក្រមដាច់ពីគ្នាបែបនេះនៃការអភិវឌ្ឍ បានកាត់ផ្តាច់ទំនាក់ទំនងជលសាស្ត្រនៃទីជម្រាល ដែលនាំមកនូវផលប៉ះពាល់ដែលមិនរំពឹងទុក និងមិនបានគ្រោងទុក និងការរេចរិលជាលំដាប់នៃអាងនេះ ដោយបង្កើតឱ្យមានទឹកជំនន់ និងគ្រោះរាំងស្ងួតកាន់តែធ្ងន់ធ្ងរឡើង។ ហេដ្ឋារចនាសម្ព័ន្ធទឹកដែលមានស្រាប់នៅក្នុងអនុអាង 9C-9T មានបានបង្ហាញក្នុងរូបភាពទី ៦។

*រូបភាពទី ៦. ហេដ្ឋារចនាសម្ព័ន្ធទឹកក្នុងអនុអាង* 9C-9T




អវត្តមានការវាយតម្លៃប្រកបដោយប្រសិទ្ធភាពនៃផលប៉ះពាល់នៅតំបន់ខ្សែទឹកខាងលើ/ខាងក្រោមនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធទាំងនេះ ឬផលប៉ះពាល់បណ្ដុំនៃគម្រោងទាំងនេះ ជាពិសេស សម្រាប់ទំនប់ និងអាងស្ដុកទឹកខ្នាតធំ និងគម្រោងខ្នាតតូចដែលមានស្រាប់រាប់រយ និងគម្រោងដែលគ្រោងអនុវត្ត គួរតែបានឆ្លងកាត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ការកសាងផែនការចម្រុះ និងការវាយតម្លៃហេតុប៉ះពាល់ឆ្លងដែនដែលមានកម្រិតកំណត់ ពុំជានាថា ការអភិវឌ្ឍនានានៅតំបន់ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោមក្នុងប្រទេសទាំងពីរ នាំមកនូវអត្ថប្រយោជន៍ឡើយ។ គណៈកម្មាធិការអាងទន្លេដែលត្រូវបានបង្កើតឡើងសម្រាប់អាងទន្លេសាប 9T ក្នុងប្រទេសថៃ និងសម្រាប់អនុអាងស្ទឹងមង្គលបូរីដែលនៅជាប់គ្នានេះ ក្នុងប្រទេសកម្ពុជា បច្ចុប្បន្ននៅខ្វះសមាជិកភាពមកពីអន្តរវិស័យ ដែលជាលក្ខខណ្ឌតម្រូវសម្រាប់សម្រួលដល់ការគ្រប់គ្រងធនធានទឹកចម្រុះ។ កង្វះការបន្សុីគ្នារវាងគោលនយោបាយ និងដំណើរការរៀបចំផែនការអាងទន្លេនៅក្នុងប្រទេសទាំងពីរមានន័យថា ឱកាសដើម្បីសហប្រតិបត្តិការ និងពិគ្រោះយោបល់នៅក្នុងការអនុវត្តជាក់ស្ដែង ពុំមានភាពច្បាស់លាស់ឡើយ។ ជាលទ្ធផល ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត មិនត្រូវបានបញ្ជ្រាបនៅក្នុងការប្រើប្រាស់ដី និងការកសាងផែនការអភិវឌ្ឍន៍ទូទាំងតំបន់ជនបទ និងទីក្រុងនោះឡើយ។

## *៣.៣.៣ ការប្រែប្រួលអាកាសធាតុ*

ការប្រែប្រួលអាកាសធាតុត្រូវបាននិទស្សន៍ថា នឹងធ្វើឱ្យប្រែប្រួលរបាយទឹកភ្លៀងនិងសីតុណ្ហភាព និងបង្កើនទំហំនៃព្រឹត្តិការណ៍ទឹកជំនន់និងគ្រោះរាំងស្ងួត ពន្លឿនការបាត់បង់ដីជាតិដី និងធនធានធម្មជាតិ នៅក្រោមការគ្រប់គ្រងបច្ចុប្បន្ន។

ការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ មានសារៈសំខាន់ក្នុងការកាត់បន្ថយហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួត និងធានាសុខភាពរយៈពេលវែងនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី របរចិញ្ចឹមជីវិត និងសហគមន៍នៅក្នុងអនុអាងរួមនេះ។

កិច្ចការពារនិងកែលំអទីជម្រាលឡើងវិញ មានសារៈសំខាន់ណាស់ក្នុងការទប់ទល់នឹងកម្លាំងទាំងនេះ។ សារៈសំខាន់ជាពិសេសគឺ ការកែលំអឡើងវិញ និងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាពនូវតំបន់ទេសភាពព្រៃឈើនៅតំបន់ខ្សែទឹកខាងលើ និងច្រករបៀងបង្ហូរទឹកក្នុងតំបន់កសិកម្មនៃអាងធំៗ ដោយសង្កត់ធ្ងន់លើអភិក្រមប្រព័ន្ធអេកូឡូស៊ី។ ដូចគ្នានេះដែរ តំបន់ទីក្រុងដែលកំពុងពង្រីកយ៉ាងឆាប់រហ័ស ទាមទារឱ្យមានការរៀបចំផែនការរូបវន្តយ៉ាងប្រុងប្រយ័ត្ន នវានុវត្តន៍លើវិស័យទឹក និងការពង្រីកគម្របបៃតង ដើម្បីកាត់បន្ថយហានិភ័យនៃទឹកជំនន់ គ្រោះរាំងស្ងួត និងលក្ខខណ្ឌកាន់តែអាក្រក់នៃបរិស្ថាន។ ទីជម្រាលដែលមានសុខភាពល្អ នឹងបង្កើនភាពធន់ និងផលិតភាពនៃហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និងដែលបានគ្រោងទុក ដោយជួយសម្រួលលំហូរទឹក និងកំណកល្បាប់ និងពុំតម្រូវឱ្យមានការថែទាំច្រើនឡើយ។

មានការវិនិយោគនៅតាមភូមិសាស្ត្រជាក់ស្តែងត្រឹមតិចតួចប៉ុណ្ណោះ លើការបន្សុំនឹងការប្រែប្រួលអាកាសធាតុ ដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី តាមរយៈការស្តារឡើងវិញនូវទីជម្រាល និងតំបន់ការពារធម្មជាតិនៅក្នុងអនុអាង 9C-9T ឬតំបន់ជិតខាង។ ការវិនិយោគភាគច្រើន ផ្តោតលើអាងស្តុកទឹក និងប្រព័ន្ធស្រោចស្រព និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដែលរងការប៉ះពាល់ពីការរេចរិលកាន់តែខ្លាំងឡើងនៃទីជម្រាល សំណឹក កំណកល្បាប់ និងការខូចខាតដោយសារទឹកជំនន់។ ការវិនិយោគនៅក្នុងបឹងទន្លេសាប ជាប់នឹងភាគខាងក្រោមនៃអនុអាងទឹក 9C-9T ក៏រងការគំរាមកំហែង បណ្តាលពីការខូចខាតតំបន់ទេសភាព និងធនធានទឹកនៃអនុអាង 9C-9T និងទឹកជំនន់ និងគ្រោះរាំងស្ងួតដែលពាក់ព័ន្ធផងដែរ។

ប្រទេសទាំងពីរនៅមានឱកាសដើម្បីអនុវត្តដំណោះស្រាយផ្អែកលើធម្មជាតិ ដែលជាវិធានការចាំបាច់សម្រាប់ការបំពេញបន្ថែម និងធ្វើឱ្យប្រសើរឡើងនូវអាយុកាលនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធរឹង ទន្ទឹមនឹងការស្តារ និងកែលំអឡើងវិញនូវទីជម្រាល ការផ្តល់ពហុប្រយោជន៍ដល់ជីវភាពរស់នៅ ភាពងាយស្រួលរស់នៅនៃទីក្រុង សមភាពយេនឌ័រនិងសង្គម ជីវចម្រុះ និងការបន្សុំទៅនឹងការប្រែប្រួលអាកាសធាតុ។ ការអនុវត្តដំណោះស្រាយផ្អែកលើធម្មជាតិ គឺជាការវិនិយោគអាទិភាព ដើម្បីកសាងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។

## ៣.៤ ការឆ្លើយតប និងកាលានុវត្តភាព

រដ្ឋាភិបាលទាំងពីរកំពុងឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃទឹកជំនន់ និងគ្រោះរាំងស្ងួត ជាមួយការប្តេជ្ញាចិត្តកាន់តែខ្លាំងក្លាក្នុងការគ្រប់គ្រងធនធានទឹកចម្រុះ និងការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹងនៅគ្រប់កម្រិត។ សកម្មភាពនេះ មានជាអាទិ៍ ការបញ្ចូលជាអាណត្តិ និងការពង្រឹងដំណើរការកសាងផែនការនៅកម្រិតអាងទន្លេ ការវិនិយោគលើការបន្សុំនឹងការប្រែប្រួលអាកាសធាតុ និងការយកចិត្តទុកដាក់ចំពោះកិច្ចសហប្រតិបត្តិការអន្តរវិស័យ និងនៅពហុកម្រិត។ រួមជាមួយសកម្មភាពដើម្បីកាត់បន្ថយកត្តាជំរុញសំខាន់ៗចំនួនបីនៃទឹកជំនន់ និងគ្រោះរាំងស្ងួត ការឆ្លើយតបជាមូលដ្ឋាននេះ បញ្ជាក់ពីហេតុផលសម្រាប់ការកសាងផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួតសម្រាប់អនុអាង 9C-9T។

### *៣.៤.១ ការកសាងផែនការអាងទន្លេ*

ប្រទេសទាំងពីរបានធ្វើបច្ចុប្បន្នភាពបទដ្ឋានគតិយុត្តរបស់ខ្លួនដែលជាការប្តេជ្ញាលើការគ្រប់គ្រងធនធានទឹកចម្រុះ និងការកសាងផែនការគ្រប់គ្រងអាងទន្លេ។ នៅកម្ពុជា ការប្តេជ្ញាចិត្តនេះបានបង្ហាញតាមរយៈអនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេឆ្នាំ ២០១៥ ក្រោមច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក (២០០៧) ដែលអនុវត្តដោយ MoWRAM ។ ក្នុងប្រទេសថៃ

អភិក្រមនេះត្រូវបានបញ្ចូលនៅក្នុងច្បាប់ស្តីពីធនធានទឹកឆ្នាំ ២០១៨ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងឆ្នាំ ២០១៩ ដែលមាន ONWR មាននាទីជាស្ថាប័នសម្របសម្រួល និងគាំទ្របច្ចេកទេស។ ការអនុវត្តច្បាប់របស់ប្រទេសថៃ បានធ្វើឡើងស្របតាមផែនការមេសម្រាប់រយៈពេល ២០ ឆ្នាំ ស្តីពីការគ្រប់គ្រងធនធានទឹក (២០១៨ – ២០៣៧) រួមទាំងការប្តេជ្ញាចិត្តនៅក្រោមយុទ្ធសាស្ត្រទី ៥ សម្រាប់ "ការអភិរក្ស និងស្តារឡើងវិញនូវព្រៃលិចទឹកដែលខូចគុណភាព និងកិច្ចការពារទល់នឹងសំណឹកដី"។

ច្បាប់ទាំងនេះកំណត់អាណត្តិក្នុងការបង្កើតគណៈកម្មាធិការអាងទន្លេ និងការកសាងផែនការសម្រាប់អាងទន្លេនីមួយៗ ដែលត្រូវគាំទ្រដោយគណៈកម្មាធិការនៅថ្នាក់ជាតិ។ ផែនការអាងទន្លេមួយ ត្រូវបានរៀបចំសម្រាប់អនុអាង 9C-9T ក្នុងប្រទេសថៃ ហើយគណៈកម្មាធិការអាងទន្លេសាប 9T កំពុងអនុវត្តកិច្ចការនេះ។ ផែនការអាងទន្លេនៃប្រទេសថៃ ត្រូវបានពិនិត្យ និងរៀបចំសម្រាប់អាងទន្លេនីមួយៗរៀងរាល់ប្រាំឆ្នាំម្តង ជាមួយវិស័យសមស្រប ដែលជាអ្នករួមចំណែកអនុវត្ត និងផ្តល់ថវិកា។ កម្ពុជាមានចេតនាស្រដៀងគ្នាក្នុងការបង្កើតគណៈកម្មាធិការអាងទន្លេ និងរៀបចំផែនការអាង ប៉ុន្តែប្រទេសទាំងពីរមានបញ្ហាប្រឈម ក្នុងការទាក់ទាញឱ្យមានការចូលរួមពិតប្រាកដពីវិស័យនានា នៅក្នុងការអនុវត្តផែនការ និងការឈាន ទៅរកអភិក្រមរួមមួយនៃការកំណត់បញ្ជីឈ្មោះគម្រោង ដែលជាមូលដ្ឋាននៃការកសាងផែនការចម្រុះ។

នៅកម្ពុជា ផែនការអាងមួយត្រូវបានអនុម័តនៅឆ្នាំ ២០១៥ ០សម្រាប់អនុអាងដែលនៅជិតខាង ប៉ុន្តែមិនទាន់មានការរៀបចំ និងការអនុម័តផែនការថ្មីណាមួយឡើយ ចាប់តាំងពីមានអនុក្រឹត្យឆ្នាំ ២០១៥មក។ កម្ពុជាមានបំណងបង្កើតផែនការមេអាងទន្លេ សម្រាប់អាងទន្លេទាំង ៣៩របស់ខ្លួន។ ប៉ុន្តែ ប្រទេសនេះពុំទាន់មានគណៈកម្មាធិការអាងទន្លេ ឬផែនការសម្រាប់អនុអាង 9C-9T សម្រាប់កម្ពុជានៅឡើយទេ។ ប្រទេសថៃ មានសេចក្តីព្រាងផែនការមេគ្រប់គ្រងធនធានទឹក (២០២០-២០៣៧)សម្រាប់អាងទន្លេសាប ដែលបានចេញផ្សាយក្នុងខែកញ្ញា ឆ្នាំ២០២០ ដែលរួមទាំងផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់ឆ្នាំ ២០២០-២០២២ផងដែរ។

ភាពចាំបាច់ក្នុងការឈានមិនត្រឹមតែទៅរកការចុះបញ្ជីគម្រោងហេដ្ឋារចនាសម្ព័ន្ធ ប៉ុន្តែទៅរកផែនការ IWRM ត្រូវបាន ONWR ទទួលស្គាល់ ដោយមានការផ្តួចផ្តើមធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (SEA) សម្រាប់គ្រប់អាងទន្លេក្នុងប្រទេសថៃ ដើម្បីផ្តល់ព័ត៌មានកាន់តែច្បាស់ដល់ដំណើរការរៀបចំផែនការ។ ចំពោះផែនការថ្មីៗសម្រាប់អាងទន្លេ បច្ចុប្បន្នមានការដាក់បញ្ចូល គោលបំណង និងសកម្មភាពឆ្លើយតបទៅនឹងវិស័យយុទ្ធសាស្ត្រនីមួយៗទាំង ៦ នៃផែនការមេធនធានទឹករបស់ជាតិសម្រាប់រយៈពេល ២០ឆ្នាំ។ គោលដៅគឺថា ការកែសម្រួលផែនការអាងទន្លេនៅក្នុងវដ្តក្រោយៗ ត្រូវអនុលោមតាមដំណើរការ SEA។ នៅកម្ពុជា ពុំមានការចែងច្បាស់អំពីក្របខ័ណ្ឌផែនការសម្រាប់អាងទន្លេឡើយ។ ការប្តេជ្ញាចិត្តចំពោះ SEAs ត្រូវបានដាក់បញ្ចូលក្នុងសេចក្តីព្រាងថ្មីនៃក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលក្រសួងបរិស្ថានកំពុងរៀបចំតាំងពីឆ្នាំ ២០១៥មក ប៉ុន្តែពុំទាន់មានទំនាក់ទំនងខាងផ្លូវច្បាប់ជាមួយការរៀបចំផែនការ និងការគ្រប់គ្រងអាងទន្លេនោះទេ។

ខណៈដែលស្ថាប័នរដ្ឋាភិបាលបង្កើនការបញ្ជ្រាបយេនឌ័រ ការពិចារណាអំពីក្រុមងាយរងគ្រោះផ្សេងទៀត ក៏អាចនឹងត្រូវពង្រឹងផងដែរ។ ប្រការចាំបាច់គឺ ត្រូវសង្កត់ធ្ងន់បន្ថែមទៀត ដើម្បីបង្ហាញគោលការណ៍ទាំងនេះ ក្នុងផែនការតាមវិស័យ និងផែនការអាងទន្លេ។ នៅមានគម្លាតដ៏សំខាន់មួយទៀត ដែលទាក់ទងនឹងការត្រួតពិនិត្យ និងការវាយតម្លៃសម្រាប់ផែនការអាងទន្លេ ជាពិសេស នៅកម្ពុជា។ ចាប់តាំងពីការអនុម័តនៅឆ្នាំ ២០១៥មក កម្ពុជាពុំបានធ្វើឱ្យមានវឌ្ឍនភាពជាក់ស្តែងលើការអនុវត្តផែនការអាងដែលមានស្រាប់តែមួយសម្រាប់ស្ទឹងស្រែងនោះឡើយ។ ប្រទេសទាំងពីរនៅត្រូវពង្រឹងការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យអាងទន្លេ។

## *៣.៤.២ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរឹងក្នុងវិស័យទឹក*

កម្ពុជា និងថៃកំពុងធ្វើការវិនិយោគសំខាន់ៗលើហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធស្រោចស្រព ប្រព័ន្ធដោះទឹក និងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកនៅក្នុងអនុអាង 9C-9T។ សម្រាប់វិស័យទឹក ប្រទេសទាំងពីរមានផែនការមេអភិវឌ្ឍន៍តាមតំបន់ ដែលបន្តសង្កត់ធ្ងន់លើអភិក្រមតាមវិស័យ សម្រាប់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរឹង ជាពិសេសសម្រាប់ការបង្កើនផ្ទៃដីស្រោចស្រព ឬហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធដោះទឹក ដោយពុំមានការវាយតម្លៃ និងកិច្ចការពារបរិស្ថានគ្រប់គ្រាន់ឡើយ។ ជាលទ្ធផល ការវិនិយោគនាពេលបច្ចុប្បន្នដែលឆ្លើយតបទៅនឹងទឹកជំនន់ និងគ្រោះរាំងស្ងួត បានផ្តោតជាខ្លាំងតែលើហេដ្ឋារចនាសម្ព័ន្ធរឹង ហើយខ្វះការគិតគូរអន្តរវិស័យនិងការវាយតម្លៃផលប៉ះពាល់បណ្តុំ ដែលចាំបាច់សម្រាប់ការគ្រប់គ្រងធនធានទឹកចម្រុះ។

នៅកម្ពុជា MoWRAM មានគម្រោងដែលកំពុងអនុវត្ត និងក្នុងការគ្រោង ដើម្បីស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពដែលមានស្រាប់និងសាងសង់អាងស្តុកទឹកខ្នាតធំថ្មីៗនៅក្នុងតំបន់ 9C។ គម្រោងទាំងនោះ រួមមាន ផែនការគាំទ្រដោយកូរ៉េ សម្រាប់ក្រុងសិរីសោភ័ណក្នុងខេត្តបន្ទាយមានជ័យ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដោយ ADB សម្រាប់តំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែត រួមទាំង ការកសាងផែនការប្រព្រឹត្តកម្មសំណល់ និងការកែលំអប្រឡាយដោះទឹកភ្លៀង។

ប្រទេសថៃបានរៀបចំផែនការមេរយៈពេល ១៥ឆ្នាំសម្រាប់អាង Huai Phrom Hoad ក្នុងស្រុកអារញ្ញប្រាថេត នៃខេត្តស្រះកែវ ហើយបានកំណត់គម្រោងចំនួន ១៦២ ជាការឆ្លើយតបទៅនឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងអាង និងតំបន់សេដ្ឋកិច្ចពិសេសនោះ។ វិធានការនានា រួមមាន កម្មវិធីបូមស្តារ និងកំចាត់រុក្ខជាតិ ក្នុងអាងស្តុកទឹកនានា ការជួសជុលប្រព័ន្ធស្រោចស្រព និងការពង្រឹងផែនការបែងចែកទឹកសម្រាប់ដោះស្រាយគ្រោះរាំងស្ងួត។ វិធានការ'ទន់'ដែលអមជាមួយ ក៏ត្រូវបានស្នើឡើងផងដែរ ដើម្បីកែលម្អការគ្រប់គ្រងអាងស្តុកទឹក និងកែលម្អការប្រកាសផ្តល់ព័ត៌មាន ដែលទាក់ទងនឹងទឹកជំនន់ កិច្ចសហប្រតិបត្តិការ និងប្រព័ន្ធព័ត៌មាន។

នាយកដ្ឋានសមុទ្រកំពុងធ្វើការវាយតម្លៃស្ទឹងធំៗដែលហូរកាត់អារញ្ញប្រាថេត ដើម្បីធ្វើការបូមស្តារ ក្នុងបំណងកែលម្អការដោះទឹក និងកាត់បន្ថយការជន់លិចច្រាំងស្ទឹង ដោយគ្រោងអនុវត្តនៅឆ្នាំ ២០៣០។ អនុសាសន៍ពីការសិក្សាមួយស្តីពីការរៀបចំផែនការ និងកាត់បន្ថយទឹកជំនន់សម្រាប់អាងទន្លេសាប ដោយមន្ទីរសាធារណការ និងការរៀបចំផែនការទីក្រុង និងប្រទេស នៅក្នុងប្រទេសថៃ បានរួមបញ្ចូល ការរៀបចំគោលការណ៍ណែនាំអំពីការប្រើប្រាស់ដីផងដែរ។

## *៣.៤.៣ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ទឹកជំនន់ និងគ្រោះរាំងស្ងួត*

ប្រទេសទាំងពីរកំពុងវិនិយោគលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ជាមួយលក្ខខណ្ឌតម្រូវឱ្យមានផែនការសកម្មភាពបន្សាំតាមវិស័យនិងតាមខេត្ត។ គម្រោងមួយដែលទើបបញ្ចប់ថ្មីៗ ស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដែលគាំទ្រដោយ ADB មានបញ្ចូល ការកសាងសមត្ថភាពមន្ត្រីថ្នាក់ខេត្តនៅក្នុងខេត្តបាត់ដំបង។ សកម្មភាពសំខាន់មួយគឺ ការរៀបចំឯកសារមគ្គុទ្ទេសក៍បន្សាំសម្រាប់ដំណោះស្រាយផ្អែកលើធម្មជាតិដែលពាក់ព័ន្ធសម្រាប់វិស័យចំនួនបួន៖ កសិកម្ម សាធារណការ ទឹក និងបរិស្ថាន។ ការតាមដានរបស់ ADB លើការគ្រប់គ្រងបរិស្ថានទីក្រុងលំដាប់ទីពីរ នៅក្នុងគម្រោងអាងបឹងទន្លេសាប សម្រាប់ការកែលម្អសេវាកម្មទីក្រុង និងលើកកម្ពស់ភាពធន់នឹងអាកាសធាតុនៅក្នុងក្រុងចំនួនបីគឺ ក្រុងសេរីសោភ័ណ (ខេត្តបន្ទាយមានជ័យ) បាត់ដំបង (ខេត្តបាត់ដំបង) និងស្ទឹងសែន (ខេត្តកំពង់ធំ) មានបញ្ចូល ការវាយតម្លៃទូលំទូលាយនូវភាពងាយរងគ្រោះចំពោះមុខការប្រែប្រួលអាកាសធាតុ ដែលនាំទៅរកការកែប្រែការរចនាប្លង់ ដោយការបង្កើនលំដាប់ផ្លូវ និងពង្រីកសមត្ថភាពដោះទឹក។

នៅតំបន់ខ្សែទឹកខាងក្រោមនៃអាងទឹក 9C-9T បឹងទន្លេសាបកំពុងទទួលបានការវិនិយោគយ៉ាងសំខាន់ តាមរយៈកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាពនិងបរិយាប័ន្ន(CAPFISH) ជាមួយ សមាសភាគវារីវប្បកម្ម និងសមាសភាគការនេសាទ។ ធនាគារ KfW បានគាំទ្រដល់ការកែលំអតំបន់ដីសើម និងការគ្រប់គ្រងទីជម្រក ដែលកំពុងស្ថិតក្នុងការអនុវត្តជាពិសេស នៅតំបន់រ៉ាមសារព្រែកទាល់។ គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា ដែលបំពេញបន្ថែមដោយ WB និង GEF ក៏មានបញ្ចូលផងដែរនូវ ការវិនិយោគសម្រាប់បឹងទន្លេសាប និងតំបន់ទ្រនាប់ ដោយផ្តោតលើការកំណត់តំបន់គ្រប់គ្រង និងការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ ព្រមទាំងការវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ដែលរួមទាំង សម្រាប់តំបន់ព្រែកទាល់ ប៉ុន្តែពុំមានបញ្ចូលវិធានការកែលំអដីធ្លី ឬទឹកឡើយ។ ការវិនិយោគនៅតំបន់ខ្សែទឹកខាងក្រោមទាំងនេះ មានសារៈសំខាន់ណាស់ និងគួរតែបានទទួលការគាំទ្រ ដោយការវិនិយោគដូចគ្នានេះ ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់ទីជម្រាលនានាផងដែរ។

ការិយាល័យគោលនយោបាយ និងផែនការធនធានធម្មជាតិ និងបរិស្ថានរបស់រដ្ឋាភិបាលថៃ (ONEP) បានបង្កើតផែនការមេស្តីពីការប្រែប្រួលអាកាសធាតុក្នុងឆ្នាំ ២០១៥ និងផែនការបន្សាំថ្នាក់ជាតិ(NAP)ក្នុងឆ្នាំ ២០១៩។ បច្ចុប្បន្ន ONEP កំពុងធ្វើការយ៉ាងសកម្មលើគោលការណ៍ណែនាំ NAP ដែលរួមបញ្ចូល ព័ត៌មានលម្អិតសម្រាប់ការអនុវត្តវិធានការបន្សាំដោយស្ថាប័នថ្នាក់ខេត្ត ក្រុង និងប្រតិបត្តិ។ NAP តម្រូវឱ្យស្ថាប័នរដ្ឋាភិបាលទាំងអស់បង្កើត និងអនុវត្តគោលនយោបាយបន្សាំសម្រាប់អំឡុងឆ្នាំ ២០១៨-២០២១។ វិស័យជាគោលដៅទាំងប្រាំមួយនៃ NAPគឺ៖ ការគ្រប់គ្រងទឹក, កសិកម្ម និងសន្តិសុខស្បៀង, ការគ្រប់គ្រងទេសចរណ៍, ការគ្រប់គ្រងសុខភាពសាធារណៈ, ការគ្រប់គ្រងធនធានធម្មជាតិ, និងការតាំងទីលំនៅនិងសន្តិសុខមនុស្ស។ កម្មវិធីសហការរវាង GIZ និង ONEP កំពុងស្វែងរកការរៀបចំផែនការសកម្មភាពប្រែប្រួលអាកាសធាតុសម្រាប់ខេត្តចំនួន១៧ និងក្រុងចំនួន៣២ ដែលនឹងគ្របដណ្តប់ខេត្តស្រះកែវ និងខេត្តចាន់ថាបុរីផងដែរ។

## *៣.៤.៤ ជលសាស្ត្រ- ឧតុនិយម និងការប្រកាសផ្តល់ព័ត៌មានអំពីទឹកជំនន់ និងគ្រោះរាំងស្ងួត*

នៅកម្ពុជា និងថៃ មានប្រព័ន្ធថ្នាក់ជាតិសម្រាប់ការប្រកាសផ្តល់ព័ត៌មាន ជាមួយកម្មវិធីទូរស័ព្ទ ឬការផ្ញើសារដែលត្រូវបានបង្កើតឡើង ទោះបីពុំមានវិសាលភាពគ្របដណ្តប់ទូលំទូលាយក៏ដោយ។ ប្រទេសទាំងពីរមាននាយកដ្ឋាន និងមជ្ឈមណ្ឌលជាច្រើនដែលមានបណ្តាញស្ថានីយ៍ជលសាស្ត្រ-ឧតុនិយម និងឧបករណ៍ចាប់សញ្ញាពីផ្កាយរណប និងលំដាប់ថ្នាក់នានានៃការប្រកាសផ្តល់ព័ត៌មាន និងការគ្រប់គ្រងគ្រោះមហន្តរាយ។ ប្រទេសទាំងពីរពុំមានយន្តការផ្លូវការសម្រាប់ការផ្លោះប្តូរទិន្នន័យ និងព័ត៌មានក្នុងពេលជាក់ស្តែង សម្រាប់អំឡុងពេលព្រឹត្តិការណ៍ទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងអនុអាង 9C-9T ឡើយ។ សហគមន៍តាមព្រំដែន ពុំបានតភ្ជាប់ទៅប្រព័ន្ធប្រកាសផ្តល់ព័ត៌មានអំពីទឹកជំនន់ឡើយ ដែលនេះមានន័យថា យន្តការដែលមានស្រាប់សម្រាប់ការប្រកាសផ្តល់ព័ត៌មានរបស់ថៃ មិនបានផ្សព្វផ្សាយដល់ប្រទេសកម្ពុជាឡើយ។ ការប្រើប្រាស់និមិត្តសញ្ញាក្នុងការប្រកាសផ្តល់ព័ត៌មានអំពីទឹកជំនន់និងគ្រោះរាំងស្ងួត គ្មានភាពស៊ីសង្វាក់គ្នាឡើយ។ ចំនួនអ្នកស្លាប់ និងការខូចខាតកម្រិតខ្ពស់ដែលកើតមាននៅក្នុងអនុអាង 9C-9T ក្នុងឆ្នាំ ២០១២-២០១៣, ២០១៦-១៦ និងនៅឆ្នាំ ២០២០ បង្ហាញច្បាស់អំពីភាពចាំបាច់ឱ្យមានការកែលំអព័ត៌មាន និងការប្រកាសផ្តល់ព័ត៌មានអំពីទឹកជំនន់ និងគ្រោះរាំងស្ងួត ជាពិសេស នៅថ្នាក់ក្រោមជាតិ។

MRC បានបង្កើតប្រព័ន្ធណែនាំអំពីទឹកជំនន់គំហុក ក្នុងអាងទន្លេមេគង្គសម្រាប់ប្រទេសទាំងពីរ និងគ្របដណ្តប់អនុអាងទឹក 9C-9T ប៉ុន្តែគេមានការព្រួយបារម្ភថា ដំណោះស្រាយនេះមិនគ្រប់គ្រាន់ដើម្បីណែនាំប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលមិនបានឆ្លើយតប នៅចំពោះមុខការប្រកាសជូនដំណឹងមិនត្រឹមត្រូវជាច្រើនលើកនោះឡើយ។ ឧបសគ្គមួយចំពោះការ

ប្រកាសផ្តល់ព័ត៌មានឱ្យបានប្រសើរជាងមុននៅតាមមូលដ្ឋាន គឺបណ្តាញស្ថានីយ៍ជលសាស្ត្រ-ឧតុនិយមដែលស្ថិតនៅដាច់ឆ្ងាយពីគ្នាពេក។ នៅកម្ពុជា ស្ថានីយ៍ជលសាស្ត្រ-ឧតុនិយមពុំស្ថិតនៅលើទីតាំងសមស្របសម្រាប់ជូនព័ត៌មានអំពីទឹកជំនន់ឡើយ។ ជាពិសេស ទឹកជំនន់គំហុក នៅតែបន្តជាបញ្ហាប្រឈមមួយសម្រាប់ការព្យាករណ៍ និងតាមដាន។ ដូចគ្នានេះផងដែរ ស្ថានីយ៍ភាគច្រើនវាស់តែកម្រិតកំពស់ទឹកប៉ុណ្ណោះ តែមិនមែនវាស់លំហូរឡើយ ដោយសារពុំបាន បង្កើតការគណនាមុខកាត់ទន្លេ និងក្រាហ្វិកខ្សែកោងវាយតម្លៃលំហូរទឹកនោះឡើយ។

ពាក់ព័ន្ធនឹងលំហូរឆ្លងដែន មានស្ថានីយ៍វាស់វែងចរន្តទឹកត្រឹមតិចតួចប៉ុណ្ណោះ នៅតំបន់ខ្សែទឹកខាងក្រោមនៃដងស្ទឹងធំៗក្នុងប្រទេសថៃ មុនហូរឆ្លងកាត់ព្រំដែនចូលមកប្រទេសកម្ពុជា ដោយសារតំបន់នេះពុំមែនជាអាទិភាពសម្រាប់នាយកដ្ឋាននៃប្រទេសថៃ។ ប្រការនេះរារាំងការប្រកាសផ្តល់ព័ត៌មានអំពីទឹកជំនន់ និងការវាយតម្លៃលំហូរបរិស្ថាន ព្រមទាំងការកសាងផែនការ និងការគ្រប់គ្រងធនធានទឹក។ យោងតាមផែនការឆ្នាំ ២០១៦-២០៣០ នៃមន្ទីរធនធានទឹក ការឆ្លើយតបរបស់រដ្ឋាភិបាលក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធស្ថានីយ៍ជលសាស្ត្រ-ឧតុនិយម ពាក់ព័ន្ធនឹងគម្រោងគាំទ្រដោយ ADB និង AFD ជាពិសេសនៅក្នុងខេត្តបាត់ដំបង និងការដំឡើងស្ថានីយ៍បន្ថែមសម្រាប់ប្រកាសផ្តល់ព័ត៌មានអំពីទឹកជំនន់គំហុកនៅក្នុងខេត្តស្រះកែវ។

## *៣.៤.៥ ការចែករំលែកទិន្នន័យឆ្លងដែន*

រដ្ឋាភិបាលទាំងពីរបាននិងកំពុងវិនិយោគលើការប្រមូលទិន្នន័យថ្មីៗ ប៉ុន្តែពុំមានការបង្កើតយន្តការសម្រាប់ការចែករំលែកទិន្នន័យជាប្រព័ន្ធរវាងកម្ពុជា និងថៃ សម្រាប់អនុអាង 9C-9Tឡើយ។ គម្រោងរួមនេះ បានចាប់ផ្តើមដោះស្រាយតម្រូវការសម្រាប់ការចែករំលែកព័ត៌មានអំពីទឹកជំនន់ និងគ្រោះរាំងស្ងួត ជាមួយការបង្កើតផែនទីទឹកជំនន់សម្រាប់អនុអាង 9C-9T ការបង្កើតម៉ូដែលជលសាស្ត្រដែលមានកម្រិតច្បាស់ខ្លាំង និងការរៀបចំធ្វើនិទស្សន៍ការប្រែប្រួលអាកាសធាតុ។ លទ្ធផលសំខាន់មួយនៃដំណាក់កាលបច្ចុប្បន្ន (២០១៩-២០២១) គឺសៀវភៅផែនទីអាង 9C-9T[3] - កម្រងទិន្នន័យរួមមួយអំពីចំណេះដឹង និងព័ត៌មាន សម្រាប់ជាប្រព័ន្ធគាំទ្រការសម្រេចចិត្តខាងភូមិសាស្ត្រតាមគេហទំព័រសម្រាប់អនុអាងនេះ និងបញ្ជីដំណោះស្រាយផ្អែកលើធម្មជាតិ សម្រាប់ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត ដើម្បីគាំទ្រដល់ការកសាងផែនការរួមគ្នា។ ប្រទេសថៃបានបង្ហាញចំណាប់អារម្មណ៍រួចហើយ ក្នុងការចម្លងយកសៀវភៅផែនទីអនុអាង 9C-9T ជាឧបករណ៍គាំទ្រការកសាងផែនការសម្រាប់ការអនុវត្តនៅក្នុងអាងដទៃទៀតនៃប្រទេសថៃ។

បច្ចុប្បន្ន ពុំមានពិធីសារសម្រាប់ការថែទាំ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យគាំទ្រការសម្រេចចិត្ត និងព័ត៌មានដែលបានបញ្ចូលទៅក្នុងសៀវភៅផែនទីអាង 9C-9T ថ្មីនេះទេ។ បណ្តាញស្ថានីយ៍ជលសាស្ត្រ-ឧតុនិយម នៅក្នុងអនុអាងនេះ ស្ថិតនៅដាច់ឆ្ងាយពីគ្នាជាខ្លាំង និងផ្តល់ព័ត៌មានត្រឹមតិចតួចអំពីលំហូរឆ្លងដែន។ ប្រសិទ្ធភាពទាបនៃការប្រកាសផ្តល់ព័ត៌មានទៅថ្នាក់ក្រោមជាតិ ឬ អនុស្សរណៈនៃការយោគយល់ឆ្លងដែនសម្រាប់ការទំនាក់ទំនងទៅកាន់តំបន់ខ្សែទឹកខាងក្រោម សម្រាប់គ្រាមានទឹកជំនន់ និងគ្រោះរាំងស្ងួត មានន័យថា ការខូចខាតទំនងជាកើនឡើង ស្របជាមួយ កំណើនភាពញឹកញាប់នៃទឹកជំនន់ និងគ្រោះរាំងស្ងួត ដោយសារការប្រែប្រួលអាកាសធាតុ និងការរេចរិលនៃទីជម្រាល។

---

[3] សៀវភៅផែនទី 9C-9T – ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅកម្ពុជា និងថៃ។ URL: **9C9T Atlas (icem.com.au)**

# ៤ .ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាព

## ៤.១ ហេតុផល

**បញ្ហា**ដែលផែនការមេស្វែងរកដំណោះស្រាយគឺ ភាពងាយរងគ្រោះរបស់សហគមន៍ខ្មែរ និងថៃ នៅក្នុងអនុអាងរួម 9C-9T នៅចំពោះមុខការកើនឡើងនៃកម្រិតញឹកញាប់ ទំហំ និងផលប៉ះពាល់នៃទឹកជំនន់ និងគ្រោះរាំងស្ងួត ក្រោមសម្ពាធនៃកំណើនចំនួនប្រជាជន ការប្រែប្រួលអាកាសធាតុ និងការរេចរិលទីជម្រាល។

**ដំណោះស្រាយដែលបានស្នើឡើង**គឺ ពង្រឹងយន្តការ និងស្ថាប័នរួមគ្នា ផែនការសកម្មភាព ការត្រួតពិនិត្យ និងសម្របសម្រួលសកម្មភាព ដើម្បីវិនិយោគលើបណ្តាញតភ្ជាប់នៃការបន្សាំតាមប្រព័ន្ធអេកូឡូស៊ី និងដំណោះស្រាយផ្អែកលើធម្មជាតិ និងចម្រុះ នៅទូទាំងអនុអាងនេះ និងដើម្បីគ្រប់គ្រងហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួត និងសុវត្ថិភាពទឹកជារួម នៅក្នុងអភិក្រមចម្រុះនៃទីជម្រាលឆ្លងដែន។

## ៤.២ ទិដ្ឋភាពទូទៅនៃការប្តេជ្ញាចិត្តដែលមានស្រាប់ខាងគោលនយោបាយ

ផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួតសម្រាប់អនុអាង 9C-9T ទទួលយកការណែនាំគោលនយោបាយយុទ្ធសាស្ត្រទៅតាមឋានានុក្រមនៃទិសដៅយុទ្ធសាស្ត្រ និងការប្តេជ្ញាចិត្តដែលធ្វើឡើងដោយកម្ពុជា និងថៃ៖

១. កិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត
២. យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គឆ្នាំ ២០២១ - ២០៣០ & ផែនការយុទ្ធសាស្ត្ររបស់ MRC ឆ្នាំ ២០២១ - ២០២៥ និងសន្ទស្សន៍ផែនការជាតិឆ្នាំ ២០២១-២០២៥
៣. អាទិភាពយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងប្រទេសថៃ
៤. ទិសដៅយុទ្ធសាស្ត្រនៃគម្រោងរួមអនុអាង 9C-9T ដំណាក់កាលទី ១ ដែលបានអនុម័តដោយគណៈកម្មាធិការតម្រង់ទិសថ្នាក់តំបន់ក្នុងឆ្នាំ ២០១៨។

### *៤.២.១ កិច្ចព្រមព្រៀងអន្តរជាតិស្តីពីទឹកជំនន់ និងគ្រោះរាំងស្ងួត*

កម្ពុជា និងថៃ គឺជាភាគីនៃអនុសញ្ញាទីក្រុងរីយ៉ូចំនួនបី(រូបភាពទី៧) - អនុសញ្ញាសហប្រជាជាតិស្តីពីជីវចម្រុះជីវសាស្ត្រ(CBD) អនុសញ្ញាសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងវាលខ្សាច់ស្ថានកម្ម(UNCCD) និងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC)- ដែលជាកិច្ចព្រមព្រៀងសំខាន់ៗសម្រាប់ណែនាំគោលនយោបាយជាតិ និងសកម្មភាពសម្រាប់ដោះស្រាយទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងអាងទន្លេជាតិនិងឆ្លងដែន។ ប្រទេសទាំងពីរក៏ជាហត្ថលេខីនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) ក្របខ័ណ្ឌសេនដាយសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងអនុសញ្ញារ៉ាមសារស្តីពីតំបន់ដីសើមផងដែរ។ យុទ្ធសាស្ត្រជាតិ ផែនការអភិវឌ្ឍន៍និងកម្មវិធីសកម្មភាពនៅកម្ពុជា និងថៃ បានប្រឹងប្រែង អនុវត្តកិច្ចព្រមព្រៀងអន្តរជាតិទាំងនេះនៅក្នុងវិស័យនេះ។ រដ្ឋាភិបាលជាតិទាំងពីរ រាយការណ៍ជាទៀងទាត់អំពីវឌ្ឍនភាពក្នុងការបំពេញការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងក្រប ខ័ណ្ឌអន្តរជាតិសំខាន់ៗទាំងនេះ។

រូបភាពទី ៧. កិច្ចព្រមព្រៀងអនុសញ្ញាទាំងបីនៅទីក្រុងរីយ៉ូសម្រាប់ការស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ




កិច្ចព្រមព្រៀង និងពិធីសារពាក់ព័ន្ធផ្សេងៗ ដែលភ្ជាប់នឹងគោលនយោបាយអន្តរជាតិទាំងនេះ បានផ្តល់ការណែនាំបន្ថែមដល់កម្ពុជា និងថៃ និងដល់គណៈកម្មការទន្លេមេគង្គ។

**ក្របខ័ណ្ឌសេនដាយ ២០១៥-២០៣០** គឺជាការប្តេជ្ញាចិត្តជាអន្តរជាតិដែលពាក់ព័ន្ធបំផុត ឆ្ពោះទៅកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ ឧទាហរណ៍ ក្របខ័ណ្ឌនេះលើកកម្ពស់"កិច្ចសហប្រតិបត្តិការឆ្លងដែន ដើម្បីបើកឱ្យមានដំណើរការគោលនយោបាយ និងផែនការ សម្រាប់ការអនុវត្តអភិក្រមផ្អែកលើប្រព័ន្ធអេកូឡូស៊ី ដែលទាក់ទងនឹងធនធានរួម ដូចជានៅក្នុងអាងទន្លេ"(វាក្យខណ្ឌ ២៨(ឃ)) និងការពង្រឹង"ការប្រើប្រាស់និងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីដោយនិរន្តរភាព និងអនុវត្តអភិក្រមគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិចម្រុះ ដែលរួមបញ្ចូលការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (DRR)" (វាក្យខណ្ឌ ៣០(ឈ)) ដោយយោងជាពិសេស ចំពោះទឹកជំនន់ និងគ្រោះរាំងស្ងួត។

ក្របខ័ណ្ឌសេនដាយ ធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធជាមួយកិច្ចព្រមព្រៀងរបៀបវារៈឆ្នាំ២០៣០ផ្សេងទៀត ដែលរួមទាំង UNFCCC កិច្ចព្រមព្រៀងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ និងចុងក្រោយគឺ SDGs ដែលទាំងពីរនេះបានបញ្ចូល DRR ជាផ្នែកសំខាន់មួយនៃការអភិវឌ្ឍដោយចីរភាព ការដោះស្រាយទំនាក់ទំនងរវាងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការបន្សាំ និង DRR។

**របៀបវារៈឆ្នាំ ២០៣០ សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព** ដែលត្រូវគេស្គាល់ថាជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព មានបញ្ចូលចំណុចដៅអនុវត្ត IWRM នៅគ្រប់កម្រិត ដែលរួមទាំង តាមរយៈកិច្ចសហប្រតិបត្តិការឆ្លងដែន (ចំណុចដៅ ៦.៥) ដើម្បីការពារ និងស្តារប្រព័ន្ធអេកូឡូស៊ីដែលទាក់ទងនឹងទឹក ដែលរួមទាំង ភ្នំ ព្រៃឈើ តំបន់ដីសើម ទន្លេ ល្អាងទឹកក្រោមដី និងបឹង (ចំណុចដៅ ៦.៦) និងដើម្បីបង្វែរទិសនៃឱនភាពដី ដែលត្រូវបានចាត់ទុកថាជា កត្តាជំរុញដ៏សំខាន់ចំពោះគ្រោះមហន្តរាយនានា (គោលដៅទី ១៥)។

នៅកម្ពុជា SDGs កំពុងត្រូវបានអនុវត្ត តាមរយៈការបង្កើតស្ថាប័ន និងយន្តការនានា ការបង្កើតក្របខ័ណ្ឌ SDG កម្ពុជា សមាហរណកម្មជាមួយនឹងការរៀបចំផែនការជាតិ និងថវិកាសាធារណៈ ដូចមានឆ្លុះបញ្ចាំងក្នុងអាទិភាពនៃផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី IV (RS-IV) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០១៩-២០២៣។ ការប្តេជ្ញាចិត្តទាំងនេះ មានចែងកាន់តែលម្អិតនៅក្នុងផែនការ និងគោលនយោបាយអភិវឌ្ឍន៍នៃវិស័យពាក់ព័ន្ធ ដូចជា MOWRAM ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ដែលជំរុញការកសាងផែនការអាងទន្លេ អភិក្រម IWRM និងការស្តារប្រព័ន្ធអេកូឡូស៊ី ដែលជាយុទ្ធសាស្ត្រសម្រាប់កាត់បន្ថយហានិភ័យគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។

យុទ្ធសាស្ត្រជាតិរយៈពេល ២០ ឆ្នាំ នៃប្រទេសថៃ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិលើកទី ១៣ ព្យាយាមអនុវត្ត SDGs រួមទាំង ការផ្តល់អាទិភាពដល់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការគ្រប់គ្រងទឹកចម្រុះ និងនិរន្តរភាពកសិកម្ម។ ប្រទេសថៃ គឺជាអ្នកគាំទ្រដ៏ខ្លាំងក្លាលើក្របខ័ណ្ឌសេនដាយ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (២០១៥-២០៣០) ដែលបានបង្ហាញតាមរយៈ ច្បាប់ស្តីពីកិច្ចការពារ និងកាត់បន្ថយគ្រោះមហន្តរាយឆ្នាំ ២០០៥ ផែនការជាតិបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយឆ្នាំ ២០១៥ និងផែនការមេគ្រប់គ្រងធនធានទឹក ២០១៨-២០៣៧។

**កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ**នៅក្រោម UNFCCC ជាប់ជាកាតព្វកិច្ចស្របច្បាប់លើភាគីនានា និងទទួលស្គាល់ក្របខ័ណ្ឌសេនដាយ។ កិច្ចព្រមព្រៀងនេះ មានបញ្ចូលបទប្បញ្ញត្តិជាច្រើនដែលចាំបាច់សម្រាប់ IWRM និងការគ្រប់គ្រងធនធានទឹកឆ្លងដែន ដូចជា៖ ការពង្រឹងមូលដ្ឋានចំណេះដឹង ការចែករំលែកព័ត៌មាន ចំណេះដឹង និងបទពិសោធន៍ ការត្រួតពិនិត្យនិងការវាយតម្លៃផែនការ និងការសម្រេចបានភាពធន់នៃអេកូឡូស៊ី។ កម្ពុជាកំពុងអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ (CCCSP) និងផែនការសកម្មភាព

ប្រែប្រួលអាកាសធាតុ(CCAP)ចំនួនដប់ប្រាំ ដើម្បីលើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈឧទាហរណ៍ ការកែលម្អសន្តិសុខស្បៀង ទឹក និងថាមពល និងធានាភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ ជីវចម្រុះ តំបន់ការពារ និងតំបន់បេតិកភណ្ឌវប្បធម៌។ CCAPs ផ្តោតលើវិស័យដែលមានព័ត៌មានលម្អិតអំពីការវិភាជន៍ថវិកាទៅក្រសួងនីមួយៗ ដើម្បីអនុវត្តផែនការដែលពាក់ព័ន្ធ ដូចជា កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការគ្រប់គ្រងគ្រោះមហន្តរាយ ធនធានទឹក និងឧតុនិយម ហេដ្ឋារចនាសម្ព័ន្ធជនបទ ការដឹកជញ្ជូន ការគ្រប់គ្រងដីធ្លី ការកសាងផែនការទីក្រុង សំណង់ និងបរិស្ថាន។

ប្រទេសថៃកំពុងអនុវត្តផែនការមេរបស់ខ្លួនស្តីពីការប្រែប្រួលអាកាសធាតុ(CCMP) ២០១៥ – ២០៥០ និងបានភ្ជាប់ផែនការជាតិបន្សាំ(NAP)នឹងការប្រែប្រួលអាកាសធាតុ ដែលផ្អែកលើអាទិភាពផែនការមេចំនួនប្រាំមួយ ដែលសង្កត់ធ្ងន់លើការគ្រប់គ្រង និងការស្តារប្រព័ន្ធទឹក និងធម្មជាតិ។ NAP និងផែនទីបង្ហាញផ្លូវថ្នាក់ជាតិស្តីពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុ បានបង្ហាញតាមរយៈផែនការសកម្មភាពតាមវិស័យ និងផែនការអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន។

**អនុសញ្ញាស្តីពីជីវចម្រុះ**ទទួលស្គាល់តួនាទីនៃជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងការផ្តល់សេវាដែលកាត់បន្ថយមុខសញ្ញាគ្រោះថ្នាក់នៃទឹកជំនន់និងគ្រោះរាំងស្ងួត និងភាពងាយរងគ្រោះរបស់សហគមន៍។ កម្ពុជាបានប្រឹងប្រែងជាខ្លាំងក្នុងការអនុវត្តអនុសញ្ញាជីវចម្រុះ និងគោលដៅជីវៈចម្រុះអៃជីទាំង២០។ ផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិស្តីពីជីវៈចម្រុះ (NBSAP)(២០១៦) ត្រូវបានដាក់ឱ្យអនុវត្ត តាមរយៈយុទ្ធសាស្ត្រនិងផែនការជាតិជាច្រើន ដូចជាផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣, របាយការណ៍ជាតិលើកទីពីរទៅ UNFCCC, កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងឱនភាពដី ២០១៨-២០២៧ ក្រោមអនុសញ្ញាសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងរហោស្ថានកម្ម និងគោលដៅស្ម័គ្រចិត្តសម្រាប់អព្យាក្រឹតភាពនៃឱនភាពដី ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិឆ្នាំ ២០១៧ យុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣ និងក្រមបរិស្ថាននិងធនធានធម្មជាតិកម្ពុជា។

ប្រទេសថៃក៏បានគាំទ្រយ៉ាងខ្លាំងចំពោះការអនុវត្តអនុសញ្ញាជីវចម្រុះ និងគោលដៅអៃជីរបស់ខ្លួន។ រដ្ឋធម្មនុញ្ញថៃ (ឆ្នាំ ២០១៧) ធានាសិទ្ធិរបស់ប្រជាពលរដ្ឋ និងសហគមន៍ក្នុងការប្រើប្រាស់ប្រកបដោយនិរន្តរភាព និងការពារជីវៈចម្រុះ ហើយតម្រូវឱ្យរដ្ឋគ្រប់គ្រងសកម្មភាពដែលអាចប៉ះពាល់ដល់ប្រព័ន្ធធម្មជាតិ។ ការប្តេជ្ញាចិត្តចំពោះការអភិរក្សនិងការស្តារឡើងវិញនូវជីវៈចម្រុះ មានចែងលម្អិតក្នុងផែនការមេចម្រុះសម្រាប់ការគ្រប់គ្រងជីវចម្រុះ(២០១៥-២០២១)។ នេះជាធាតុផ្សំដ៏សំខាន់មួយនៃយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍនិងកំណើនដែលមានមេត្រីភាពជាមួយបរិស្ថាន (២០១៨-២០៣៧) ផែនការជាតិគ្រប់គ្រងបរិស្ថាន (២០១៧-២០២១) ផែនការមេផ្សេងទៀតសម្រាប់យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍដោយចីរភាព ដែលរួមទាំង ផែនការសេដ្ឋកិច្ចជាតិ និងអភិវឌ្ឍន៍សង្គមលើកទី១៣។ ដូចកម្ពុជាដែរ ប្រទេសថៃបានសម្រេចចំណុចដៅនៅក្រោមអនុសញ្ញា CBD ឆ្នាំ ២០២០ ត្រឹម១៧% (ចំណុចដៅអៃជី ១១)។ រដ្ឋាភិបាលថៃមានបំណងបង្កើនតួលេខនេះឱ្យដល់យ៉ាងហោចណាស់២៥%នៃផ្ទៃប្រទេស នៅត្រឹមឆ្នាំ២០២៥។

**អនុសញ្ញាសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម**(UNCCD) បានបង្ហាញចំណុចដៅដើម្បីសម្រេចបាននូវអព្យាក្រឹតភាពនៃឱនភាពដីធ្លីនៅក្នុងប្រទេសទាំងពីរ គិតត្រឹមឆ្នាំ ២០៣០។ កម្ពុជាមានបំណងបង្កើនគម្របព្រៃឈើឱ្យដល់ ៤៧% នៃផ្ទៃដីសរុបរបស់ប្រទេស; បង្កើនកំណើនកសិកម្មឱ្យបាន៥% ក្នុងមួយឆ្នាំៗ ធៀបនឹង ៣% ក្នុងឆ្នាំ ២០១៦; បង្កើនស្តុកកាបូនសរីរាង្គនៃដីនៅក្នុងព្រៃឈើ និងដីដំណាំឱ្យបាន ១,២% ក្នុងមួយឆ្នាំៗ ធៀបនឹងឆ្នាំ ២០១៥ និងរក្សា និងលើកកំពស់ប្រព័ន្ធអេកូឡូស៊ី និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដោយបង្កើតព្រៃការពារទំហំ ២៣.៥០០ គីឡូម៉ែត្រការ៉េ និងព្រៃឈើ

ផលិតកម្ម ៣,៩០០គីឡូម៉ែត្រការ៉េ ព្រមទាំងស្តារឡើងវិញយ៉ាងហោចណាស់ ៨%នៃតំបន់ការពារធម្មជាតិដែលរេចរិល និង បាត់បង់សក្តានុពល តំបន់អភិរក្ស ប្រព័ន្ធអេកូឡូស៊ីកសិកម្ម និងប្រព័ន្ធអេកូឡូស៊ីព្រៃឈើ រួមទាំង ព្រៃកោងកាង។

ចំណុចដៅរបស់ប្រទេសថៃមានលក្ខណៈស្រដៀងគ្នានេះ ប៉ុន្តែមិនសូវជាក់លាក់ទេ។ ចំណុចដៅទាំងនោះមានបំណង បង្កើនសមាមាត្រគម្របព្រៃឈើជាតិ តាមរយៈការដាំដើមឈើឡើងវិញ និងការស្តារឡើងវិញនូវព្រៃឈើដែលរេចរិល, កែលំអ និងស្តារឡើងវិញនូវដីដែលខូចគុណភាព ឱ្យមានផលិតភាពឡើងវិញ ដោយសង្កត់ធ្ងន់លើនិរន្តរភាពកសិកម្ម និងកាត់បន្ថយការបាត់បង់កាបូនក្នុងដី ព្រមទាំង បង្កើនសម្រួបកាបូននៃដី តាមរយៈការអភិរក្សដី និងទឹក និងលើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងដីធ្លី។

**ជំហានបន្ទាប់សម្រាប់កម្ពុជា និងថៃ ក្នុងការគាំទ្រសកម្មភាពជាសាកល ដើម្បីកាត់បន្ថយការគំរាមកំហែងនៃទឹកជំនន់ និងគ្រោះរាំងស្ងួត៖** នៅឆ្នាំនេះ ទាំងកម្ពុជា និងថៃ បានចូលរួមក្នុងកិច្ចប្រជុំលើកទី ១៥ នៃសន្និសីទភាគី (COP 15) នៃអនុសញ្ញាស្តីពីជីវៈចម្រុះ(CBD) នៅទីក្រុងគុនមីង ប្រទេសចិន ក្នុងខែតុលា ឆ្នាំ ២០២១ - បន្តដោយកិច្ចប្រជុំចុះហត្ថលេខានៅខែមេសា ឆ្នាំ ២០២២ - និងសម័យប្រជុំលើកទី ២៦ នៃសន្និសិទភាគីក្នុងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ក្នុងខែវិច្ឆិកា ឆ្នាំ ២០២១ នៅចក្រភពអង់គ្លេស។

សន្និសីទភាគីលើកទី១៥ (COP 15) នៃអនុសញ្ញា CBD កំពុងដើរតួនាទីឈានមុខ នៅក្នុងការកំណត់របៀបវារៈសកល នាពេលអនាគតសម្រាប់និរន្តរភាពអេកូឡូស៊ី ដោយអនុម័តក្របខ័ណ្ឌជីវចម្រុះសកល (GBF) រយៈពេលដប់ឆ្នាំដល់ឆ្នាំ ២០៣០ ជាមួយចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។ ក្របខ័ណ្ឌទាំងនេះអំពាវនាវដល់ភាគីនានាឱ្យបញ្ឈប់ការដួលរលំនៃប្រព័ន្ធធម្មជាតិដើម្បីសម្រេចបាន *ចំណុចដៅអាកាសធាតុទីក្រុងប៉ារីស* និងដើម្បីសម្រេចបាននូវ *គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ* ដោយការអភិរក្សយ៉ាងហោចណាស់ ៣០% នៃផ្ទៃដី និង ៣០% នៃវិសាលភាពសមុទ្រ តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ស្មើភាព តំណាងដោយប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធតភ្ជាប់យ៉ាងល្អនៃតំបន់ការពារធម្មជាតិ។ អនុសញ្ញានេះក៏អំពាវនាវឱ្យមានការបង្កើនលំហូរហិរញ្ញវត្ថុអន្តរជាតិឱ្យបាន ២០០ ពាន់លានដុល្លារពីគ្រប់ប្រភពទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ការស្តារឡើងវិញ និងការអភិរក្សជីវចម្រុះផងដែរ។ CBC COP 15 ផ្តួចផ្តើមទសវត្សរ៍សហប្រជាជាតិស្តីពីការស្តារប្រព័ន្ធអេកូឡូស៊ីឆ្នាំ ២០២១ – ២០៣០ ដែលអំពាវនាវដល់សមាជិកទាំងអស់ឱ្យទប់ស្កាត់ បញ្ឈប់ និងបង្វែរទិសនៃការរេចរិលប្រព័ន្ធអេកូឡូស៊ីទូទាំងពិភពលោក ដើម្បីបង្កើតបណ្តាញអេកូឡូស៊ី និងការតភ្ជាប់គ្នាតាមរយៈច្រករបៀងអេកូឡូស៊ី កាត់បន្ថយការកាត់ផ្តាច់ជាបំណែកនិងការគាំទ្រឱ្យមានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ គោលគំនិតស្នូលនៅពីក្រោយសេចក្តីអំពាវនាវនេះគឺ ការងាកចេញពីការកាត់បន្ថយការបាត់បង់ជីវចម្រុះ ទៅរកកំណើនជីវៈចម្រុះ តាមរយៈការស្តារឡើងវិញ និងការគ្រប់គ្រងដោយប្រសិទ្ធភាព។

សន្និសីទភាគីលើកទី ២៦(COP 26) នៃ UNFCCC បានសង្កត់ធ្ងន់លើភាពចាំបាច់បន្ទាន់ក្នុងការបង្កើនមូលនិធិដើម្បីជួយប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការលើកកម្ពស់ការបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងភាពចាំបាច់ដើម្បីទប់ស្កាត់ កាត់បន្ថយ និងដោះស្រាយការបាត់បង់ និងការខូចខាត។ ប្រទេសជាង ១២០ បានប្តេជ្ញាចិត្តក្នុងការបញ្ឈប់ និងបង្វែរទិសនៃការបាត់បង់ព្រៃឈើ និងឱនភាពដីធ្លី នៅត្រឹមឆ្នាំ ២០៣០ និងដើម្បីជំរុញការអភិវឌ្ឍដោយចីរភាព និងលើកកម្ពស់ការកែប្រែជាបរិយាបន្ននៅជនបទ។ ការកាប់បំផ្លាញព្រៃឈើគឺជាប្រធានបទសំខាន់មួយក្នុងចំណោមប្រធានបទសំខាន់ៗចំនួនបួនដែលត្រូវដោះស្រាយហើយការបញ្ឈប់ និងការបង្វែរទិសនៃការបំផ្លិចបំផ្លាញព្រៃឈើឱ្យបានត្រឹមឆ្នាំ

២០៣០ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាកំណើនកំដៅផែនដីនៅក្នុងរង្វង់ ១,៥ អង្សា។ កិច្ចការនេះក៏នឹងកាត់បន្ថយការគំរាមកំហែងនៃទឹកជំនន់ និងគ្រោះរាំងស្ងួត និងរួមចំណែកដល់ការគ្រប់គ្រងធនធានទឹកឱ្យមានប្រសិទ្ធភាពផងដែរ។

### *៤.២.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គ ឆ្នាំ ២០២១-២០៣០*

នៅថ្នាក់តំបន់ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គ (BDS) ២០២១-២០៣០ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ យុទ្ធសាស្ត្រនេះផ្តោតលើវិស័យអាទិភាពចំនួនប្រាំៈ ការកែលម្អមុខងារអេកូឡូស៊ីនៃអាងទន្លេមេគង្គសម្រាប់បរិស្ថានដែលមានសុខភាពល្អ និងសហគមន៍ដែលមានផលិតភាព បង្កើនលទ្ធភាពទទួលបាន និងប្រើប្រាស់ទឹក និងធនធានពាក់ព័ន្ធដើម្បីសុខុមាលភាពសហគមន៍ ចីរភាពនៃការអភិវឌ្ឍដើម្បីកំណើនសេដ្ឋកិច្ចជាបរិយាបន្ន ភាពធន់នឹងអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយ និងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ផ្អែកលើទស្សនៈទាននៃអាងទន្លេទាំងមូល។

យុទ្ធសាស្ត្រ BDS ថ្មីនេះ ផ្អែកលើការវាយតម្លៃនាពេលថ្មីៗនេះអំពីផលប៉ះពាល់សំខាន់ៗបណ្តាលមកពីការអភិវឌ្ឍធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ រួមទាំង ទំនប់ទឹក ដែលបានកែប្រែរបបលំហូរ ប៉ះពាល់ដល់ការបញ្ជូនកំណកល្បាប់ និងកំណើនការបាក់ច្រាំង។ ផលប៉ះពាល់ទាំងនេះបាននាំឱ្យបរិមាណត្រីក្នុងធម្មជាតិថយចុះ ការរេចរិលនៃសម្បត្តិបរិស្ថាន និងតំបន់ទំនាបលិចទឹក ហើយការចាក់បង្ករកំណកល្បាប់ក្នុងដែនដីសណ្តទន្លេមេគង្គ ក៏ថយចុះផងដែរ។ ការប្រែប្រួលអាកាសធាតុ បានធ្វើឱ្យផលប៉ះពាល់ទាំងនេះកាន់តែធ្ងន់ធ្ងរ ដែលនាំមកនូវភាពមិនប្រាកដប្រជា និងហានិភ័យកាន់តែច្រើន ដែលរួមទាំង គ្រោះរាំងស្ងួត និងទឹកជំនន់កាន់តែញឹកញាប់ផងដែរ។

យុទ្ធសាស្ត្រ BDS អំពាវនាវឱ្យប្រទេសសមាជិកឈានហួសពីអភិក្រមគម្រោងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការរៀបចំផែនការ ទៅរកអភិក្រមមួយដែលផ្អែកលើបុរេសកម្មនៃកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីកំណត់សកម្មភាពថ្មីៗរួមគ្នា និងនៅថ្នាក់ជាតិ ដែលមានសារៈសំខាន់សម្រាប់អាងទន្លេទាំងមូល ដើម្បីកាត់បន្ថយភាពងាយរងគ្រោះទាំងកម្រិតអាងទន្លេ និងនៅថ្នាក់ជាតិ និងផ្តល់នូវការឆ្លើយតបបានទូលំទូលាយ ចំពោះការប្រែប្រួលអាកាសធាតុ និងបញ្ហាប្រឈមនានាដែលទាក់ទងនឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។

យុទ្ធសាស្ត្រ BDS ប្រកាន់យកចក្ខុវិស័យសម្រាប់ឆ្នាំ ២០៤០ នៃអាងទន្លេមេគង្គដែលមានវិបុលភាពសេដ្ឋកិច្ច សង្គមយុត្តិធម៌ បរិស្ថាន និងដែលធន់នឹងអាកាសធាតុ។ ការពាក់ព័ន្ធពិសេសចំពោះផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួតសម្រាប់អនុអាង 9C-9T គឺ ជាចក្ខុវិស័យសម្រាប់អាងដែលមានបរិស្ថានល្អ ដែលចែងថាៈ

*បរិស្ថានល្អៈ ទន្លេអាងនៅឆ្នាំ ២០៤០ គឺជាកន្លែងមួយដែលមនុស្សរស់នៅដោយសុខដុមរមនាជាមួយធម្មជាតិ ដែលសម្បត្តិបរិស្ថានដែលនៅសេសសល់ ជាពិសេស តំបន់ដីសើម និងព្រៃឈើធម្មជាតិសំខាន់ៗ ត្រូវបានការពារមិនឱ្យបាត់បង់បន្ថែមទៀត។ ធនធានធម្មជាតិត្រូវបានគ្រប់គ្រងដោយនិរន្តរភាពក្នុងព្រំដែនអេកូឡូស៊ី ដូច្នេះសេវាប្រព័ន្ធអេកូឡូស៊ី រួមទាំង សេវាការពារទល់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត ត្រូវបានរក្សា សម្រាប់ជាប្រយោជន៍ដល់សេដ្ឋកិច្ច និងប្រជាជននៃប្រទេសទាំងនេះ។ អាងនេះ នៅតែជាកន្លែងសំបូរជីវចម្រុះបំផុតមួយនៃពិភពលោក ដែលផ្តល់ទីជម្រកគ្រប់គ្រាន់ និងមុខងារនិយ័តកម្មដើម្បីបញ្ឈប់ការបាត់បង់ប្រភេទសត្វ។ ទីជម្រាល ដើរតួយ៉ាងសំខាន់ជាជម្រកសម្រាប់រុក្ខជាតិ និងសត្វ និយ័តកម្មលំហូរទឹក និងផ្តល់ទឹកក្រោមដី និងកាត់បន្ថយការហូរច្រោះដី។*

**លទ្ធផល BDS ដែលពាក់ព័ន្ធនៅឆ្នាំ ២០៣០** មានជាអាទិ៍៖ ១.១៖ លំហូរទឹកទន្លេគាំទ្រឱ្យបរិស្ថានមានសុខភាពល្អ និងសហគមន៍ដែលមានផលិតភាព ១.២៖ ការបញ្ជូនកំណកល្បាប់ជួយកាត់បន្ថយសំណឹកច្រាំងទន្លេនិងការបាក់ដី ១.៣៖ ទីជម្រកក្នុងទន្លេ និងតំបន់ដីសើម និងទីជម្រាល ផ្តល់សេវាប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ ៤.១៖ វត្តមានលំហូរគ្រប់គ្រាន់នៅ រដូវប្រាំង ដើម្បីទ្រទ្រង់សកម្មភាពចិញ្ចឹមជីវិត និងកាត់បន្ថយកម្ពស់ទឹកជំនន់អតិបរមានៅរដូវវស្សា និង ៤.២៖ សហគមន៍ក្នុងអាងទន្លេ ត្រៀមខ្លួនបានប្រសើរជាងមុននៅចំពោះមុខទឹកជំនន់ និងគ្រោះរាំងស្ងួតដែលកើតឡើងញឹកញាប់ និងធ្ងន់ធ្ងរ បណ្តាលពីការប្រែប្រួលអាកាសធាតុ។ សរុបមក អាទិភាពយុទ្ធសាស្ត្រ BDS និងលទ្ធផលសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងអាង ផ្តោតលើការរួមចំណែកក្នុងការសម្រេចបាន SDGs ដែលពាក់ព័ន្ធ។

ចក្ខុវិស័យ លទ្ធផល និងធាតុចេញនៃ BDS ផ្តល់ជាក្របខ័ណ្ឌគ្រឹះដ៏រឹងមាំមួយ សម្រាប់ផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួតសម្រាប់អនុអាង 9C-9T ដោយចងចាំថា BDS គឺជាយុទ្ធសាស្ត្រទូលំទូលាយមួយ ចំណែកផែនការមេ 9C-9T ផ្តោតលើទឹកជំនន់ និងការគ្រប់គ្រងគ្រោះរាំងស្ងួត។

យុទ្ធសាស្ត្រ BDS ត្រូវបានរៀបចំឡើងដោយកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ ដែលកម្ពុជា និងថៃ ជាភាគីសមាជិក ជាពិសេស SDGs និងអនុសញ្ញាទាំងបីនៃទីក្រុងរីយ៉ូ ជាមួយពិធីសារ និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធនានា។

### *៤.២.៣ អាទិភាពនៃយុទ្ធសាស្ត្រជាតិគ្រប់គ្រងធនធានទឹក*

កម្ពុជា និងថៃបានអនុម័តយុទ្ធសាស្ត្រជាតិ និងផែនការនានា ដើម្បីអនុវត្តកាតព្វកិច្ច និងការប្តេជ្ញារបស់ខ្លួនក្រោមកិច្ចព្រមព្រៀងអន្តរជាតិ រួមទាំង MRC BDS ដើម្បីកែលម្អការគ្រប់គ្រងទឹកជំនន់និងគ្រោះរាំងស្ងួតតាមរយៈវិធានការ IWRM។

**នៅកម្ពុជា** ក្រសួងធនធានទឹក និងឧតុនិយម មានច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក គោលនយោបាយ និងយុទ្ធសាស្ត្រជាតិគ្រប់គ្រងធនធានទឹក ផែនការមេសម្រាប់ការគ្រប់គ្រងធនធានទឹក និងគោលការណ៍ណែនាំ និងបទប្បញ្ញត្តិជាច្រើនសម្រាប់ការគ្រប់គ្រងធនធានទឹក ដែលបន្សុំនឹងការប្រែប្រួលអាកាសធាតុបានកាន់តែប្រសើរ។ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ទទួលស្គាល់តួនាទីដ៏សំខាន់របស់ស្ថាប័នផ្សេងទៀតនៃរដ្ឋាភិបាល ក្នុងការសម្រេចគោលបំណងរបស់ខ្លួន និងសារៈសំខាន់នៃកិច្ចសហការ និងការសម្របសម្រួលអន្តរវិស័យ។

តួនាទីស្នូលរបស់ក្រសួងបរិស្ថាន ក្នុងការស្តារ និងថែទាំទីជម្រាល តាមរយៈការអនុវត្តយុទ្ធសាស្ត្រ និងផែនការផ្សេងៗទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងគុណភាពទឹក ត្រូវបានលើកឡើងពីខាងដើម។

គួរបញ្ជាក់ផងដែរថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) គឺជាដៃគូដ៏សំខាន់មួយ ក្នុងការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត។ ឧទាហរណ៍ ការឆ្លើយតបបឋមរបស់រដ្ឋាភិបាល ចំពោះឱនភាពដីធ្លី ត្រូវបានបញ្ចូលក្នុងផែនការសកម្មភាពជាតិឆ្នាំ ២០១៧-២០២៦ ដើម្បីប្រយុទ្ធប្រឆាំងនឹងឱនភាពដីធ្លី។ ឱនភាពដីធ្លីកំពុងគំរាមកំហែងដោយផ្ទាល់ដល់សន្តិសុខស្បៀង និងទឹក ដោយសារវាប៉ះពាល់ដល់ផលិតភាពកសិកម្ម និងសមត្ថភាពរក្សាទឹកនៅក្នុងទីជម្រាល។ ឱនភាពដីធ្លីត្រូវបានផ្សារភ្ជាប់ជាមួយការរេចរិលព្រៃឈើ និងផលប៉ះពាល់នៃទឹកជំនន់ និងគ្រោះរាំងស្ងួតដែលកាន់តែធ្ងន់ធ្ងរដោយសារការប្រែប្រួលអាកាសធាតុ។ ផែនការសកម្មភាពនេះ លើកកម្ពស់ការអភិរក្សដីស្រែចម្ការ និងការអនុវត្តកសិកម្ម-រុក្ខកម្ម ការស្តារឡើងវិញនូវតំបន់ព្រៃសហគមន៍ និងការប្រើប្រាស់ដោយនិរន្តរភាព និងការគ្រប់គ្រង និងការតាមដានទីជម្រាល។ ស្ថាប័នដ៏សំខាន់គឺ នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម (DALRM) នៃក្រសួង MAFF។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុម័តយុទ្ធសាស្ត្រជាតិរេដបូកជាតិ(NRS) ២០១៧-២០២៦ ដើម្បីកាត់បន្ថយការបំភាយឧស្ម័នពីការកាប់បំផ្លាញព្រៃឈើ និងការរេចរិលព្រៃឈើ តាមរយៈការអភិរក្ស និងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងការលើកកំពស់ស្តុកកាបូនព្រៃឈើ - ដែលអនុវត្តតាមរយៈផែនការសកម្មភាព និងការវិនិយោគនៅក្រោម NRS (NRS-AIP)។ យុទ្ធសាស្ត្រ NRS កំណត់គោលដៅយុទ្ធសាស្ត្រចំនួនបី ដើម្បីដោះស្រាយកត្តាជម្រុញ និងមូលហេតុនៃការបាត់បង់ព្រៃឈើ និងការរេចរិលព្រៃឈើ៖ (i) ការកែលម្អប្រសិទ្ធភាពនៃការពិនិត្យតាមដានការប្រើប្រាស់ធនធានព្រៃឈើ និងការគ្រប់គ្រងដីធ្លី (ii) ការលើកកម្ពស់សកម្មភាពគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និង (iii) ការលើកកម្ពស់ការចូលរួមនៃភាគីពាក់ព័ន្ធ។ គោលបំណងទាំងនេះ គាំទ្រដល់វិធានការដោះស្រាយ កាត់បន្ថយ និងបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ជាពិសេស កាត់បន្ថយហានិភ័យពីទឹកជំនន់ និងគ្រោះរាំងស្ងួត។

**ប្រទេសថៃ** ក៏កំពុងអនុវត្តយុទ្ធសាស្ត្រ និងផែនការទូលំទូលាយជាច្រើន ដែលរួមចំណែកដោយផ្ទាល់ ដល់ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត តាមរយៈវិស័យនានានៃរដ្ឋាភិបាល។ ស្របតាមការប្តេជ្ញារបស់ខ្លួនក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និងអនុសញ្ញាស្តីពីជីវៈចម្រុះ (CBD) ការប្តេជ្ញាជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងការធ្វើឱ្យមានអព្យាក្រឹតនៃឱនភាពដីធ្លី ទាមទារឱ្យមានកិច្ចសហការលើសកម្មភាពនានាដោយស្ថាប័នជាច្រើន ដែលរួមមាន MONRE, ONWR, ONEP, នាយកដ្ឋានព្រៃឈើ នាយកដ្ឋានធារាសាស្ត្រ ក្រសួងកសិកម្ម និងសហករណ៍ នាយកដ្ឋានអភិវឌ្ឍន៍ដីធ្លី និងនាយកដ្ឋានឧទ្យានជាតិ សត្វព្រៃ និងអភិរក្សរុក្ខជាតិ ក្នុងចំណោមស្ថាប័នដទៃទៀត។ ការបង្កើតការិយាល័យធនធានទឹកជាតិ ដើម្បីដឹកនាំការសម្របសម្រួលវិស័យទឹក គូសបញ្ជាក់បន្ថែមអំពីការប្តេជ្ញាចិត្តចំពោះការចូលរួមនៃស្ថាប័នពីវិស័យនានា ដើម្បីភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។

ស្រដៀងគ្នានេះដែរ ផែនការមេរយៈពេល ២០ ឆ្នាំរបស់ថៃ ស្តីពីការគ្រប់គ្រងធនធានទឹក ២០១៨-២០៣៧ ទាមទារឱ្យមានការអនុវត្តពីសំណាក់ស្ថាប័នទាំងអស់នៃរដ្ឋាភិបាល។ ផែនការមេរបស់ថៃ កំណត់អាទិភាពជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងធនធានទឹកក្នុងវិស័យនានា ដែលប្រទេសទាំងពីរប្រកាន់យករួមគ្នាគឺ កម្ពុជាតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ និងភ្ជាប់ផែនការមេនៃវិស័យផ្សេងៗដូចជា ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន។ វិស័យអាទិភាពជាយុទ្ធសាស្ត្រជាតិរួមទាំងប្រាំមួយនេះ ត្រូវបានសង្ខេបដូចខាងក្រោម៖

**១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់៖** វិធានការផ្គត់ផ្គង់ និងប្រសិទ្ធភាពទឹកស្អាត គួរតែបានអនុវត្ត ដើម្បីធានាសន្តិសុខទឹកសម្រាប់សហគមន៍ទាំងអស់ប្រើប្រាស់។

**២. ការកសាងសន្តិសុខទឹកក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម រួមទាំង ប្រព័ន្ធស្រោចស្រព៖** បង្កើតប្រភពទឹក និងប្រព័ន្ធចែកចាយថ្មីៗ រួមជាមួយ វិធានការអភិរក្សទឹកដែលបង្កើនផលិតភាព ដែលសម្រេចបានតាមរយៈការកសាងផែនការរួម ដែលរួមទាំង ការគិតគូរជាពិសេសចំពោះទឹកជំនន់ និងគ្រោះរាំងស្ងួត។

**៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត៖** តាមរយៈការកែលំអទន្លេធម្មជាតិឡើងវិញ ការបំបាត់ឧបសគ្គនៅតាមផ្លូវទឹក ការរៀបចំផែនការគ្រប់គ្រងនៅតាមមូលដ្ឋាន ដើម្បីកាត់បន្ថយហានិភ័យ និងភាពធ្ងន់ធ្ងរនៃទឹកជំនន់ និងគ្រោះរាំងស្ងួត និងការប្រកាន់យកវិធានការឆ្លើយតបបន្ទាន់ និងការកែលម្អលើការចែកចាយព័ត៌មាន និងការប្រកាសផ្តល់ព័ត៌មាន។

៤. **ការគ្រប់គ្រងគុណភាពទឹក និងការអភិរក្សធនធានទឹក៖** កិច្ចការពារ និងអភិរក្សគុណភាពទឹក បរិមាណនិងអេកូឡូស៊ីក្នុងទន្លេ ប្រកបរបៀងដោះទឹក និងតំបន់ដីសើម ព្រមទាំង ប្រឡាយ និងអាងស្តុកទឹក - រួមផ្សំជាមួយ ការកាត់បន្ថយ និងការប្រើប្រាស់សំណល់រាវឡើងវិញ តាមរយៈ យន្តការប្រសិទ្ធភាព ការប្រមូលផ្តុំ និងប្រព្រឹត្តកម្មទឹក។

៥. **ការស្តារឡើងវិញនូវទីជម្រកក្នុងទឹក និងព្រៃឈើដែលខូចគុណភាពសម្រាប់និរន្តរភាពទឹក៖** ការថែរក្សា និងការស្តារឡើងវិញនូវទីជម្រាល និងព្រៃឈើដែលរេចរិល តាមរយៈ ការគ្រប់គ្រងលើការប្រើប្រាស់ដីឱ្យបានសមស្រប និងការអភិរក្សដោយរួមផ្សំជាមួយ គម្របរុក្ខជាតិជាយុទ្ធសាស្ត្រសម្រាប់កិច្ចការពារ ដើម្បីជៀសវាងការបាត់បង់ដីដោយសារសំណឹក។

៦. **ការកសាងប្រព័ន្ធគ្រប់គ្រង រដ្ឋបាល និងព័ត៌មានឱ្យមានប្រសិទ្ធភាព៖** ការគ្រប់គ្រងដីនិងទឹកចម្រុះ ដែលចាំបាច់ សម្រាប់ការគ្រប់គ្រងធនធានទឹកចម្រុះ ទាមទារឱ្យមានការសម្របសម្រួលរវាងវិស័យកាន់តែច្រើន ដើម្បីចែករំលែកព័ត៌មាន រៀបចំផែនការ ត្រួតពិនិត្យ និងវាយតម្លៃ នៅទូទាំងស្ថាប័នអនុវត្ត ជាពិសេសសម្រាប់ ទឹកជំនន់ និងគ្រោះរាំងស្ងួត។

អាទិភាពទាំងនោះឆ្លុះបញ្ចាំងអំពីការកែប្រែពីការផ្តោតតែលើការរៀបចំគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគទៅជាការកសាងផែនការបុរេសកម្មទូលំទូលាយនៅកម្រិតអាងទន្លេ ការស្តារឡើងវិញ និងការអនុវត្តអភិក្រម IWRM តាមរយៈសកម្មភាពអន្តរវិស័យសម្រាប់ដោះស្រាយបញ្ហាប្រឈមរួមនៃទឹកជំនន់ និងគ្រោះរាំងស្ងួត ដោយប្រទេសទាំងពីរ។ កិច្ចការនេះបានទទួលការគាំទ្រជាខ្លាំង នៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិដែលកម្ពុជា និងថៃជាភាគី រួមទាំង MRC BDS ផងដែរ។

គោលបំណង និងលទ្ធផលនៃផែនការមេនេះ រួមចំណែកដល់វិស័យអាទិភាពជាយុទ្ធសាស្ត្រជាតិរួមគ្នាទាំងប្រាំមួយដូចបានរៀបរាប់ក្នុងម៉ាទ្រីសនៅក្នុងឧបសម្ព័ន្ធ ១។ សេចក្តីលម្អិតបន្ថែមទៀតនៃសូចនាករនីមួយៗ នឹងមានផ្តល់ជាបន្ថែមនៅពេលចាប់ផ្តើមការអនុវត្តផែនការមេនេះ។

### *៤.២.៤ ការផ្តោតជាយុទ្ធសាស្ត្រក្នុងដំណាក់កាលទី៤នៃគម្រោងរួមក្នុង 9C-9T*

នេះក៏ជាការកែប្រែមួយដែលបានទទួលយកនៅក្នុងគម្រោងរួម 9C-9T ផងដែរ។ គម្រោងសហការនោះផ្ទាល់ បានបង្កើតទិសដៅយុទ្ធសាស្ត្រដែលផ្តល់នូវរចនាសម្ព័ន្ធគោលដៅដ៏ល្អសម្រាប់ផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួតអាង 9C-9T ដែលស្វែងរកការអនុវត្តកិច្ចព្រមព្រៀងសកល យុទ្ធសាស្ត្រBDSទន្លេមេគង្គ និងអាទិភាពជាតិ ដែលទាក់ទងនឹងការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតឱ្យមានប្រសិទ្ធភាព។ នៅក្នុងកិច្ចប្រជុំលើកទី ៣ របស់ខ្លួន ក្នុងខែឧសភា ឆ្នាំ ២០១៩ គណៈកម្មាធិការរួមតម្រង់ទិសថ្នាក់តំបន់នៃគម្រោង បានកំណត់វិស័យអាទិភាពចំនួន៥ សម្រាប់សកម្មភាពលើផ្នែកទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងអនុអាង 9C-9T ដូចជា៖

១. **ផែនការមេអាងទន្លេ៖** ផែនការមេអាងទន្លេសម្រាប់ 9C-9T ផ្តល់ឱកាសសម្រាប់ការកសាងផែនការចម្រុះ សម្រាប់ធនធានដី និងទឹក ដោយប្រទេសទាំងពីរ ឆ្ពោះទៅអាណត្តិរៀងៗខ្លួន សម្រាប់ការគ្រប់គ្រងធនធានទឹកចម្រុះ។ ផែនការមេអាងទន្លេ ស្វែងរកការកែលម្អស្ថានភាព និងមុខងារនៃអនុអាង ដោយគិតគូរអំពីធនធានទឹក និងសេវាសង្គម និងប្រព័ន្ធអេកូឡូស៊ីដែលពាក់ព័ន្ធ ដោយផ្តោតសំខាន់លើភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។ អាទិភាពនេះសន្មត់ថា គម្រោងរួមនេះនឹងឈានពីការរៀបចំផែនការមេអាងទន្លេ ទៅរកការអនុវត្តសកម្មភាពលើភូមិសាស្ត្រ ក្នុងដំណាក់កាលបន្តនៃគម្រោងនេះ។

២. **ការកសាងសមត្ថភាពក្នុងតំបន់៖** ការចែករំលែកចំណេះដឹងបង្កើតជាមូលដ្ឋានសម្រាប់ការវាយតម្លៃរួមគ្នា និងការអនុវត្តសកម្មភាពអាទិភាពនៅក្នុងអនុអាង 9C-9T រួម។ តាមរយៈអភិក្រមថ្នាក់តំបន់ ស្ថាប័ន និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាននៃប្រទេសទាំងពីរ អាចអនុវត្ត និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនបន្ថែមទៀត សម្រាប់ការរៀបចំផែនការចម្រុះ ការគ្រប់គ្រងធនធានទឹកឆ្លងដែន និងកិច្ចសហប្រតិបត្តិការទ្វេភាគី សម្រាប់ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។

៣. **ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងទីក្រុង៖** ការពិនិត្យឡើងវិញនូវកត្តាជំរុញនិងហានិភ័យនៃទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងទីក្រុង និងការរៀបចំយុទ្ធសាស្ត្រឆ្លើយតប ជាធាតុចូលដ៏មានតម្លៃសម្រាប់ការរៀបចំផែនការនៅតាមទីកន្លែង និងការកសាងប្រព័ន្ធការពារការអភិវឌ្ឍ។ ការរចនាទីក្រុងដែលងាយប្រឈមនឹងបញ្ហាទឹក និងធ្វើឱ្យទីក្រុងមានពណ៌បៃតង គឺជាឱកាសដែលផ្តល់ពហុអត្ថប្រយោជន៍ ដើម្បីបង្កើនភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងអនុអាង 9C-9T ។

៤. **កម្រងទិន្នន័យចំណេះដឹង និងព័ត៌មាន៖** កម្រងទិន្នន័យរួមមួយ ដើម្បីសម្រួលដល់ការផ្លាស់ប្តូរចំណេះដឹង និងព័ត៌មានដែលទាក់ទងនឹងទឹកជំនន់ គ្រោះរាំងស្ងួត និងធនធានទឹកនៅក្នុងអនុអាង 9C-9T។

៥. **ការកែលម្អទិន្នន័យជលសាស្ត្រ-ឧតុនិយម និងគ្រោះទឹកជំនន់៖** ការពង្រីកបណ្តាញស្ថានីយ៍ជលសាស្ត្រ-ឧតុនិយមក្នុងអនុអាង 9C-9T នឹងបង្កើតទិន្នន័យថ្មីៗ សម្រាប់បង្កើនការយល់ដឹង និងការគ្រប់គ្រងធនធានទឹក ដែលរួមទាំង ការកែលម្អម៉ូដែលជលសាស្ត្រដែលបានបង្កើតឡើងសម្រាប់អនុអាងនេះ។ កិច្ចការនេះក៏ផ្តល់នូវមធ្យោបាយមួយដើម្បីពង្រឹងការប្រកាសផ្តល់ព័ត៌មានអំពីទឹកជំនន់និងគ្រោះរាំងស្ងួតផងដែរ។ ឱកាសផ្សេងទៀត ដូចជា ការកំណត់តំបន់ជន់លិច ការបណ្តុះបណ្តាលអំពីការត្រៀមបង្ការនិងការឆ្លើយតបនឹងគ្រោះមហន្តរាយ និងការធ្វើឱ្យប្រសើរឡើងនូវការចែកចាយ និងការប្រាស្រ័យទាក់ទងសម្រាប់ការប្រកាសផ្តល់ព័ត៌មាន គួរតែបានអនុវត្តស្របគ្នានេះផងដែរ។

អាទិភាពទាំងប្រាំសម្រាប់សកម្មភាពទឹកជំនន់ និងគ្រោះរាំងស្ងួត គាំទ្រដល់ការអនុវត្តអាទិភាពជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងធនធានទឹក ដែលធ្វើឡើងរួមគ្នាដោយប្រទេសកម្ពុជា និងប្រទេសថៃ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួត 9C-9T ត្រូវបានរៀបចំឡើងជុំវិញវិស័យអាទិភាពចំនួនប្រាំសម្រាប់សកម្មភាពក្នុងផ្នែកទឹកជំនន់ និងគ្រោះរាំងស្ងួតដែលត្រូវបានកំណត់ និងឯកភាពក្នុងដំណាក់កាលទី I នៃគម្រោងរួម។

## ៤.៣ ចក្ខុវិស័យ និងសេចក្តីថ្លែងការណ៍បេសកកម្ម

ចក្ខុវិស័យសម្រាប់ផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួត 9C-9T គឺការកែលំអ និងស្តារឡើងវិញនូវអាងទន្លេ ដែលបានរេចរិលធ្ងន់ធ្ងរ ដោយសារការបាត់បង់គម្របព្រៃឈើយ៉ាងច្រើន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធខ្នាតធំនិងតូច ដែលបានគ្រោងទុក និងដែលបានអនុវត្ត សម្រាប់គោលដៅតាមវិស័យតែមួយ ដោយពុំមានការវាយតម្លៃបានគ្រប់គ្រាន់នៅកម្រិតទីជម្រាល និងការវាយតម្លៃផលប៉ះពាល់បណ្តុំ។ ឥទ្ធិពលបច្ចុប្បន្នបណ្តាលពីការប្រែប្រួលអាកាសធាតុ កំពុងដាក់បន្ទុកបន្ថែម និងធ្វើឱ្យហានិភ័យ និងផលប៉ះពាល់នៃទឹកជំនន់ និងគ្រោះរាំងស្ងួតកាន់តែធ្ងន់ធ្ងរ។ ដំណើរការកែលំអ តម្រូវឱ្យមានការបង្វែរទិសដៅជាច្រើន និងធ្វើឱ្យមានតុល្យភាពនៃការវិនិយោគ ឆ្ពោះទៅរកដំណោះស្រាយផ្អែកលើធម្មជាតិ ដែលពាក់ព័ន្ធនឹងកិច្ចការពារ ការស្តារ និងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីដោយនិរន្តរភាព តាមវិធីដែលបង្កើនភាពធន់ និងសមត្ថភាពនៃដំណើរការនេះ ក្នុងការដោះស្រាយបញ្ហាប្រឈមនៃទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងអាងទន្លេ ទន្ទឹមនឹងការពារជីវចម្រុះ និងការកែលម្អសុខុមាលភាពរបស់មនុស្ស។ ចក្ខុវិស័យ និងការឆ្លើយតបនេះ ដែលចែងក្នុងផែនការមេនេះ គឺបានបរិយាយពិស្តារដូចខាងក្រោម៖

**ចក្ខុវិស័យអាង៖** ផែនការមេសម្រាប់ការប្រយុទ្ធប្រឆាំងនឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងអនុអាង 9C-9Tនេះគឺត្រូវ បានគាំទ្រដោយចក្ខុវិស័យដូចខាងក្រោម៖

*អនុអាង 9C-9T គឺជាប្រព័ន្ធដែលមានសុខភាពល្អ ស្អាត និងផលិតភាពខ្ពស់ ដែលទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ីកាត់បន្ថយហា-និភ័យនៃទឹកជំនន់ និងគ្រោះរាំងស្ងួត និងផ្តល់សេវាកម្មដ៏មានតម្លៃសម្រាប់ទាំងអស់គ្នាទាំងនាពេលបច្ចុប្បន្ន និងពេលអនាគត។*

**សេចក្តីថ្លែងការណ៍បេសកកម្ម៖** ដើម្បីសម្រេចបានចក្ខុវិស័យអាងនេះ សេចក្តីថ្លែងការណ៍បេសកកម្មសម្រាប់ឆ្លើយតបទៅនឹងផែនការមេនេះគឺ ការចាត់វិធានការ ដោយផ្អែកលើផែនការមួយច្បាស់លាស់ និងគុណតម្លៃនៃការគ្រប់គ្រងអាងទន្លេ ដូចខាងក្រោម៖

- បង្ហាញពីអត្ថប្រយោជន៍នៃកិច្ចសហប្រតិបត្តិការឆ្លងដែន ក្នុងការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលរួមទាំងការចែករំលែកព័ត៌មាន និងការប្រកាសផ្តល់ព័ត៌មានជាមុន ដើម្បីគាំទ្រសុខុមាលភាព និងជីវភាពរស់នៅដែលងាយប្រឈមនឹងបញ្ហាទឹក។
- ធានាថា រាល់សកម្មភាពយុទ្ធសាស្ត្រពិតជាត្រឹមត្រូវ និងសមធម៌ ដោយផ្តោតលើវិធានការគ្រប់គ្រងហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលផ្តោតលើតំបន់ និងសហគមន៍នានាដែលមានតម្រូវការខ្លាំងបំផុត។
- ទទួលស្គាល់ទំនាក់ទំនងអន្តរកម្មនៃប្រព័ន្ធទន្លេ ជាពិសេស ចំណងទាក់ទងរវាងតំបន់ខ្សែទឹកខាងលើ-ខាងក្រោម។
- ស្វែងរកនិរន្តរភាពអេកូឡូស៊ី និងការថែរក្សាសេវាប្រព័ន្ធអេកូឡូស៊ី តាមរយៈ ការស្តារ និងថែទាំនៅទូទាំងអាងទន្លេ។
- អនុវត្តជម្រើសអភិវឌ្ឍន៍ចម្រុះបៃតង-ប្រផេះ និងដំណោះស្រាយផ្អែកលើធម្មជាតិសុទ្ធសាធ នៅក្នុងការស្តារ និងថែទាំទីជម្រាល និងដើម្បីបង្កើនសុខភាពនៃហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និងដែលបានគ្រោងទុក។
- លើកកម្ពស់សមភាពយេនឌ័រ និងបរិយាបន្នសង្គម។
- កសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុដោយបញ្ជ្រាបការបន្សាំ។

## ៤.៤ អាទិភាពយុទ្ធសាស្ត្រ និងលទ្ធផលសម្រាប់ទឹកជំនន់ និងគ្រោះរាំងស្ងួត

ផែនការមេនេះ ត្រូវបានរៀបចំឡើងឱ្យស្របជាមួយទម្រង់នៃយុទ្ធសាស្ត្រ BDS អាងទន្លេមេគង្គ ដែលកំណត់ចក្ខុវិស័យអាង អាទិភាពយុទ្ធសាស្ត្រ លទ្ធផលសម្រាប់អាទិភាពនីមួយៗ និងជាតុចេញ ដើម្បីសម្រេចបាននូវលទ្ធផលក្នុងរយៈពេល ១៥ ឆ្នាំ។ អាទិភាពជាយុទ្ធសាស្ត្រត្រូវបានបង្កើតឡើង ដោយផ្អែកលើការអនុម័តដោយគណៈកម្មាធិការតម្រង់ទិសថ្នាក់តំបន់ នៃគម្រោងរួមនេះ ក្នុងជំណាក់កាលទី I ដូចខាងក្រោម៖

១. អនុវត្តផែនការមេអាងទន្លេ

២. គ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅទីក្រុង និងជនបទ

៣. ផ្លោះប្តូរព័ត៌មាន និងចំណេះដឹង

៤. ពង្រឹងបណ្តាញស្ថានីយ៍ជលសាស្ត្រ-ឧតុនិយម និងការប្រកាសផ្តល់ព័ត៌មានអំពីទឹកជំនន់ និងគ្រោះរាំងស្ងួត

៥. កសាងសមត្ថភាពក្នុងតំបន់។

អាទិភាពយុទ្ធសាស្ត្រទី ៣ និងទី ៤ មានលក្ខណៈអន្តរវិស័យ ដែលគាំទ្រដល់អាទិភាពទី ១ និងទី ២ ដែលផ្តោតលើការអនុវត្តអន្តរាគមន៍ផ្នែកទឹកជំនន់និងគ្រោះរាំងស្ងួតនៅទូទាំងតំបន់ទីក្រុងនិងជនបទ និងតំបន់ព្រៃឈើ នៅក្នុងភូមិសាស្ត្រនៃតំបន់ក្បាលទឹកនៃទីជម្រាល។ អាទិភាពទី៥ ផ្តោតលើការកសាងសមត្ថភាព នៅទូទាំងវិស័យអាទិភាពទាំង៤។

សម្រាប់អាទិភាពនីមួយៗ មានចែងអំពីលទ្ធផលគ្រោងទុក ដើម្បីបង្កើតក្របខ័ណ្ឌផែនការមេ (រូបភាពទី ៨)។ បន្ទាប់មកលទ្ធផលនីមួយៗ ត្រូវបានចែងលម្អិត ដល់កម្រិតជាតុចេញ សម្រាប់ផែនការសកម្មភាពរយៈពេល ១៥ ឆ្នាំ ដូចដែលមានចែងពិស្តារក្នុងជំពូក ៤.៦ ជាមួយកាលវិភាគ និងសន្ទស្សន៍ថវិកាជាតិ និងអន្តរជាតិ ដែលបានផ្តល់ឱ្យសម្រាប់រយៈពេល ៥ ឆ្នាំដំបូង ២០២២-២០២៦។ កម្រិតនៃការសម្របសម្រួលដែលត្រូវអនុវត្តសម្រាប់ជាតុចេញនីមួយៗក៏មានបង្ហាញផងដែរ។

*រូបភាពទី ៨. រចនាសម្ព័ន្ធនៃផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួតសម្រាប់អនុអាង 9C-9T នៅកម្រិតលទ្ធផល*

## ចក្ខុវិស័យអាង 9C-9T សម្រាប់ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត

*អនុអាង 9C-9T គឺជាប្រព័ន្ធដែលមានសុខភាពល្អ ស្អាត និងផលិតភាពខ្ពស់ ដែលទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី កាត់បន្ថយហានិភ័យនៃទឹកជំនន់ និងគ្រោះរាំងស្ងួត និងផ្តល់សេវាកម្មដ៏មានតម្លៃសម្រាប់ទាំងអស់គ្នា ទាំងនាពេលបច្ចុប្បន្ននិងទៅអនាគត។*

## អាទិភាពយុទ្ធសាស្ត្រនៃអាង 9C-9T

| ១ពិនិត្យ កែសម្រួល និងអនុ . វត្តផែនការមេអាង 9C-9T | ២គ្រប់គ្រងទឹកជំនន់ និងគ្រោះរាំង . ស្ងួតនៅទីក្រុង និងជនបទ ដើម្បីកាត់ | ៣ផ្លោះប្តូរព័ត៌មាន និងចំណេះ . ដឹង | ៤ពង្រឹងបណ្តាញជលសាស្ត្រ .-ឧតុនិយម និងការប្រកាសផ្តល់ព័ត៌មានជាមុនអំពីទឹកជំនន់និងគ្រោះរាំងស្ងួត | ៥. កសាងសមត្ថភាពក្នុងតំបន់ |
|---|---|---|---|---|
| **លទ្ធផលនៃអាង 9C-9T** | | | | |
| លទ្ធផល១.១ ៖បានបន្សុីក្របខណ្ឌច្បាប់ និងការអនុវត្តសម្រាប់គ្រប់គ្រងធនធានទឹកឆ្លងដែន ដើម្បីគាំទ្រភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត | លទ្ធផល ២.១៖បានពង្រឹងភាពធន់នឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងទីក្រុង តាមរយៈឧបករណ៍ផែនការនវានុវត្តន៍ ដែលគិតគូរពីអាកាសធាតុ និងអន្តរាគមន៍បន្សាំ | លទ្ធផល ៣.១៖ ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត នឹងបញ្ហាអាកាសធាតុ IWRM ដែលងាយប្រឈម តាមរយៈការចែករំលែកចំណេះដឹង | លទ្ធផល ៤.១៖ បានពង្រឹងពិធីសារត្រួតពិនិត្យរួមគ្នានិងការប្រកាសផ្តល់ព័ត៌មានជាមុនអំពីជលសាស្ត្រ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ និងគ្រោះរាំងស្ងួត | លទ្ធផល ៥.១៖បានពង្រឹងសមត្ថភាពសម្រាប់ការស្តារ និងថែទាំអាងតាមរយៈវិធានការណ៍ផ្អែកលើធម្មជាតិ និងចម្រុះ |
| លទ្ធផល ១.២ ៖ បានពង្រឹងយន្តការដើម្បីកែលម្អផែនការIWRM និងការគ្រប់គ្រងចម្រុះអាងទន្លេ សម្រាប់ទឹកជំនន់ និងគ្រោះរាំងស្ងួត | លទ្ធផល ២.២៖បានពង្រឹងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅតាមជនបទ តាមរយៈឧបករណ៍កសាងផែនការផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងអន្តរាគមន៍បន្សាំ | លទ្ធផល ៣.២៖ ពង្រឹងការអនុវត្តល្អ និងចែករំលែកមេរៀនដែលបានពីគម្រោងរួម9C-9T ក្នុងអាងទន្លេមេគង្គក្រោម | | លទ្ធផល ៥.២៖ បានពង្រឹងសមត្ថភាពសម្រាប់ការរៀបចំផែនការអាងទន្លេ និងការគ្រប់គ្រងអាងទន្លេឆ្លងដែន |
| លទ្ធផល ១.៣៖និរន្តភាពហិរញ្ញប្បទាន សម្រាប់វិធានការបន្សាំតាមប្រព័ន្ធអេកូឡូស៊ី សម្រាប់ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត | លទ្ធផល ២.៣៖ បានស្តារអាងទន្លេនៅតំបន់ក្បាលទឹក និងតំបន់ដីសើមឡើងវិញ ដើម្បីកែលម្អសន្តិសុខទឹកនិងភាពធន់នឹងអាកាសធាតុ តាមរយៈអន្តរាគមន៍បន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី | | | លទ្ធផល៥.៣៖ បានពង្រឹងសមត្ថភាពក្នុងធ្វើម៉ូដែលទឹកជំនន់ និងគ្រោះរាំងស្ងួត ការបកស្រាយ និងការប្រាស្រ័យទាក់ទងលទ្ធផល |

## ៤.៥ សេចក្តីអធិប្បាយអំពីអាទិភាពយុទ្ធសាស្ត្រនិងលទ្ធផលនៃផែនការមេ 9C-9T

### *៤.៥.១ អាទិភាពយុទ្ធសាស្ត្រ ១៖ ពិនិត្យ ធ្វើបច្ចុប្បន្នភាព និងអនុវត្តផែនការមេអាងទន្លេ* 9C-9T

- **លទ្ធផល ១.១៖ បានបន្ស៊ីក្របខ័ណ្ឌច្បាប់ និងការអនុវត្តសម្រាប់គ្រប់គ្រងធនធានទឹកឆ្លងដែន ដើម្បីគាំទ្រភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត**
- **លទ្ធផល ១.២ ៖ របានពង្រឹងយន្តការដើម្បីកែលម្អផែនកា IWRM និងការគ្រប់គ្រងចម្រុះអាងទន្លេ សម្រាប់ទឹកជំនន់ និងគ្រោះរាំងស្ងួត**
- **លទ្ធផល ១.៣ ៖ ការផ្តល់ហិរញ្ញប្បទានដោយនិរន្តរភាពសម្រាប់វិធានការបន្សាំតាមប្រព័ន្ធអេកូឡូស៊ី សម្រាប់ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត**

អាទិភាពយុទ្ធសាស្ត្រ ១ និងលទ្ធផលក្រោមអាទិភាពនេះ សង្កត់ធ្ងន់លើផ្នែកសកម្មភាព ដើម្បីបង្កើត និងអនុវត្តប្រព័ន្ធដែលមានសង្គតិភាពសម្រាប់ការរៀបចំផែនការអាងទន្លេក្នុងប្រទេសកម្ពុជា និងប្រទេសថៃ។ គោលដៅគឺ ធ្វើឱ្យផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួត វិវត្តទៅជាផែនការអាងទន្លេទូលំទូលាយមួយ សម្រាប់អនុអាង 9C-9T ក្នុងអំឡុងពេលប្រាំឆ្នាំដំបូងនៃការអនុវត្ត។ ក្នុងដំណាក់កាលនេះ ប្រទេសទាំងពីរពុំបានកសាងផែនការអាងទន្លេជាលក្ខណៈអន្តរវិស័យ និងចម្រុះឡើយ។ ការនាំយកវិស័យទាំងអស់មកធ្វើការជាមួយគ្នា ដើម្បីគាំទ្រ និងបន្ទាប់មក ទទួលយកអភិក្រមអាងទន្លេទាំងមូលសម្រាប់ការកសាងផែនការ និងការវិនិយោគ បានបង្ហាញអោយឃើញថា ជាការលំបាក ជាពិសេសនៅក្នុងយុទ្ធសាស្ត្រដែលស្តារឡើងវិញ និងថែរក្សាប្រព័ន្ធធម្មជាតិជាអាទិភាពនៅក្នុងការគ្រប់គ្រងធនធានទឹក។ ការកសាងផែនការ ការអភិវឌ្ឍ និងថវិកាភាគច្រើនបានអនុវត្តទៅតាមវិស័យដាច់ដោយឡែកពីគ្នា។

ដើម្បីរៀបចំ និងអនុវត្តផែនការមេអាងទន្លេអន្តរជាតិប្រកបដោយជោគជ័យ ជាមួយការប្តេជ្ញាចិត្តពីគ្រប់វិស័យពាក់ព័ន្ធទាំងសងខាងនៃព្រំដែន ទាមទារឱ្យមានក្របខ័ណ្ឌច្បាប់ និងការអនុវត្តដែលបានបន្ស៊ីគ្នា សម្រាប់ការគ្រប់គ្រងធនធានទឹកឆ្លងដែន ការពង្រឹងយន្តការដើម្បីកែលម្អការអនុវត្ត IWRM និងអភិក្រមចម្រុះនៅទូទាំងអាងទន្លេ និងយន្តការហិរញ្ញប្បទានដែលមាននិរន្តរភាព ដែលចាត់ទុកវិធានការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ីជាអាទិភាព។

អាទិភាពយុទ្ធសាស្ត្រ ១ និងលទ្ធផលក្រោមអាទិភាពនេះ នឹងពង្រីកការអនុវត្តល្អជាអន្តរជាតិក្នុងការរៀបចំផែនការសកម្មភាព និងការវិនិយោគរួមគ្នាលើអនុអាងនេះ។ ការបន្ស៊ីគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ រួមបញ្ចូលការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនៅក្នុងអនុអាង និងការពង្រឹងយន្តការស្ថាប័នសម្រាប់ IWRM ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការកសាងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។ សម្រាប់វិស័យទឹក ប្រទេសទាំងពីរមានផែនការមេអភិវឌ្ឍន៍ដែលបន្តសង្កត់ធ្ងន់លើអភិក្រមតាមវិស័យដាច់ពីគ្នា សម្រាប់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធរឹង ជាពិសេសសម្រាប់ការបង្កើនវិសាលភាពតំបន់ស្រោចស្រពឬហេដ្ឋារចនាសម្ព័ន្ធដោះទឹក ដោយពុំមានការវាយតម្លៃឬកិច្ចការពារបរិស្ថានគ្រប់គ្រាន់ឡើយ។ គណៈកម្មាធិការអាងទន្លេដែលបានបង្កើតឡើង នៅខ្វះសមាជិកភាពពីវិស័យនានា ដែលចាំបាច់ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងធនធានទឹកចម្រុះ។ ជាលទ្ធផល ផែនការអាងទន្លេមិនទំនងជាទទួលបានការគាំទ្រពីអន្តរស្ថាប័នឬអន្តរវិស័យដែលចាំបាច់ដើម្បីឱ្យការគ្រប់គ្រងចម្រុះទទួលជោគជ័យ។ ទោះបីមានការបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការកសាងផែនការនៃគម្រោងចំពោះដៃគូអភិវឌ្ឍន៍ជាច្រើនក៏ដោយ ប្រទេសទាំងពីរនៅត្រូវសង្កត់ធ្ងន់បន្ថែមទៀតលើការអភិវឌ្ឍស្ថា- ប័ន និងការកសាងផែនការតាមវិស័យ និងនៅកម្រិតអាងទន្លេផងដែរ។

ការកសាងផែនការចម្រុះ និងការវាយតម្លៃផលប៉ះពាល់ឆ្លងដែននៃការអភិវឌ្ឍដែលនៅមានកម្រិតកំណត់ មិនប្រាកដជាអាចផ្តល់អត្ថប្រយោជន៍សម្រាប់ប្រទេសទាំងពីរឡើយ ទាំងសម្រាប់តំបន់ខ្សែទឹកខាងលើ និងខាងក្រោម។ កង្វះការបន្សីគោលនយោបាយ និងដំណើរការរៀបចំផែនការអាងទន្លេនៅក្នុងប្រទេសទាំងពីរ មានន័យថា ឱកាសដើម្បីសហការ និងពិគ្រោះយោបល់ ពុំមានភាពច្បាស់លាស់ឡើយ នៅក្នុងការអនុវត្តជាក់ស្តែង។ ជាលទ្ធផល ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត មិនបានបញ្ជ្រាបនៅក្នុងការប្រើប្រាស់ដី និងការរៀបចំផែនការអភិវឌ្ឍន៍ឡើយ ដែលរួមទាំងក្នុងតំបន់ទីក្រុង។

ប្រទេសទាំងពីរកំពុងធ្វើការដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះនៅក្នុងដំណាក់កាលបច្ចុប្បន្ននៃកិច្ចសហប្រតិបត្តិដែលគាំទ្រដោយ MRC-GIZ តាមរយៈការរៀបចំផែនការមេអាងទន្លេឆ្លងដែនសម្រាប់ទឹកជំនន់ និងគ្រោះរាំងស្ងួត។ ផែនការមេនេះផ្តួចផ្តើមឱ្យមានដំណើរការ ដែលប្រទេសទាំងពីរអាចអនុម័ត និងអនុវត្ត ដើម្បីធានាឱ្យមានការត្រួតពិនិត្យ និងការធ្វើបច្ចុប្បន្នភាពជាប្រចាំ លើសកម្មភាពយុទ្ធសាស្ត្រ និងអាទិភាពចំនួនប្រាំដែលបានព្រមព្រៀងគ្នា។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការទ្វេភាគីបែបនេះ ទាមទារឱ្យមានការជម្រុញបន្ថែមទៀត ដើម្បីបង្កើត និងបញ្ចូលពិធីសាររួម ផែនការសកម្មភាព និងសមត្ថភាព សម្រាប់វដ្តនៃការរៀបចំផែនការជាតិ និងថវិកានៃប្រទេសទាំងពីរ។

អាទិភាពយុទ្ធសាស្ត្រ ១ នៃផែនការមេនេះ តម្រូវឱ្យអនុវត្ត និងកែសម្រួលជាប្រចាំ នូវចក្ខុវិស័យជាយុទ្ធសាស្ត្រនៃអនុអាង 9C-9T ឆ្លងដែន និងផែនការសកម្មភាពរួម ឱ្យស្របតាមវដ្តផែនការអភិវឌ្ឍន៍ជាតិរយៈពេលប្រាំឆ្នាំ។ ដើម្បីសម្រួលដល់ការអនុវត្តផែនការ ចាំបាច់ត្រូវបង្កើតគណៈកម្មាធិការអាងទន្លេសម្រាប់តំបន់ 9C ដែលរួមទាំងសម្រាប់ ស្ទឹងមង្គលបូរី និងស្ទឹងសេរីសោភ័ណ ដោយត្រូវមានសមាជិកភាពអន្តរវិស័យស្រដៀងនឹងគណៈកម្មាធិការ"ទន្លេសាប"នៃប្រទេសថៃផងដែរ។ ចាំបាច់ត្រូវមានការពង្រឹងស្ថាប័នបន្ថែមទៀត ដើម្បីធានាថា គណៈកម្មាធិការអាងទាំងពីរអាចធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា និងជាមួយក្រុមការងារថ្នាក់ជាតិ និងគណៈកម្មាធិការតម្រង់ទិសថ្នាក់តំបន់ ដើម្បីអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្ររួមគ្នានៅកម្រិតអាងទន្លេ។

ការធ្វើសុខដុមនីយកម្មគោលនយោបាយ គឺជាលក្ខខណ្ឌចាំបាច់ ដើម្បីអាចបញ្ចូលដោយនិរន្តរភាពនូវអាទិភាពនៃផែនការសកម្មភាពយុទ្ធសាស្ត្រអនុអាង 9C-9T ទៅក្នុងវដ្តនៃដំណើរការកសាងផែនការ និងថវិកានៃប្រទេសទាំងពីរ ដោយមានការប្តេជ្ញាចិត្តរួមគ្នាចំពោះ SEA ដើម្បីណែនាំគោលនយោបាយ និងផែនការឱ្យមាននិរន្តរភាព។ ត្រូវមានការពិនិត្យ និងកែសម្រួលឡើងវិញនូវផែនការមេរបស់ថៃនាពេលបច្ចុប្បន្ននេះសម្រាប់អាងទន្លេសាប ធៀបនឹងអាទិភាព និងគោលបំណងនៃផែនការសកម្មភាពយុទ្ធសាស្ត្រអនុអាង 9C-9T។ ការបញ្ជ្រាបសកម្មភាពយុទ្ធសាស្ត្ររួមដែលបានព្រមព្រៀងគ្នា ក៏ដូចជាការគិតគូរអំពីយេនឌ័រនៅក្នុងសកម្មភាព និងផែនការគ្រប់គ្រងតាមវិស័យ និងក្នុងមូលដ្ឋាន គឺជាតម្រូវការចាំបាច់ ទន្ទឹមនឹងភាពចាំបាច់ក្នុងការវាយតម្លៃសេដ្ឋកិច្ចដើម្បីគាំទ្រដល់ដំណើរការនេះ និងដើម្បីទទួលបានការគាំទ្រទូលំទូលាយ។ គួរប្រើប្រាស់ឱកាសសម្រាប់ការវិនិយោគរបស់វិស័យឯកជនលើសកម្មភាពយុទ្ធសាស្ត្ររួមគ្នាសម្រាប់ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត ជាពិសេស នៅតំបន់ទីក្រុង ដើម្បីធានាថា អាទិភាពដូចមាននៅលើក្រដាស ទទួលបានធនធានពេញលេញ និងអាចបន្តចាត់ជាអាទិភាពនៅក្នុងការអនុវត្ត។

### *៤.៥.២ អាទិភាពយុទ្ធសាស្ត្រ ២. គ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅទីក្រុង និងជនបទ ដើម្បីកាត់បន្ថយហានិភ័យ*

- លទ្ធផល ២.១ ៖បានពង្រឹងភាពធន់នឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងទីក្រុង តាមរយៈឧបករណ៍ផែនការនៅវានុវត្តន៍ដែលគិតគូរពីអាកាសធាតុ និងផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងអន្តរាគមន៍បន្សាំ

- លទ្ធផល ២.២ ៖.បានពង្រឹងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅតាមជនបទ តាមរយៈឧបករណ៍កសាងផែនការផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងអន្តរាគមន៍បន្សាំ
- លទ្ធផល ២.៣៖ បានស្តារអាងទន្លេនៅតំបន់ក្បាលទឹក និងតំបន់ដីសើមឡើងវិញ ដើម្បីកែលម្អសន្តិសុខទឹកនិងភាពធន់នឹងអាកាសធាតុ តាមរយៈអន្តរាគមន៍បន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី

អាទិភាពយុទ្ធសាស្ត្រ ២ និងលទ្ធផលក្រោមអាទិភាពនេះ សង្កត់ធ្ងន់លើអាទិភាពជាតិសម្រាប់ការស្តារឡើងវិញនូវទីជម្រាល និងអាទិភាពរួមនៃការកសាងទីក្រុង និងជនបទ និងភាពធន់នឹងគ្រោះរាំងស្ងួត។ ចំណុចនេះពាក់ព័ន្ធនឹងការអភិវឌ្ឍ និងការអនុវត្តផែនការកំណត់តំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងទឹកជំនន់តាមមូលដ្ឋាន និងកិច្ចការពារនៅមូលដ្ឋាន បន្តដោយការរចនាប្លង់ និងការអនុវត្តវិធានការណ៍ដែលផ្អែកលើធម្មជាតិ និងចម្រុះ នៅទូទាំងអនុអាង ដែលរួមទាំងតំបន់ព្រៃក្បាលទឹក តំបន់ទេសភាពជនបទ តំបន់ជុំវិញនិងកណ្តាលទីក្រុង។ បណ្តាញនៃការវិនិយោគនេះនឹងរួមចំណែកចំពោះភាពធន់នៃទីជម្រាល និងសហគមន៍ ចំពោះមុខទឹកជំនន់ គ្រោះរាំងស្ងួត និងការប្រែប្រួលអាកាសធាតុ ទន្ទឹមនឹងផ្តល់នូវការអនុវត្តបង្ហាញ និងមេរៀនសម្រាប់ការចម្លង និងការបង្កើនការអនុវត្ត។

ការវិនិយោគនាពេលបច្ចុប្បន្នសម្រាប់ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងអនុអាង 9C-9T បានផ្តោតជាខ្លាំងលើហេដ្ឋារចនាសម្ព័ន្ធរឹង និងខ្វះការពិចារណាអន្តរវិស័យ និងការវាយតម្លៃផលប៉ះពាល់បណ្តុំ។ ការគិតគូរក្នុងកម្រិតកំណត់អំពីផលប៉ះពាល់ឆ្លងដែន ក៏នាំមកនូវកង្វល់ដែលទាក់ទងនឹងការកែលម្អនៅតំបន់ខ្សែទឹកខាងលើក្នុងការដោះទឹកដែលអាចបង្កើនល្បឿននៃលំហូរដល់កម្រិតកំពូលមកតំបន់ខ្សែទឹកខាងក្រោម។ ខណៈពេលដែលកិច្ចខិតខំប្រឹងប្រែងជាច្រើនកំពុងត្រូវបានអនុវត្តក្នុងការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍទេសចរណ៍ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ មានភស្តុតាងត្រឹមតិចតួចប៉ុណ្ណោះនៃការពិចារណាអំពីទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងកម្មវិធី និងគម្រោងទាំងនោះ។ ការវិនិយោគនៅលើភូមិសាស្ត្រជាក់ស្តែងមានតិចតួចជាខ្លាំង ក្នុងការស្តារឡើងវិញនូវទីជម្រាល និងតំបន់ការពារធម្មជាតិនៅក្នុងអនុអាង 9C-9T ឬតំបន់ជិតខាង។ ជាលទ្ធផល គេនៅតែបាត់បង់ឱកាសដើម្បីទទួលបានពហុប្រយោជន៍សម្រាប់ជីវភាពរស់នៅទីក្រុងដែលផ្តល់ភាពងាយស្រួលរស់នៅ សហគមន៍ងាយរងគ្រោះ សមភាពយេនឌ័រ ជីវចម្រុះ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ តាមរយៈវិធានការបន្សាំតាមធម្មជាតិ។

ទន្ទឹមនឹងនេះ ការវិនិយោគដែលកំពុងបន្តនៅក្នុងអាងស្តុកទឹក និងហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ទទួលរងនូវផលប៉ះពាល់ពីការរេចរិលនៃទីជម្រាល សំណឹក កំណកល្បាប់ និងការខូចខាតដោយទឹកជំនន់។ ការវិនិយោគនៅក្នុងបឹងទន្លេសាបដែលស្ថិតនៅខ្សែទឹកខាងក្រោមនៃអនុអាង 9C-9T ក៏រងការគំរាមកំហែងផងដែរដោយសារការរេចរឹលនៃតំបន់ទេសភាព និងធនធានទឹកនៃអនុអាង 9C-9T និងទឹកជំនន់ និងគ្រោះរាំងស្ងួតដែលពាក់ព័ន្ធផងដែរ។

ខណៈពេលដែលប្រទេសទាំងពីរផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹង កិច្ចសហប្រតិបត្តិការឆ្លងដែននៃគម្រោងរួមនេះ ផ្តល់នូវឱកាសដ៏សំខាន់មួយដើម្បីបង្កើតក្របខ័ណ្ឌសម្រាប់កិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងផលប៉ះពាល់រវាងតំបន់ខ្សែទឹកខាងលើ-ខាងក្រោមនៃការវិនិយោគទាំងនេះ តាមរយៈផែនការគ្រប់គ្រងតាមវិស័យ និងក្នុងមូលដ្ឋាន និងពង្រឹកការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ីដែលពាក់ព័ន្ធ សម្រាប់ភាពធន់នឹងទឹកជំនន់និងគ្រោះរាំងស្ងួត។ ដំណាក់កាលបច្ចុប្បន្ន (២០១៩-២០២១) នៃគម្រោងរួម MRC-GIZ កំពុងចុះបេសកកម្មនៅតាមមូលដ្ឋាន ដើម្បីចងក្រងឯកសារអំពីតំបន់រេចរឹល និងកន្លែងងាយរងគ្រោះដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួត និងគិតគូរអំពីវិធានការកាត់បន្ថយទឹកជំនន់និងគ្រោះរាំងស្ងួតដែលសមស្របតាមទីតាំងជាក់លាក់ ដើម្បីកសាងភាពធន់នៅក្នុងអាងនេះ។

អាទិភាពយុទ្ធសាស្ត្រ ២ នៃផែនការមេនេះ នឹងផ្តល់ការវិនិយោគជាសំខាន់ ដើម្បីធ្វើការស្តារឡើងវិញនូវតំបន់ទេសភាពសម្រាប់ជាបណ្តាញការអនុវត្តបង្ហាញ'ភាតរៈ'នៃដំណោះស្រាយធម្មជាតិសម្រាប់ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅតាមជនបទ តំបន់ជុំវិញទីក្រុង តំបន់ទីក្រុង និងតំបន់ការពារធម្មជាតិទាំងសងខាងព្រំដែនកម្ពុជា និងថៃ។[4] ឧទាហរណ៍អំពីវិធានការនេះ មានជាអាទិ៍ ការស្តារឡើងវិញនូវទីជម្រាលក្នុងតំបន់ខ្សែទឹកខាងលើ និងច្រករបៀងដោះទឹកដែលរេចរិល, ការកែលំអ និងបង្កើតផ្លូវទឹក/ទំនាបលិចទឹក/តំបន់ដីសើម និងស្រះ រួមផ្សំជាមួយ ការពង្រឹងច្រាំងនៃស្ទឹងនានា ដើម្បីកាត់បន្ថយការហូរច្រោះ និងកំណកល្បាប់, ការស្តារឡើងវិញ និងការបង្កើតភាពធន់នៅក្នុងទេសភាពកសិកម្ម ដោយផ្សារភ្ជាប់ជាមួយជីវភាពរស់នៅឆ្លាតវៃចំពោះអាកាសធាតុ និងពង្រីកតំបន់បៃតងនៅក្នុងទីក្រុង។

នៅពេលមានកិច្ចជាច្រើនដែលត្រូវអនុវត្ត ដើម្បីស្តារអាង 9C-9T ក្នុងគោលដៅកាត់បន្ថយហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួត គេត្រូវការឱ្យមានការណែនាំជាចាំបាច់អំពីទីតាំងជាក់លាក់ ដើម្បីចាត់អាទិភាពការវិនិយោគសម្រាប់អាទិភាពជាយុទ្ធសាស្ត្រទី ២។ ជំហានដំបូង អាងនេះត្រូវបានបែងចែកទៅជា ១៨ អនុទីជម្រាល សម្រាប់ចាត់ថ្នាក់ ដោយយោងតាមតម្រូវការនៃការស្តារឡើងវិញ (ចំពោះសេចក្តីលម្អិតអំពីការវាយតម្លៃទីជម្រាលនេះ សូមអានឧបសម្ព័ន្ធ២)។ បន្ទាប់មក ត្រូវធ្វើការកំណត់តំបន់សាកល្បងជាក់លាក់នៅក្នុងទីជម្រាលដែលមានអាទិភាពខ្ពស់ទាំងនេះ សម្រាប់ការវិនិយោគភ្លាមៗជាមួយវិធានការដើម្បីកសាងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត (រូបភាពទី ៩)។

*រូបភាពទី ៩. ការដាក់ពិន្ទុ និងការកំណត់ជ្រើសរើសអនុទីជម្រាល*




[4] គម្រោងភាតរៈចែកចេញជាពីរបែប - (i) គម្រោងដែលនៅជាប់ព្រំដែន ដែលទាមទារឱ្យមានសកម្មភាពពីប្រទេសថៃ និងកម្ពុជា ដើម្បីសម្រេចគោលបំណងរួម ដូចជា គម្រោងទីក្រុងភាតរៈប៉ោយប៉ែត និងអារញ្ញប្រាថេត ដែលពាក់ព័ន្ធនឹងសកម្មភាពដាច់ដោយឡែកពីគ្នា ប៉ុន្តែស្រដៀងគ្នានៅក្នុងទីក្រុងនីមួយៗ និងសកម្មភាពរួមគ្នាតាមច្រករបៀងរួមគ្នាដែលជាស្ទឹង; និង (ii) គម្រោងដែលបានធ្វើឡើងដោយឡែកពីគ្នា ប៉ុន្តែដោះស្រាយបញ្ហាស្រដៀងគ្នា ដូចជាការអនុវត្តដំណោះស្រាយផ្អែកលើធម្មជាតិ ដើម្បីការពារ និងពង្រឹងមុខងារនៃអាងស្តុកទឹកដែលមានកំណកល្បាប់ខ្លាំង និងដែលពាក់ព័ន្ធជាមួយការចែករំលែក និងការតម្រូវឱ្យមានកិច្ចសម្របសម្រួលជិតស្និទ្ធរវាងប្រទេសទាំងពីរ។ គម្រោងទាំងពីរបែបនេះ នឹងត្រូវបញ្ចូលជាផ្នែកមួយនៃសំណើថវិកា ដើម្បីគាំទ្រដល់ការអនុវត្តផែនការមេនេះ។

ការអភិវឌ្ឍបណ្តាញនេះបន្ថែមទៀត ត្រូវភ្ជាប់ទៅនឹងហេដ្ឋារចនាសម្ព័ន្ធ និងតំបន់ការពារធម្មជាតិ(PA)ដែលមានស្រាប់ ដើម្បីសម្រួលដល់ការចូលរួមនិងការពាក់ព័ន្ធនៃវិស័យឯកជន តាមរយៈកិច្ចព្រមព្រៀងអភិរក្សជាមួយសហគមន៍ និងគណៈកម្មការសហគមន៍។ នៅតំបន់ជនបទ និងតំបន់ទ្រនាប់នៃ PA វិធានការទាំងនេះត្រូវធ្វើការជាមួយសហគមន៍ ដើម្បីលើកកម្ពស់ឱកាសសម្រាប់របរជីវិតដែលសន្សំសំចៃទឹក និងអត្ថប្រយោជន៍នៃការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី។ តាមរយៈវិធីសាស្ត្រនេះ ការវិនិយោគលើការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី មិនត្រឹមតែបង្កើតភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមចំណែកបង្កើតផលប្រយោជន៍សេដ្ឋកិច្ចពិតប្រាកដ ការលើកកម្ពស់ជីវភាពរស់នៅ និងសន្តិសុខស្បៀង តាមរយៈអភិក្រមចម្រុះបៃតងប្រផេះ។

### *៤.៥.៣ អាទិភាពយុទ្ធសាស្ត្រ ៣ និង ៤ .ការផ្តោះប្តូរព័ត៌មាន និងចំណេះដឹង និងពង្រឹងបណ្តាញជលសាស្ត្រ-ឧតុនិយម និងការប្រកាសផ្តល់ព័ត៌មានជាមុនអំពីទឹកជំនន់និងគ្រោះរាំងស្ងួត*

- **លទ្ធផល ៣.៣ ៖ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត និង ដែលងាយប្រឈមបញ្ហាអាកាសធាតុ IWRM តាមរយៈការចែករំលែកចំណេះដឹង**
- **លទ្ធផល ៣.៣ ៖ពង្រីកការអនុវត្តល្អ និងចែករំលែកមេរៀនដែលបានពីគម្រោងរួម ៖C-9T ក្នុងអាងទន្លេមេគង្គក្រោម**
- **លទ្ធផល ៤.៤ ៖បានពង្រឹងពិធីសារត្រួតពិនិត្យរួមគ្នា និងការប្រកាសផ្តល់ព័ត៌មានជាមុនអំពីជលសាស្ត្រ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ និងគ្រោះរាំងស្ងួត**

អាទិភាពយុទ្ធសាស្ត្រទី ៣ និងទី ៤ និងលទ្ធផលនៅក្រោមអាទិភាពនេះ សង្កត់ធ្ងន់លើការកែលំអបណ្តាញស្ថានីយ៍ជលសាស្ត្រ-ឧតុនិយម និងការប្រកាសផ្តល់ព័ត៌មានជាមុន ក៏ដូចជា ការចែករំលែកចំណេះដឹង និងព័ត៌មានផងដែរ។ តាមរយៈអាទិភាពទាំងនេះ ពិធីសាររួមសម្រាប់ការត្រួតពិនិត្យ ការប្រកាសផ្តល់ព័ត៌មាន និងការចែករំលែកទិន្នន័យ នឹងត្រូវបង្កើតឡើងសម្រាប់មុខសញ្ញាគ្រោះថ្នាក់នៃទឹកជំនន់ និងគ្រោះរាំងស្ងួត ជាពិសេស សម្រាប់ការតាមដានវឌ្ឍនភាពធៀបនឹងគោលបំណងនៃផែនការមេនេះ។ នៅក្នុងការគ្រោងទុកនេះផងដែរគឺ ការបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការឆ្លងដែន ដើម្បីចែករំលែកមេរៀន សម្រាប់ការអនុវត្តល្អលើការកសាងផែនការអាងទន្លេឆ្លងព្រំដែនដោយកម្ពុជា និងថៃ ជាមួយអនុអាងដទៃទៀតនៃដៃទន្លេមេគង្គ។

បច្ចុប្បន្ននេះ ប្រទេសទាំងពីរពុំមានយន្តការផ្លាស់ប្តូរទិន្នន័យរវាងគ្នាជាប្រព័ន្ធឡើយ ដែលរួមទាំង ក្នុងអំឡុងពេលព្រឹត្តិការណ៍ទឹកជំនន់ និងគ្រោះរាំងស្ងួត និងពុំមានពិធីសារសម្រាប់ការថែទាំ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យដែលគាំទ្រដល់ការសម្រេចចិត្តក្នុងការរៀបចំផែនការនិងព័ត៌មាន ដែលរួមបញ្ចូលនៅក្នុងសៀវភៅផែនទីអាង 9C-9T ថ្មីនេះឡើយ។ បណ្តាញស្ថានីយ៍ជលសាស្ត្រ-ឧតុនិយមនៅក្នុងអនុអាងនេះ ស្ថិតនៅដាច់ឆ្ងាយពីគ្នាខ្លាំងណាស់ និងផ្តល់ព័ត៌មានត្រឹមតិចតួចប៉ុណ្ណោះអំពីលំហូរឆ្លងដែន។ នៅក្នុងគ្រាមានទឹកជំនន់ និងគ្រោះរាំងស្ងួត ប្រសិទ្ធភាពទាបនៃការប្រកាសផ្តល់ព័ត៌មាននៅថ្នាក់ក្រោមជាតិ ឬក្នុងការប្រាស្រ័យទាក់ទងឆ្លងដែន មានន័យថា ការខូចខាតទំនងជាកើនឡើង ស្របជាមួយកំណើនភាពញឹកញាប់នៃទឹកជំនន់ និងគ្រោះរាំងស្ងួត ដោយសារការប្រែប្រួលអាកាសធាតុ និងការវេចរិលនៃទីជម្រាល។ ភាពខ្វះចន្លោះដ៏សំខាន់មួយទៀតដែលនៅតែមាន ពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងការវាយតម្លៃសម្រាប់ផែនការអាង ជាពិសេសនៅកម្ពុជា។ ជាលទ្ធផល នៅកម្ពុជា ពុំមានវឌ្ឍនភាពជាក់ស្តែងលើការអនុវត្តផែនការអាងដែលមានស្រាប់តែមួយនោះឡើយ

(សម្រាប់ ស្ទឹងស្រែង)ចាប់តាំងបានអនុម័តនៅឆ្នាំ២០១៥ មក។ កង្វះការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យអាងនៅក្នុងប្រទេសទាំងពីរនេះ ក៏ជាការបាត់បង់ឱកាសផងដែរ។

អាទិភាពជាយុទ្ធសាស្ត្រ ៤ នឹងពិនិត្យ និងពង្រីកបណ្តាញស្ថានីយ៍ជលសាស្ត្រ-ឧតុនិយម និងបង្កើតពិធីសារសម្រាប់ការផ្លាស់ប្តូរទិន្នន័យក្នុងពេលជាក់ស្តែងរវាងប្រទេសទាំងពីរ។ អាទិភាពនេះក៏នឹងអភិវឌ្ឍសមត្ថភាពក្នុងការបង្កើតម៉ូដែលទឹកជំនន់ និងគ្រោះរាំងស្ងួត និងការប្រាស្រ័យទាក់ទងលទ្ធផល ដោយផ្អែកលើម៉ូដែលបង្កើតឡើងនៅក្រោមគម្រោងរួម MRC-GIZ ក្នុងភាពជាដៃគូជាមួយមជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតថ្នាក់តំបន់នៃMRCផងដែរ។ ប្រព័ន្ធសហគមន៍សម្រាប់ការត្រួតពិនិត្យ និងរាយការណ៍អំពីសុខភាពទីជម្រាល នឹងត្រូវបង្កើតឡើងជាធាតុចូលសម្រាប់ការវាយតម្លៃ និងវដ្តនៃការកសាងផែនការអាងសម្រាប់ 9C-9T ដោយផ្សារភ្ជាប់ជាមួយសៀវភៅផែនទីអាង 9C-9T DSS ថ្មី។

សកម្មភាពផែនការមេ រួមមាន ការចងក្រងឯកសារនូវមេរៀនដែលទទួលបាន ជាធាតុចូលក្នុងការអនុវត្តឡើងវិញនាពេលខាងមុខ និងការបញ្ជ្រាបទៅក្នុងផែនការអាងទន្លេជាច្រើន ដែលគ្រោងរៀបចំឡើង នៅទូទាំងប្រទេសទាំងពីរ ក្រោមគោលនយោបាយដែលបានកែសម្រួលឡើងវិញនាពេលថ្មីៗនេះ និងនៅក្នុងអនុអាងឆ្លងកាត់ព្រំដែនស្រដៀងគ្នានេះ ក្នុងតំបន់មេគង្គ។ សកម្មភាពទាំងនេះនឹងត្រូវបានផ្សព្វផ្សាយ តាមរយៈការបង្កើតបណ្តាញចែករំលែកចំណេះដឹងធំមួយ ដើម្បីគាំទ្រដល់ការបញ្ជ្រាបដំណោះស្រាយផ្អែកលើធម្មជាតិ នៅក្នុងការរៀបចំផែនការសកម្មភាពអាងទន្លេនៅកម្ពុជា និងថៃ និងពង្រីកការកសាងផែនការនិងយន្តការត្រួតពិនិត្យឆ្លងដែនរួមគ្នា និងពិធីសារនានា សម្រាប់អនុវត្តនៅក្នុងអនុអាងរួមស្រដៀងគ្នានេះរវាងប្រទេសទាំងពីរដែលជាសមាជិក MRC។ MRC នឹងចាត់ចែងគ្រប់គ្រង និងពង្រីកការប្រើប្រាស់បណ្តាញនេះ ដោយពង្រឹងកិច្ចសហប្រតិបត្តិការដែលមានស្រាប់ក្នុងតំបន់ និងការគាំទ្រ តាមរយៈយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង។

### *៤.៥.៤ អាទិភាពយុទ្ធសាស្ត្រ ៥ .កសាងសមត្ថភាពក្នុងតំបន់*

- **លទ្ធផល ៥.១ ៖បានពង្រឹងសមត្ថភាពសម្រាប់ការស្តារ និងថែទាំអាង តាមរយៈវិធានការណ៍ផ្អែកលើធម្មជាតិនិងចម្រុះ**
- **លទ្ធផល ៥.២ ៖បានពង្រឹងសមត្ថភាពសម្រាប់ការរៀបចំផែនការអាងទន្លេ និងការគ្រប់គ្រងអាងទន្លេឆ្លងដែន**
- **លទ្ធផល ៥.៣ ៖បានពង្រឹងសមត្ថភាពធ្វើម៉ូដែលទឹកជំនន់ និងគ្រោះរាំងស្ងួត ការបកស្រាយ និងការប្រាស្រ័យទាក់ទងលទ្ធផល**

អាទិភាពយុទ្ធសាស្ត្រ ៥ និងលទ្ធផលនៅក្រោមអាទិភាពនេះ បង្កើតសមត្ថភាពចាំបាច់ ដើម្បីគាំទ្រដល់អាទិភាពបួនផ្សេងទៀត។ ការកសាងសមត្ថភាពនឹងផ្តោតជាពិសេសលើ វិស្វករ អ្នកគ្រប់គ្រងធនធានធម្មជាតិ អ្នករៀបចំផែនការទីក្រុង និងអ្នកគ្រប់គ្រងព្រៃឈើ និងតំបន់ការពារធម្មជាតិ លើការរចនាប្លង់ និងការអនុវត្តជាក់ស្តែងនូវដំណោះស្រាយផ្អែកលើធម្មជាតិ។ ក្រុមទាំងនេះ នៅពុំទាន់យល់ច្បាស់នៅឡើយទេអំពីតួនាទី និងវិធីប្រើប្រាស់ដំណោះស្រាយផ្អែកលើធម្មជាតិ ជាពិសេសនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធសាមញ្ញ។ ប្រទេសទាំងពីរត្រូវការជំនាញ គោលនយោបាយ ស្តង់ដារ និងការប្តេជ្ញាចិត្តពីស្ថាប័នជាន់ខ្ពស់ ទើបការអនុវត្តជាប្រព័ន្ធនៃដំណោះស្រាយផ្អែកលើធម្មជាតិនៅតាមមូលដ្ឋាន អាចផ្តល់អត្ថប្រយោជន៍ពីជីវចម្រុះ លើកកម្ពស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងពហុប្រយោជន៍នានា ដូចជា សម្រួបកាបូនជាដើម។

ផែនការមេស្វែងរកការកសាងសមត្ថភាពលើការរចនាប្លង់ និងការអនុវត្តដំណោះស្រាយទាំងនេះ ដែលរួមទាំងអន្តរាគមន៍នៅកម្រិតតំបន់ទេសភាពសម្រាប់ការស្តារឡើងវិញនូវព្រៃឈើ និងតំបន់ដីសើមធម្មជាតិ និងអន្តរាគមន៍នៅតាមទីតាំងជាក់លាក់ ដូចជា តំបន់ដីសើមសិប្បនិម្មិត ការគ្រប់គ្រងសំណឹក ការគ្រប់គ្រងទឹកក្នុងទីក្រុង និងវិធានការលើផ្អែក

គុណភាព។ ការស្តារឡើងវិញនូវព្រៃឈើ និងតំបន់ដីសើមនៅតាមទំនាបលិចទឹក អាចកាត់បន្ថយហានិភ័យនៃទឹកជំនន់ គ្រោះរាំងស្ងួត ការបំពុលទឹក និងកង្វះទឹក ដែលទំនងជាកាន់តែធ្ងន់ធ្ងរនៅក្រោមលក្ខខណ្ឌអាកាសធាតុនាពេលអនាគត។

ប្រព័ន្ធអេកូឡូស៊ីដែលមានសុខភាពល្អ អាចដើរតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងអាងទន្លេ។ ប្រព័ន្ធអេកូឡូស៊ីអាចជួយកាត់បន្ថយលំហូរដោយរក្សាទុកទឹកនៅក្នុងប្រព័ន្ធ និងបញ្ចេញទឹកបន្តិចម្តងៗតាមពេលវេលា ដោយកាត់បន្ថយប្រពលភាព និងលទ្ធភាពនៃការកើតឡើងនៃព្រឹត្តិការណ៍ទឹកជំនន់ដ៏មហន្តរាយ។ ប្រព័ន្ធអេកូឡូស៊ីជួយស្តុកទឹក និងរក្សាការពារទន្លេ និងប្រព័ន្ធដោះទឹក ដោយផ្តល់ទឹកនៅក្នុងអំឡុងពេលគ្រោះរាំងស្ងួត។ ប្រព័ន្ធអេកូឡូស៊ីអាចដើរតួជាហេដ្ឋារចនាសម្ព័ន្ធធម្មជាតិ ដោយកាត់បន្ថយផលប៉ះពាល់ពីគ្រោះមហន្តរាយ តាមរយៈការកាត់បន្ថយភាពងាយរងគ្រោះរូបវន្ត និងពង្រឹងភាពធន់។ ស្ថាប័នអភិវឌ្ឍន៍ធនធានទឹកក្នុងប្រទេសទាំងពីរនៅត្រូវការសមត្ថភាពជាច្រើន មុននឹងអាចធ្វើសមាហរណកម្មពេញលេញនូវលក្ខខណ្ឌតម្រូវសម្រាប់ការថែរក្សាប្រព័ន្ធអេកូឡូស៊ីទៅក្នុងការវិនិយោគ និងការអនុវត្តជាក់ស្តែងរបស់ស្ថាប័នទាំងនោះ ជាមួយការគាំទ្រពីវិស័យពាក់ព័ន្ធផ្សេងទៀត។

ការទទួលយកអភិក្រមផ្អែកលើធម្មជាតិសម្រាប់កាត់បន្ថយហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួត ទាមទារឱ្យមានការយល់ដឹងថែមទៀត អំពីលក្ខខណ្ឌប្រែប្រួលនៃប្រព័ន្ធជលសាស្ត្រក្នុងអនុអាង 9C-9T និងការពិចារណាលើចំណងទាក់ទងរវាងតំបន់ខ្សែទឹកខាងលើនិងខាងក្រោម នៃសកម្មភាពអភិវឌ្ឍន៍ និងហានិភ័យដែលកើតចេញពីសកម្មភាពអភិវឌ្ឍន៍ទាំងនោះ។ ការទទួលយកអភិក្រមបែបនេះ គឺជាស្នូលក្នុងការដោះស្រាយហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួតតាមវិធីចម្រុះ ដែលឈានហួសព្រំដែនរដ្ឋបាល និងវិស័យនីមួយៗដាច់ពីគ្នា។ អភិក្រមនេះអំពាវនាវឱ្យមានសកម្មភាពរួមនៅគ្រប់កម្រិតភាគីពាក់ព័ន្ធ និងវិស័យនានា ដោយចាត់ទុកអនុអាង 9C-9T ទាំងមូលជាប្រធានបទស្នូលនៃការកសាងផែនការ និងការសម្រេចចិត្ត ក៏ដូចជា សម្រាប់អភិបាលកិច្ចអនុអាងនេះផងដែរ។ ដើម្បីធ្វើបែបនេះបាន ទាមទារនូវសមត្ថភាពថ្មីៗ ក្នុងការរៀបចំផែនការអាងទន្លេ និងការគ្រប់គ្រងឆ្លងដែន ការបង្កើតម៉ូដែលទឹកជំនន់ និងគ្រោះរាំងស្ងួត ការបកស្រាយ និងការប្រាស្រ័យទាក់ទងដោយប្រសិទ្ធភាពនូវលទ្ធផល ដើម្បីឱ្យអ្នកធ្វើសេចក្តីសម្រេចជាន់ខ្ពស់ទទួលយកទាំងស្រុង និងប្តេជ្ញាចិត្តមោះមុត ចំពោះយុទ្ធសាស្ត្រគ្រប់គ្រងអាង ដោយជឿជាក់ថា បានផ្អែកលើវិទ្យាសាស្ត្រនិងការវិភាគល្អបំផុតដែលមាន។

## ៤.៦ ផែនការសកម្មភាព

ជាតុចេញពិស្តារដែលបានស្នើឡើងក្រោមសមាសធាតុនីមួយៗ ត្រូវបានចែងទៅតាមគោលបំណង លទ្ធផល និងជាតុចេញ ដែលមានបង្ហាញក្នុងតារាងទី ២។ អន្តរាគមន៍ជាបីកម្រិត - ទ្វេភាគី ជាតិ និងមូលដ្ឋាន - ដែលពាក់ព័ន្ធនឹងជាតុចេញនីមួយៗ ត្រូវបានយកមកពិចារណា។ ដើម្បីអនុវត្តសកម្មភាពដែលបានកំណត់នៅក្នុងផែនការមេនេះ ទាមទារឱ្យមានការផ្តល់ ទាំងថវិកាជាតិ និងពីក្រៅប្រទេស។ សន្ទស្សន៍ថវិកា ជាវិភាគទានពីប្រភពនីមួយៗ ក៏មានចែងសម្រាប់លទ្ធផលនីមួយៗផងដែរនៅក្នុងតារាងទី ៣។

## តារាងទី ២អាទិភាពយុទ្ធសាស្ត្រ លទ្ធផល អន្តរាគមន៍ និងសន្ទស្សន៍ថវិកា នៃផែនការសកម្មភាព .

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | កម្រិតនៃអន្តរាគមន៍ | ប្រាំឆ្នាំដំបូងនៃកម្មវិធីសម្រាប់រយៈពេល ១៥ឆ្នាំ | | | | | ថវិកា – ២០២២-២០២៦ (ដុល្លាអាមេរិក) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | អន្តរជាតិ | ជាតិ-កម្ពុជា | ជាតិ-ថៃ | សរុប |
| អាទិភាព ១៖ ពិនិត្យ ធ្វើបច្ចុប្បន្នភាព និងអនុវត្តផែនការមេអាងទន្លេ 9C-9T | លទ្ធផល ១.១ ៖ បានបន្សុីក្របខ័ណ្ឌច្បាប់ និងការអនុវត្តសម្រាប់គ្រប់គ្រងធនធានទឹកឆ្លងដែន ដើម្បីគាំទ្រភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត | ធាតុចេញ ១.១.១៖ ពិនិត្យ និងធ្វើបច្ចុប្បន្នភាពផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួត 9C-9T ដែលជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍ជាតិ និងវដ្តថវិការយៈពេលប្រាំឆ្នាំដែលមានស្រាប់។ | ទ្វេភាគី | | | | | | ២០០.000 | ២០.000 | ៥០.000 | ២៧០.000 |
| | | ធាតុចេញ ១.១.២៖ ពិនិត្យ និងកែសម្រួលឡើងវិញនូវក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលសម្រាប់ការរៀបចំផែនការអាងទន្លេនៅក្នុងប្រទេសទាំងពីរ ដើម្បីឱ្យមានសង្គតិភាពនឹងគ្នា ដែលរួមទាំង លក្ខខណ្ឌតម្រូវសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រដែលជាផ្នែកមួយនៃការរៀបចំផែនការ។ | ជាតិ – និងការពិគ្រោះយោបល់ទ្វេភាគី ដើម្បីធានាឱ្យមានសង្គតិភាព | | | | | | ៦០.000 | ២០.000 | ២០.000 | ១០០.000 |
| | | ធាតុចេញ ១.១.៣៖ ពិនិត្យ និងកែសម្រួលឡើងវិញនូវក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលសម្រាប់ការរៀបចំផែនការរូបវន្ត និងការកំណត់តំបន់គ្រប់គ្រង ដោយមានប្រព័ន្ធការពារ នៅក្នុងទីជម្រាលទាំងមូល និងធានាឱ្យមានឧបករណ៍ និងសមត្ថភាពពាក់ព័ន្ធនៅនឹងកន្លែង។ | ជាតិ និងទ្វេភាគីសម្រាប់ទីជម្រាលឆ្លងដែន | | | | | | ៦០.000 | ២០.000 | ២០.000 | ១០០.000 |
| | | ធាតុចេញ ១.១.៤៖ ពិនិត្យ និងកែសម្រួលក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលសម្រាប់ប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធានាឱ្យមានការវាយតម្លៃហេតុប៉ះពាល់បណ្តុំនៃការអភិវឌ្ឍជាច្រើន (ខ្នាតតូច និងធំ) នៅក្នុងទីជម្រាលជាមួយគ្នា។ | ជាតិ និងទ្វេភាគីសម្រាប់ទីជម្រាលឆ្លងដែន | | | | | | ៦០.000 | ២០.000 | ២០.000 | ១០០.000 |
| | លទ្ធផល ១.២ ៖ បានពង្រឹងយន្តការដើម្បីកែលម្អផែនការ IWRM និងការគ្រប់គ្រងចម្រុះអាងទន្លេ សម្រាប់ទឹកជំនន់ និងគ្រោះរាំងស្ងួត | ធាតុចេញ ១.២.១៖ អនុវត្តការវាយតម្លៃភាពងាយរងគ្រោះចំពោះមុខការប្រែប្រួលអាកាសធាតុនៃអាងទន្លេ 9C-9T ឆ្លងដែន និងការរៀបចំផែនការបន្សាំ សម្រាប់ជាធាតុចូលទៅក្នុងដំណើរការរៀបចំផែនការ និងក្នុងផែនការអាងទន្លេ | ទ្វេភាគី | | | | | | ៦០.000 | ២០.000 | ៥០.000 | ១៣០.000 |
| | | ធាតុចេញ ១.២.២៖ បង្កើតគណៈកម្មាធិការអាងទន្លេ 9C កម្ពុជា ដើម្បីបង្កើនការចូលរួមអន្តរវិស័យ និងសហគមន៍ក្នុងការគ្រប់គ្រងអាងទន្លេដោយផ្អែកលើរចនាសម្ព័ន្ធស្ថាប័នអន្តរវិស័យ 9C-9T ដែលមានស្រាប់ សម្រាប់កិច្ចសហប្រតិបត្តិការឆ្លងដែន។ | កម្ពុជា ជាមួយការពិគ្រោះយោបល់ទ្វេភាគី និងការរៀនសូត្រពីបទពិសោធន៍ | | | | | | ៦០.000 | ៥០.000 | 0 | ១១០.000 |
| | | ធាតុចេញ ១.២.៣៖ អនុវត្តការវាយតម្លៃ SEA ឆ្លងដែន នៃផែនការសកម្មភាពអាង 9C-9T និងកំណត់តំបន់គ្រប់គ្រងទៅតាមគុណតម្លៃនៃការអភិរក្ស និងការប្រើប្រាស់ ដោយផ្សារភ្ជាប់ជាមួយគោលការណ៍ណែនាំសម្រាប់ការស្តារ និងការគ្រប់គ្រងតំបន់ទាំងនោះ និងកំណែទម្រង់គោលនយោបាយ និងស្ថាប័នដែលពាក់ព័ន្ធ។ | ទ្វេភាគី | | | | | | ២០០.000 | ២០.000 | ៥០.000 | ២៧០.000 |
| | | ធាតុចេញ ១.២.៤៖ អនុវត្តការវាយតម្លៃហេតុប៉ះពាល់បណ្តុំទូលំទូលាយ និងដោយតម្លាភាពលើហេដ្ឋារចនាសម្ព័ន្ធដែលបានគ្រោងសម្រាប់អាង 9C-9T ដូចជា ទំនប់ស្ទាក់ទឹក ស្រះ អណ្តូង អាងស្តុកទឹក និងទំនប់ទឹក និងប្រព័ន្ធស្រោចស្រព ដែលរួមទាំង ប្រព័ន្ធស្ថានីយ៍បូមទឹក (ឧទាហរណ៍ ហេដ្ឋារចនាសម្ព័ន្ធដែលមានចុះក្នុងបញ្ជីនៅក្នុងផែនការមេធនធានទឹកជាតិនៃប្រទេសថៃ និងផែនការមេអភិវឌ្ឍន៍វិស័យនៃក្រសួងធនធានទឹក និងឧតុនិយម) | កម្ពុជា និងទ្វេភាគីសម្រាប់ទីជម្រាលឆ្លងដែន | | | | | | ៣០.000 | ១៥០.000 | ២០០.000 | ៣៨០.000 |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | កម្រិតនៃអន្តរាគមន៍ | ប្រាំឆ្នាំដំបូងនៃកម្មវិធីសម្រាប់រយៈពេល ១៥ឆ្នាំ | | | | | ថវិកា – ២០២២-២០២៦ (ដុល្លាអាមេរិក) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | អន្តរជាតិ | ជាតិ-កម្ពុជា | ជាតិ-ថៃ | សរុប |
| | | ធាតុចេញ ១.២.៥៖ រៀបចំ និងអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពយេនឌ័រ និងសហគមន៍ងាយរងគ្រោះសម្រាប់ការបញ្ជ្រាបទៅក្នុងផែនការ និងវិធានការសម្រាប់វិស័យធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។ | ទ្វេភាគី និងជាតិ | | | | | | ៣០.000 | ២០.000 | ២០.000 | ៧០.000 |
| | | ធាតុចេញ ១.២.៦៖ ពិនិត្យ រៀបចំ និងអនុម័តផែនការសកម្មភាពសុខដុមនីយកម្មតាមវិស័យ សម្រាប់តំបន់នានាក្នុងអនុអាង 9C និង 9T ដើម្បីកសាងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត (ពោលគឺផែនការរបស់ស្ថាប័នពាក់ព័ន្ធនៃវិស័យនានារបស់រដ្ឋាភិបាលថ្នាក់ជាតិ ដែលទទួលខុសត្រូវលើវិស័យផ្សេងៗ ដូចជា ការគ្រប់គ្រងទឹក ប្រព័ន្ធធារាសាស្ត្រ ព្រៃឈើ និងកសិកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត និងការគ្រប់គ្រងបរិស្ថាន) | ទ្វេភាគី និងជាតិ | | | | | | ១៥០.000 | ៥០.000 | 50,000 | ២៥០.000 |
| | | ធាតុចេញ ១.២.៧៖ ធ្វើសុខដុមនីយកម្មទម្រង់ប្លង់សម្រាប់ទំនប់ ជាមួយបទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានា ដើម្បីធានាឱ្យទទួលបានគុណភាពជាផលចំណេញពីស្ថានភាពទីជម្រាល និងជីវចម្រុះ និងការពិចារណាអំពីផលប៉ះពាល់បណ្ដុំ។ | ទ្វេភាគី និងការអនុវត្តនៅថ្នាក់ជាតិ | | | | | | ២០.000 | ២០.000 | ២០.000 | ៦០.000 |
| | លទ្ធផល ១.៣ ៖ ការផ្តល់ហិរញ្ញប្បទានដោយនិរន្តរភាពសម្រាប់វិធានការបន្សុំាតាមប្រព័ន្ធអេកូឡូស៊ីសម្រាប់ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត | ធាតុចេញ ១.៣.១៖ អនុវត្តការវាយតម្លៃសេដ្ឋកិច្ចនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដើម្បីប៉ាន់ប្រមាណអត្ថប្រយោជន៍នៃការបន្សាំនឹងលក្ខខណ្ឌងាយប្រឈមនឹងកត្តាអាកាសធាតុ ការគិតគូរខាងយេនឌ័រ និងដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី សម្រាប់វិធានការធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។ | ទ្វេភាគី | | | | | | ៦០.000 | 0 | 0 | ៦០.000 |
| | | ធាតុចេញ ១.៣.២៖ កំណត់ឱកាសដើម្បីចងលក្ខខណ្ឌបង្ការផលប៉ះពាល់សម្រាប់វិធានការកសាងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ី ដើម្បីលើកទឹកចិត្តឱ្យមានការ វិនិយោគពីវិស័យឯកជនសម្រាប់ការអនុវត្តផែនការសកម្មភាពអាង 9C-9T។ | ទ្វេភាគី និងការអនុវត្តនៅថ្នាក់ជាតិ | | | | | | ៣០.000 | 0 | 0 | ៣០.000 |
| អាទិភាព ២ . គ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅទីក្រុង និងជនបទ ដើម្បីកាត់បន្ថយហានិភ័យ | លទ្ធផល ២.១ ៖ បានពង្រឹងភាពធន់នឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងទីក្រុង តាមរយៈ ឧបករណ៍ផែនការនៅនុវត្តន៍ដែលគិតគូរពីអាកាសធាតុ និងផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងអន្តរាគមន៍បន្សាំ | ធាតុចេញ ២.១.១៖ ធ្វើការវាយតម្លៃភាពងាយរងគ្រោះចំពោះមុខការប្រែប្រួលអាកាសធាតុ និងការរៀបចំផែនការបន្សាំ ដែលនាំមកនូវផែនការបន្សាំសម្រាប់ទីក្រុងគោលដៅចំនួនពីរ (សងខាងព្រំដែន) | ជាតិ – និងការពិគ្រោះយោបល់ទ្វេភាគី ដើម្បីធានាឱ្យមានសង្គតិភាព | | | | | | ៨០.000 | ១០.000 | ២០.000 | ១១០.000 |
| | | ធាតុចេញ ២.១.២៖ រៀបចំផែនការគ្រប់គ្រងហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួតនៅមូលដ្ឋានសម្រាប់តំបន់ទីក្រុងជាគោលដៅចំនួនពីរជាប់ព្រំដែន ទាំងសងខាងព្រំដែនកម្ពុជា-ថៃ និងធានាឱ្យមានសង្គតិភាពជាមួយផែនការមេសម្រាប់វិស័យពាក់ព័ន្ធ។ | ទ្វេភាគី ជាតិ និងថ្នាក់មូលដ្ឋាន | | | | | | ៦០.000 | ១០.000 | ២០.000 | ៩០.000 |
| | | ធាតុចេញ ២.១.៣៖ ពិនិត្យ និងកែសម្រួលការកំណត់តំបន់ក្នុងទីក្រុង និងកិច្ចការពារសុវត្ថិភាព និងយន្តការពង្រឹងការអនុវត្ត ដើម្បីបង្កើនភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត ដោយផ្តោតលើផ្លូវទឹកក្នុង | ទ្វេភាគីសម្រាប់តំបន់ជាប់ព្រំដែន ជាតិ និងថ្នាក់មូលដ្ឋាន | | | | | | ៦០.000 | ១០.000 | ២០.000 | ៩០.000 |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | កម្រិតនៃអន្តរាគមន៍ | ប្រាំឆ្នាំដំបូងនៃកម្មវិធីសម្រាប់រយៈពេល ១៥ឆ្នាំ | | | | | ថវិកា – ២០២២-២០២៦ (ដុល្លាអាមេរិក) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | អន្តរជាតិ | ជាតិ-កម្ពុជា | ជាតិ-ថៃ | សរុប |
| | | ទីក្រុង គម្របរុក្ខជាតិក្នុងទីក្រុង និងវិធានការណ៍បៃតង និងការកំណត់ផ្លូវទឹកដែលមានសក្តានុពល និងការកំណត់តំបន់ទឹកជំនន់នៅក្នុងទីក្រុងចំនួនពីរ (មួយនៅក្នុងប្រទេសនីមួយៗ)។[5] | | | | | | | | | | |
| | | ធាតុចេញ ២.១.៤៖ អភិវឌ្ឍ និងអនុវត្តហេដ្ឋារចនាសម្ព័ន្ធការពារចម្រុះ (បៃតង និងប្រផេះ) ដើម្បីកាត់បន្ថយហានិភ័យទឹកជំនន់ក្នុងទីក្រុង (ដូចជា ការកែលម្អដងស្ទឹងក្នុងទីក្រុង ស្ថេរភាពច្រាំងស្ទឹង និងតំបន់ធម្មជាតិសម្រាប់ស្រូបយកទឹកជំនន់) និងលើកកំពស់គុណភាពទឹកនៅក្នុងទីក្រុងគោលដៅចំនួនពីរ (មួយក្នុងប្រទេសនីមួយៗ)។ | ទ្វេភាគីសម្រាប់តំបន់ជាប់ព្រំដែន ជាតិ និងថ្នាក់មូលដ្ឋាន | | | | | | ២.000.000 | ១.000.000 | ១.000.000 | ៤.000.000 |
| | | ធាតុចេញ ២.១.៥៖ បង្កើត និងអនុវត្តវិធានការគ្រប់គ្រងតម្រូវការទឹក ដើម្បីកាត់បន្ថយបរិមាណទឹកដែលប្រើប្រាស់តាមគ្រួសារ វិស័យទីក្រុង និងឧស្សាហកម្ម ដោយផ្តោតលើការកសាងប្រព័ន្ធអេកូឡូស៊ី និងភាពធន់នឹងអាកាសធាតុ។ | ទ្វេភាគី ជាតិ និងថ្នាក់មូលដ្ឋាន | | | | | | ១.000.000 | ៥00.000 | ៥00.000 | ២.000.000 |
| | លទ្ធផល ២.២ ៖ បានពង្រឹងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតនៅតាមជនបទ តាមរយៈឧបករណ៍កសាងផែនការផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងអន្តរាគមន៍បន្សាំ | ធាតុចេញ ២.២.១៖ បង្កើត និងអនុវត្តវិធានការស្តារទេសភាពជនបទឡើងវិញ ដែលរួមទាំង សកម្មភាពកសិ-រុក្ខកម្ម និងការកែប្រែទម្លាប់អនុវត្តក្នុងកសិកម្ម តាមរយៈពិពិធកម្មមុខដំណាំ ការប្តូរមុខដំណាំ វិធានការនវានុវត្តក្នុងការស្រោចស្រព ដើម្បីសំចៃទឹក និងអនុវត្តអភិក្រមគ្រប់គ្រងតម្រូវការទឹក ការភ្ជួររាស់តិចជាងមុន និងការកែលម្អសមត្ថភាពរក្សាទឹកក្នុងដី និងសម្រួបកាបូន។ | ទ្វេភាគីសម្រាប់តំបន់ជាប់ព្រំដែន ជាតិ និងថ្នាក់មូលដ្ឋាន | | | | | | ១.៥00.000 | ៥00.000 | ៥00.000 | ២.៥00.000 |
| | | ធាតុចេញ ២.២.២៖ បង្កើតតំបន់គ្រប់គ្រងរូបវន្ត និងកិច្ចការពារតំបន់ទេសភាពជនបទ ជាពិសេសដែលទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និងថ្មីៗ និងការតម្លើងមធ្យោបាយត្រងយកកំណកល្បាប់ ធ្វើការបូមស្តារ ដើម្បីរក្សាសមត្ថភាព ការថែទាំដើម្បីទប់ស្កាត់ការទន្ទ្រានយកដីក្នុងអាងទឹកនិងតាមច្រាំងស្ទឹងសម្រាប់ធ្វើកសិកម្ម និងការបង្កើតតំបន់ទ្រនាប់រុក្ខជាតិនៅតាមបៀងដោះទឹក និងផ្លូវដឹកជញ្ជូន និងនៅតាមកន្លែងដែលបានកំណត់នៅតាមបណ្តោយព្រំដែន។ | ទ្វេភាគីសម្រាប់តំបន់ជាប់ព្រំដែន ជាតិ និងថ្នាក់មូលដ្ឋាន | | | | | | ១.000.000 | ៥00.000 | ៥00.000 | ២.000.000 |
| | | ធាតុចេញ ២.២.៣៖ បង្កើត និងអនុវត្តអន្តរាគមន៍ផ្អែកលើធម្មជាតិនិងចម្រុះយ៉ាងហោចណាស់ប្រាំមួយឈុត (៣ ក្នុងប្រទេសនីមួយៗ) ដើម្បីកាត់បន្ថយហានិភ័យទឹកជំនន់និងគ្រោះរាំងស្ងួតនៅតំបន់ជនបទ ដោយផ្តោតលើដំណោះស្រាយផ្អែកលើធម្មជាតិសម្រាប់ការកែលំអផ្លូវទឹក និងតំបន់ទ្រនាប់រុក្ខជាតិ ការពង្រឹងស្ថេរភាពច្រាំងស្ទឹង និងសម្រាប់ការថែទាំផ្លូវទឹក។ | ទ្វេភាគីសម្រាប់តំបន់ជាប់ព្រំដែន ជាតិ និងថ្នាក់មូលដ្ឋាន | | | | | | ២.000.000 | ១.000.000 | ១.000.000 | ៤.000.000 |
| | លទ្ធផល ២.៣៖ បានស្តារអាងទន្លេនៅតំបន់ក្បាលទឹក និងតំបន់ដីសើមឡើងវិញ | ធាតុចេញ ២.៣.១៖ បង្កើត និងអនុវត្តអន្តរាគមន៍យ៉ាងតិចប្រាំមួយ (៣ ក្នុងប្រទេសនីមួយៗ) សម្រាប់ការស្តារឡើងវិញ និងការគ្រប់គ្រងដោយប្រសិទ្ធភាពនូវតំបន់ការពារធម្មជាតិ និងទីជម្រាលនៅតំបន់ខ្សែទឹកខាងលើជាប្រភពទឹកនៃអាងទន្លេនេះ - ដើម្បីកែលម្អ និងថែរក្សាសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដោយសង្កត់ធ្ងន់លើកិច្ចការពារជីវចម្រុះដែលមានសារៈសំខាន់ជាអន្តរជាតិនៅតាមព្រំដែន។ | ទ្វេភាគីសម្រាប់តំបន់ជាប់ព្រំដែន ជាតិ និងថ្នាក់មូលដ្ឋាន | | | | | | ២.៥00.000 | ១.000.000 | ១.000.000 | ៤.៥00.000 |

[5] ត្រូវធ្វើឡើងដោយមានការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយ ADB TA CAM៖ ការគាំទ្របច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំផែនការទីក្រុង - គម្រោងទីប្រឹក្សាអនុវត្ត TA (53199-001)

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ជាតុចេញ | កម្រិតនៃអន្តរាគមន៍ | ប្រាំឆ្នាំដំបូងនៃកម្មវិធីសម្រាប់រយៈពេល ១៥ឆ្នាំ | | | | | ថវិកា – ២០២២-២០២៦ (ដុល្លាអាមេរិក) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | អន្តរជាតិ | ជាតិ-កម្ពុជា | ជាតិ-ថៃ | សរុប |
| | ដើម្បីកែលម្អសន្តិសុខទឹកនិងភាពធន់នឹងអាកាសធាតុ តាមរយៈអន្តរាគមន៍បន្សុំផ្អែកលើប្រព័ន្ធអេកូឡូស៊ី | ជាតុចេញ ២.៣.២៖ បង្កើត និងអនុវត្តអន្តរាគមន៍យ៉ាងហោចណាស់បួន (២ ក្នុងប្រទេសនីមួយៗ) ដើម្បីស្តារ និងគ្រប់គ្រងតំបន់ដីសើមក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាង ដើម្បីពង្រឹងតំបន់ទ្រនាប់នៃ PA និងកែលម្អភាពពេញលេញនៃប្រព័ន្ធអេកូឡូស៊ីសម្រាប់ការផ្តល់សេវាប្រព័ន្ធអេកូឡូស៊ី (ការស្តុកទឹក/ប្រព្រឹត្តកម្មទឹក/ទឹជម្រក) | ទ្វេភាគីសម្រាប់តំបន់ជាប់ព្រំដែន ជាតិ និងថ្នាក់មូលដ្ឋាន | | | | | | ១.000.000 | ៥00.000 | ៥00.000 | ២.000.000 |
| | | ជាតុចេញ ២.៣.៣៖ បង្កើនគម្របព្រៃឈើ និងលក្ខខណ្ឌនៅតំបន់ក្បាលទឹក តាមរយៈការដាំដំណាំចម្រុះប្រភេទ ដាំដើមឈើឡើងវិញ និងការស្តារឡើងវិញនូវតំបន់រេចរឹល ដើម្បីទទួលបានតុល្យភាពជាកំណើនជីវៈចម្រុះ និងការកែលម្អដី និងស្តុកកាបូនព្រៃឈើ ដើម្បីកាត់បន្ថយ និងកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ | ទ្វេភាគីសម្រាប់តំបន់ជាប់ព្រំដែន ជាតិ និងថ្នាក់មូលដ្ឋាន | | | | | | ១.000.000 | ៥00.000 | ៥00.000 | ២.000.000 |
| អាទិភាព ៣ការ . ផ្លោះប្តូរព័ត៌មាន និងចំណេះដឹង | លទ្ធផល ៣.១ ៖ ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត និង IWRM ដែលងាយប្រឈមបញ្ហាអាកាសធាតុ តាមរយៈការចែករំលែកចំណេះដឹង | ជាតុចេញ ៣.១.១៖ ថែរក្សា និងប្រើប្រាស់សៀវភៅផែនទីជាប្រព័ន្ធគាំទ្រសេចក្តីសម្រេចនៃគម្រោងរួម (DSS)សម្រាប់អាង 9C-9T ដើម្បីជូនដំណឹងដល់ការរៀបចំផែនការ និងការគ្រប់គ្រងអាង និងសម្របសម្រួលការចែករំលែកទិន្នន័យ រវាង ONWR និង MOWRAM និងអ្នកពាក់ព័ន្ធផ្សេងទៀត។ | ទ្វេភាគីនិង ជាតិ | | | | | | ១៥0.000 | ២៤.000 | ២៤.000 | ១៩៨.000 |
| | | ជាតុចេញ ៣.១.២៖ ការអភិវឌ្ឍ និងអនុវត្តប្រព័ន្ធសម្រាប់ប្រាស្រ័យទាក់ទងអន្តរកម្មឆ្លងដែនអំពីវត្តមានទឹក និងការសម្របសម្រួលដោយប្រសិទ្ធភាពលើប្រតិបត្តិការអាងស្តុកទឹកដើម្បីសន្តិសុខទឹក។ | ទ្វេភាគីនិង ជាតិ | | | | | | ៨0.000 | ១0.000 | ២0.000 | ១១0.000 |
| | | ជាតុចេញ ៣.១.៣៖ បង្កើតប្រព័ន្ធសម្រាប់សហគមន៍រាយការណ៍អំពីទីជម្រាល និងសុខភាពដែនទឹកជាធាតុចូលដ៏សំខាន់ សម្រាប់ការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងអាង 9C-9T ដែលរួមទាំង ការគាំទ្រនៅថ្នាក់មូលដ្ឋាន ក្នុងការត្រួតពិនិត្យបន្ត ការប្រមូលទិន្នន័យ និងការរៀបចំរបាយការណ៍ តារាងវាយតម្លៃសុខភាពប្រព័ន្ធអេកូឡូស៊ី រួមទាំង ការធ្វើផែនទីអំពីមុខសញ្ញាគ្រោះថ្នាក់ និងការវិភាគអំពីការឆ្លើយតប ដោយសហគមន៍។ | ទ្វេភាគីនិង ជាតិ | | | | | | ១៥0.000 | ២0.000 | ៣0.000 | ២00.000 |
| | លទ្ធផល ៣.២ ៖ ពង្រីកការអនុវត្តល្អ និងចែករំលែកមេរៀន ដែលបានពីគម្រោងរួម 9C-9T ក្នុងអាងទន្លេមេគង្គក្រោម | ជាតុចេញ ៣.២.១៖ ពង្រីកការអនុវត្តការងារត្រួតពិនិត្យនិងតាមដាន(M&E) និងវិធានការធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតឆ្លងដែន នៅទូទាំងតំបន់មេគង្គ តាមរយៈការចែករំលែកមេរៀនពីគម្រោងដែលបានអនុវត្តនៅកម្ពុជា ថៃ និងតាមរយៈយន្តការការផ្លោះប្តូរត្បូង-ត្បូង។[6] | ទ្វេភាគីនិង ជាតិ | | | | | | ៦0.000 | ២0.000 | ៣0.000 | ១១0.000 |
| | | ជាតុចេញ ៣.២.២៖ បង្កើត និងអនុវត្តយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ដើម្បីចែករំលែកចំណេះដឹង និងមេរៀនពីគម្រោង | ទ្វេភាគីនិង ជាតិ | | | | | | ៨0.000 | ១0.000 | ២0.000 | ១១0.000 |
| អាទិភាព ៤ . ពង្រឹងបណ្តាញ | លទ្ធផល ៤.១ ៖បាន ពង្រឹងពិធីសារត្រួតពិនិ | ជាតុចេញ ៤.១.១៖ ពិនិត្យ ធ្វើបច្ចុប្បន្នភាព និងពង្រីកបណ្តាញ ឧបករណ៍ និងប្រព័ន្ធត្រួតពិនិត្យរួមគ្នាលើ កម្រិតកំពស់ទឹកស្ទឹង និងជំនន់គំហុក ដែលរួមទាំង ការផ្ទៀងផ្ទាត់ទិន្នន័យពីស្ថានីយ ជាមួយម៉ូដែល | ទ្វេភាគីនិង ជាតិ | | | | | | ៥00.000 | ១00.000 | ២00.000 | ៨00.000 |

[6] ដែលគ្របដណ្តប់៖ i) ការកសាងផែនការ និងការគ្រប់គ្រងអាងទន្លេរួមគ្នា; ii) ការចាត់ចែងប្រកាសផ្តល់ព័ត៌មានអំពីទឹកជំនន់ និងគ្រោះរាំងស្ងួត; និង iii) ការអនុវត្តវិធីសាស្ត្រ និងឧបករណ៍សម្រាប់ EbA ដែលរួមទាំង ការគាំទ្រសម្រាប់ការបង្កើតកិច្ចសហការដើម្បីពង្រីកបទពិសោធន៍នៃ 9C-9T នៅក្នុងអនុអាងទន្លេរួមគ្នាដទៃទៀតនៃតំបន់មេគង្គ។

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | កម្រិតនៃអន្តរាគមន៍ | ប្រាំឆ្នាំដំបូងនៃកម្មវិធីសម្រាប់រយៈពេល ១៥ឆ្នាំ | | | | | ថវិកា – ២០២២-២០២៦ (ដុល្លារអាមេរិក) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | អន្តរជាតិ | ជាតិ-កម្ពុជា | ជាតិ-ថៃ | សរុប |
| ជលសាស្ត្រ-ឧតុនិយម និងការប្រកាសផ្តល់ព័ត៌មានជាមុនអំពីទឹកជំនន់និងគ្រោះរាំងស្ងួត | ត្រួតពិនិត្យរួមគ្នា និងការប្រកាសផ្តល់ព័ត៌មានជាមុនអំពីជលសាស្ត្រ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ និងគ្រោះរាំងស្ងួត | អ៊ីដ្រូលិក ការសម្របសម្រួល និងពិធីសារហានិភ័យគ្រោះមហន្តរាយ ដើម្បីបង្កើនប្រសិទ្ធភាព និងការចែករំលែកទិន្នន័យសម្រាប់ការត្រួតពិនិត្យ និង ការប្រកាសផ្តល់ព័ត៌មានជាមុន។ | | | | | | | | | | |
| | | ធាតុចេញ ៤.១.២៖ បង្កើតយន្តការរួមគ្នាសម្រាប់ការផ្លោះប្តូរទិន្នន័យត្រួតពិនិត្យជលសាស្ត្រតាមពេលវេលាជាក់ស្តែង និងការប្រកាសផ្តល់ព័ត៌មានជាមុន (ថ្នាក់ជាតិ ខេត្ត និងមូលដ្ឋាននៅតាមសហគមន៍គោលដៅ)។ | ទ្វេភាគីនិង ជាតិ | | | | | | ១០០.០០០ | ២០.០០០ | ៣០.០០០ | ១៥០.០០០ |
| | | ធាតុចេញ ៤.១.៣៖ ពង្រឹង ពង្រីកឧបករណ៍ប្រាស្រ័យទាក់ទង និងឧបករណ៍គ្រប់គ្រងចំណេះដឹង និងបច្ចេកវិទ្យាដែលមានស្រាប់ សម្រាប់ការប្រកាសផ្តល់ព័ត៌មានជាមុន ដើម្បីបង្កើនភាពធន់នឹងទឹកជំនន់នៃសហគមន៍ទីក្រុង។ | ទ្វេភាគីនិង ជាតិ | | | | | | ៥០០.០០០ | ១០០.០០០ | ២០០.០០០ | ៨០០.០០០ |
| | | ធាតុចេញ ៤.១.៤៖ ពិនិត្យ ធ្វើបច្ចុប្បន្នភាព និងពង្រីកបណ្តាញ ឧបករណ៍ និងប្រព័ន្ធត្រួតពិនិត្យរួមគ្នាសម្រាប់គ្រោះរាំងស្ងួត រួមទាំង ការព្យាករណ៍តាមរដូវ និងការកំណត់ស្ថានភាព សម្រាប់ការប្រកាសផ្តល់ព័ត៌មានជាមុនអំពីគ្រោះរាំងស្ងួត ដើម្បីកែលម្អប្រសិទ្ធភាព និងការចែករំលែកទិន្នន័យសម្រាប់ការត្រួតពិនិត្យ និងការប្រកាសផ្តល់ព័ត៌មានជាមុន។ | ទ្វេភាគីនិង ជាតិ | | | | | | ៦០.០០០ | ១០.០០០ | ២០.០០០ | ៩០.០០០ |
| | | ធាតុចេញ ៤.១.៥៖ បង្កើតនីតិវិធី និងសមត្ថភាពសម្រាប់ការបញ្ចូលជាប្រចាំនូវទិន្នន័យពីផ្កាយរណបទៅក្នុងការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត។ | ទ្វេភាគីនិង ជាតិ | | | | | | ៨០.០០០ | ១០.០០០ | ២០.០០០ | ១១០.០០០ |
| អាទិភាព ៥ . កសាងសមត្ថភាពក្នុងតំបន់ | លទ្ធផល ៥.១ ៖ បានពង្រឹងសមត្ថភាពសម្រាប់ការស្តារ និងថែទាំអាង តាមរយៈវិធានការណ៍ផ្អែកលើធម្មជាតិនិងចម្រុះ | ធាតុចេញ ៥.១.១៖ ផ្តល់ការបណ្តុះបណ្តាលពិស្តារដែលផ្អែកលើការងារតាមភូមិសាស្ត្រ សម្រាប់វិស្វករ អ្នកគ្រប់គ្រងព្រៃឈើ អ្នកគ្រប់គ្រងទីជម្រាល និងអ្នកឯកទេសដទៃទៀត អំពីវិធានការផ្អែកលើធម្មជាតិ និងចម្រុះ សម្រាប់គ្រប់អន្តរាគមន៍ខាងផ្នែកទឹកជំនន់ និងគ្រោះរាំងស្ងួត។ | ទ្វេភាគីនិង ជាតិ | | | | | | ២៥០.០០០ | ២០.០០០ | ៥០.០០០ | ៣២០.០០០ |
| | | ធាតុចេញ ៥.១.២៖ រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាល ដើម្បីកសាងសមត្ថភាពនៃវិស័យនៅតាមមូលដ្ឋាន និងអង្គការអាងទន្លេ សម្រាប់ការរចនាប្លង់លម្អិត ការអនុវត្ត និងការគ្រប់គ្រងវិធានការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់គោលដៅ។ | ទ្វេភាគីនិង ជាតិ | | | | | | ៦០.០០០ | ១០.០០០ | ១០.០០០ | ៨០.០០០ |
| | លទ្ធផល ៥ ២៖. បានពង្រឹងសមត្ថភាពសម្រាប់ការរៀបចំផែនការអាងទន្លេ និងការគ្រប់គ្រងអាងទន្លេឆ្លងដែន | ធាតុចេញ ៥.២.១៖ រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលសម្រាប់បុគ្គលិកជាន់ខ្ពស់ក្នុងវិស័យសាធារណៈនិងឯកជន ដែលរួមទាំងអំពី SEA នៃផែនការគ្រប់គ្រងអាងទន្លេ ការវាយតម្លៃសេដ្ឋកិច្ចនៃការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងគាំទ្រយន្តការហិរញ្ញវត្ថុ និងការវាយតម្លៃផលប៉ះពាល់បណ្តុំ នៃការអភិវឌ្ឍន៍ដែលមានស្រាប់ និងដែលបានគ្រោងទុក សម្រាប់ទីជម្រាល។ | ជាតិ និងមូលដ្ឋាន | | | | | | ៦០.០០០ | ១០.០០០ | ១០.០០០ | ៨០.០០០ |
| | | ធាតុចេញ ៥.២.២៖ រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលនៅថ្នាក់កណ្តាលនិងខេត្ត សម្រាប់ការវាយតម្លៃភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ និងផែនការបន្សាំតាមប្រព័ន្ធអេកូឡូស៊ី ដែលជាផ្នែកមួយនៃការកសាងផែនការអាងទន្លេ។ | ជាតិ និងមូលដ្ឋាន | | | | | | ៤០.០០០ | ១០.០០០ | ១០.០០០ | ៦០.០០០ |
| | | ធាតុចេញ ៥.២.៣៖ រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់កណ្តាល និងខេត្ត សម្រាប់អនុវត្តការងារគ្រប់គ្រងទឹកដោយយល់ដឹងពីហានិភ័យអាកាសធាតុ ក្នុងតំបន់ទីក្រុងនិងជនបទជាគោលដៅ។ | ជាតិ និងមូលដ្ឋាន | | | | | | ៤០.០០០ | ១០.០០០ | ១០.០០០ | ៦០.០០០ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ជាតុចេញ | កម្រិតនៃអន្តរាគមន៍ | ប្រាំឆ្នាំដំបូងនៃកម្មវិធីសម្រាប់រយៈពេល ១៥ឆ្នាំ | | | | | ថវិកា – ២០២២-២០២៦ (ដុល្លាអាមេរិក) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | អន្តរជាតិ | ជាតិ-កម្ពុជា | ជាតិ-ថៃ | សរុប |
| | លទ្ធផល ៥.៣ ៖បាន ពង្រឹងសមត្ថភាពធ្វើម៉ូដែលទឹកជំនន់និងគ្រោះរាំងស្ងួត ការបកស្រាយ និងការប្រាស្រ័យទាក់ទងលទ្ធផល | ជាតុចេញ ៥.៣.១៖ អភិវឌ្ឍសមត្ថភាពនៅថ្នាក់តំបន់ និងថ្នាក់ជាតិសម្រាប់ការបង្កើតម៉ូដែលទឹកជំនន់ ការបកស្រាយ និងការប្រាស្រ័យទាក់ទងលទ្ធផល ដោយមានការចូលរួមនៃមជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតនៃ MRC។ | ទ្វេភាគីនិង ជាតិ | | | | | | ១៥០.000 | ២០.000 | ៣០.000 | ២00.000 |
| | | ជាតុចេញ ៥.៣.២៖ អភិវឌ្ឍសមត្ថភាពនៅថ្នាក់តំបន់ និងថ្នាក់ជាតិ សម្រាប់ការបង្កើតម៉ូដែលគ្រោះរាំងស្ងួត ការបកស្រាយ និងការប្រាស្រ័យទាក់ទងលទ្ធផល ដោយមានការចូលរួមនៃមជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតនៃ MRC។ | ទ្វេភាគីនិង ជាតិ | | | | | | ១៥០.000 | ២០.000 | ៣០.000 | ២00.000 |
| | | | | សរុបរង ដុល្លាអាមេរិក | | | | | ១៥.៧៣0.000 | ៦.៣៦៤.000 | ៦.៨០៤.០០០ | |
| | | | | សរុប ដុល្លាអាមេរិក | | | | | ២៨.៨៩៨.000 | | | |

## តារាងទី ៣៖ តារាងលម្អិតភិភាគទានថវិកាជាតិ និងអន្តរជាតិ

| អាទិភាព យុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | ថវិកា – ២០២២-២០២៦ (ដុល្លាអាមេរិក) | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | អន្តរជាតិ | | | | | ថវិកាជាតិ កម្ពុជា | | | | | ថវិកាជាតិ ថៃ | | | | | សរុប |
| | | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | |
| អាទិភាព ១៖ ពិនិត្យ ធ្វើបច្ចុប្បន្នភាព និងអនុវត្តផែនការមេអាងទន្លេ 9C-9T | លទ្ធផល ១ ១៖. បានបន្សុីក្របខ័ណ្ឌច្បាប់ និងការអនុវត្តសម្រាប់គ្រប់គ្រងធនធានទឹកឆ្លងដែន ដើម្បីគាំទ្រភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត | ធាតុចេញ ១.១.១៖ ពិនិត្យ និងធ្វើបច្ចុប្បន្នភាពផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួត 9C-9T ដែលជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍ជាតិ និងវដ្តថវិការយៈពេលប្រាំឆ្នាំដែលមានស្រាប់។ | | | | | ២០០.០០០ | | | | | ២០.០០០ | | | | | ៥០.០០០ | ២៧០.០០០ |
| | | ធាតុចេញ ១.១.២៖ ពិនិត្យនិងកែសម្រួលឡើងវិញនូវក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលសម្រាប់ការរៀបចំផែនការអាងទន្លេនៅក្នុងប្រទេសទាំងពីរ ដើម្បីឱ្យមានសង្គតិភាពនឹងគ្នាដែលរួមទាំង លក្ខខណ្ឌតម្រូវ សម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រដែលជាផ្នែកមួយនៃការរៀបចំផែនការ។ | | ៣០.០០០ | ៣០.០០០ | | | | ១០.០០០ | ១០.០០០ | | | | ១០.០០០ | ១០.០០០ | | | ១០០.០០០ |
| | | ធាតុចេញ ១.១.៣៖ ពិនិត្យនិងកែសម្រួលឡើងវិញនូវក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលសម្រាប់ការរៀបចំផែនការរូបវន្ត និងការកំណត់តំបន់គ្រប់គ្រង ដោយមានប្រព័ន្ធការពារ នៅក្នុងទីជម្រាលទាំងមូល និងធានាឱ្យមានឧបករណ៍ និងសមត្ថភាពពាក់ព័ន្ធនៅនឹងកន្លែង។ | | ៣០.០០០ | ៣០.០០០ | | | | ១០.០០០ | ១០.០០០ | | | | ១០.០០០ | ១០.០០០ | | | ១០០.០០០ |
| | | ធាតុចេញ ១.១.៤៖ ពិនិត្យ និងកែសម្រួលក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលសម្រាប់ប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធានាឱ្យមានការវាយតម្លៃផលប៉ះពាល់បណ្ដុំនៃអភិវឌ្ឍន៍ជាច្រើន (ខ្នាតតូច និងធំ) នៅក្នុងទីជម្រាលជាមួយគ្នា។ | | ៣០.០០០ | ៣០.០០០ | | | | ១០.០០០ | ១០.០០០ | | | | ១០.០០០ | ១០.០០០ | | | ១០០.០០០ |
| | លទ្ធផល ១.២ ៖ បានពង្រឹងយន្តការដើម្បីកែលម្អ | ធាតុចេញ ១.២.១៖ អនុវត្តការវាយតម្លៃភាពងាយរងគ្រោះចំពោះមុខការប្រែប្រួលអាកាសធាតុនៃអាងទន្លេ 9C-9T ឆ្លងដែន និងការរៀបចំផែនការបន្សុាំ សម្រាប់ជាធាតុបញ្ចូលទៅ | | ៦០.០០០ | | | | | ២០.០០០ | | | | | ៥០.០០០ | | | | ១៣០.០០០ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | ថវិកា – ២០២២-២០២៦ (ដុល្លាអាមេរិក) | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | អន្តរជាតិ | | | | | ថវិកាជាតិ កម្ពុជា | | | | | ថវិកាជាតិ ថៃ | | | | | សរុប |
| | | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | |
| | ផែនការ IWRM និងការគ្រប់គ្រងចម្រុះអាងទន្លេសម្រាប់ទឹកជំនន់ និងគ្រោះរាំងស្ងួត | ក្នុងដំណើរការរៀបចំផែនការ និងក្នុងផែនការអាងទន្លេ | | | | | | | | | | | | | | | | |
| | | ធាតុចេញ ១.២.២៖ បង្កើតគណៈកម្មាធិការអាងទន្លេ 9C កម្ពុជា ដើម្បីបង្កើនការចូលរួមអន្តរវិស័យ និងសហគមន៍ក្នុងការគ្រប់គ្រងអាងទន្លេដោយផ្អែកលើរចនាសម្ព័ន្ធស្ថាប័នអន្តរវិស័យ 9C-9T ដែលមានស្រាប់ សម្រាប់កិច្ចសហប្រតិបត្តិការឆ្លងដែន។ | ២០.០០០ | ២០.០០០ | ២០.០០០ | | | | ១៦.៥០០ | ១៦.៥០០ | ១៧.០០០ | | - | | | | | ១១០.០០០ |
| | | ធាតុចេញ ១.២.៣៖ អនុវត្តការវាយតម្លៃ SEA ឆ្លងដែននៃផែនការសកម្មភាពអាង 9C-9T និងកំណត់តំបន់គ្រប់គ្រងទៅតាមគុណតម្លៃនៃការអភិរក្ស និងការប្រើប្រាស់ ដោយផ្សារភ្ជាប់ជាមួយគោលការណ៍ណែនាំសម្រាប់ការស្តារ និងការគ្រប់គ្រងតំបន់ទាំងនោះ និងកំណែទម្រង់គោលនយោបាយ និងស្ថាប័នដែលពាក់ព័ន្ធ។ | | | ១០០.០០០ | ១០០.០០០ | | | | ១០.០០០ | ១០.០០០ | | | | ២៥.០០០ | ២៥.០០០ | | ២៧០.០០០ |
| | | ធាតុចេញ ១.២.៤៖ អនុវត្តការវាយតម្លៃផលប៉ះពាល់បណ្តុំទូលំទូលាយ និងដោយតម្លាភាពលើហេដ្ឋារចនាសម្ព័ន្ធដែលបានគ្រោងសម្រាប់អាង 9C-9T ដូចជា ទំនប់ស្ទាក់ទឹក ស្រះអណ្តូង អាងស្តុកទឹក និងទំនប់ទឹក និងប្រព័ន្ធស្រោចស្រព ដែលរួមទាំង ប្រព័ន្ធស្ថានីយ៍បូមទឹក (ឧទាហរណ៍ ហេដ្ឋារចនាសម្ព័ន្ធដែលមានចុះក្នុងបញ្ជីនៅក្នុងផែនការមេធនធានទឹកជាតិនៃប្រទេសថៃ និងផែនការមេអភិវឌ្ឍន៍វិស័យនៃក្រសួងធនធានទឹក និងឧតុនិយម) | | ១៥.០០០ | ១៥.០០០ | | | | ៧៥.០០០ | ៧៥.០០០ | | | | ១០០.០០០ | ១០០.០០០ | | | ៣៨០.០០០ |
| | | ធាតុចេញ ១.២.៥៖ រៀបចំ និងអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពយេនឌ័រ និងសហគមន៍ងាយរងគ្រោះសម្រាប់ការបញ្ជ្រាបនៅក្នុង | ១៥.០០០ | ១៥.០០០ | | | | | ១០.០០០ | ១០.០០០ | | | | ១០.០០០ | ១០.០០០ | | | ៧០.០០០ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | ថវិកា – ២០២២-២០២៦ (ដុល្លាអាមេរិក) | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | អន្តរជាតិ | | | | | ថវិកាជាតិ កម្ពុជា | | | | | ថវិកាជាតិ ថៃ | | | | | សរុប |
| | លទ្ធផល ៥.២ ៖ បានពង្រឹងសមត្ថភាពសម្រាប់ការរៀបចំផែនការអាងទន្លេ និងការគ្រប់គ្រងអាងទន្លេឆ្លងដែន | កម្មវិធីបណ្តុះបណ្តាលមួយសម្រាប់មន្ត្រីជាន់ខ្ពស់ ត្រូវបានរៀបចំ និងអនុវត្ត (វិស័យសាធារណៈ និងឯកជន) សម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនៃផែនការអាងទន្លេ | ជាតិ និងមូលដ្ឋាន | | | | | |
| | | វគ្គបណ្តុះបណ្តាលថ្នាក់កណ្តាល/ខេត្តមួយឈុត ត្រូវបានរៀបចំ និងអនុវត្តស្តីពីការវាយតម្លៃភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ និងការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី ដែលជាផ្នែកមួយនៃការកសាងផែនការអាងទន្លេ។ | ជាតិ និងមូលដ្ឋាន | | | | | |
| | | វគ្គបណ្តុះបណ្តាលថ្នាក់កណ្តាល/ខេត្តមួយឈុត ត្រូវបានរៀបចំ និងអនុវត្តអំពីការងារគ្រប់គ្រងទឹកដោយគិតគូរអំពីហានិភ័យអាកាសធាតុ នៅជនបទ និងទីក្រុងជាគោលដៅ។ | ជាតិ និងមូលដ្ឋាន | | | | | |
| | លទ្ធផល ៥.៣ ៖ពង្រឹងសមត្ថភាពធ្វើម៉ូដែលទឹកជំនន់និងគ្រោះរាំង | វគ្គបណ្តុះបណ្តាលប្រចាំឆ្នាំមួយលើក អំពីការបង្កើតម៉ូដែលទឹកជំនន់ ការវិភាគ និងការប្រាស្រ័យទាក់ទង។ | ទ្វេភាគី និងជាតិ | | | | | |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | សូចនាករ | លំដាប់នៃអន្តរាគមន៍ | របាយការណ៍ប្រចាំឆ្នាំ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ |
| | ស្ងួត ការបកស្រាយ និងការប្រាស្រ័យទាក់ទងលទ្ធផល។ | វគ្គបណ្តុះបណ្តាលប្រចាំឆ្នាំមួយលើក អំពីការបង្កើតម៉ូដែលគ្រោះរាំងស្ងួត ការវិភាគ និងការប្រាស្រ័យទាក់ទង។ | ទ្វេភាគី និងជាតិ | | | | | |

### *៤.៧.៥ ហានិភ័យ និងការបន្សាំ*

ប្រទេសទាំងពីរត្រូវប្រកាន់យកអភិក្រមអនុវត្ត និងគ្រប់គ្រងបែបបន្សាំ ដើម្បីធានាថា គោលបំណងនានានៃផែនការមេនេះ នឹងអាចសម្រេចនៅចំពោះមុខមុខសញ្ញាគ្រោះថ្នាក់ និងឧបសគ្គដែលអាចកើតឡើងក្នុងរយៈពេល ២០ឆ្នាំខាងមុខ។ ហានិភ័យដែលអាចពន្យារការអនុវត្តពេញលេញនូវផែនការមេនេះ និងដែលប្រទេសទាំងពីរអាចគ្រប់គ្រងបាន ត្រូវមានដូចខាងក្រោម៖

១. ភាពខ្វះខាត ឬភាពយឺតយ៉ាវក្នុងការប្ដេជ្ញាចិត្តផ្ដល់វិភាគទានពីថវិកាជាតិនៃប្រទេសទាំងពីរ។

២. ខាតខ្វះខាត ឬភាពយឺតយ៉ាវក្នុងការប្ដេជ្ញាចិត្តផ្ដល់ការគាំទ្រពីមូលនិធិអន្តរជាតិ។

៣. ការមិនបានបំពេញតាមពិធីសារចែករំលែកទិន្នន័យឱ្យទាន់ពេលវេលា ដើម្បីជួយសម្រួលដល់ការវាយតម្លៃចម្រុះរួមគ្នា ការកសាងផែនការ និងការប្រកាសផ្ដល់ព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់។

៤. ការចូលរួមនៃវិស័យនានាមិនទាន់ពេលវេលា នៅក្នុងការអនុវត្តផែនការមេដែលមានលក្ខណៈចម្រុះឱ្យបានទូទាំងអាង។

ក្នុងករណីមានឱនភាពថវិកា ឬការពន្យារពេល គេរំពឹងថា MRCS នឹងបន្តគាំទ្រដល់គម្រោងរួមនេះសម្រាប់ការអនុវត្តសមាសធាតុផែនការមេក្នុងកម្រិតទាបមួយ នៅក្នុងដែនកំណត់នៃធនធានដែលមាន។ បន្ទាប់មក ត្រូវមានការស្វែងរកការគាំទ្រថវិកាជាតិ និងជំនួយបច្ចេកទេសឱ្យបានកាន់តែច្រើន ដើម្បីធានាការអនុវត្តប្រកបដោយនិរន្តរភាព។។

## ឧបសម្ព័ន្ធ ១. ការបន្សុីធាតុចេញជាមួយអាទិភាពយុទ្ធសាស្រ្តជាតិរួមទាំងប្រាំមួយ

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃឈើរលិច | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| អាទិភាព ១៖<br>ពិនិត្យ ធ្វើបច្ចុប្បន្នភាព និងអនុវត្តផែនការមេអាងទន្លេ 9C-9T | លទ្ធផល ១.១ ៖<br>បានបន្សុីក្របខ័ណ្ឌច្បាប់ និងការអនុវត្តសម្រាប់គ្រប់គ្រងធនធានទឹកឆ្លងដែន ដើម្បីគាំទ្រភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត | ធាតុចេញ ១.១.១៖ ពិនិត្យ និងធ្វើបច្ចុប្បន្នភាពផែនការមេទឹកជំនន់ និងគ្រោះរាំងស្ងួត 9C-9T ដែលជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍ជាតិ និងវដ្តថវិការយៈពេលប្រាំឆ្នាំដែលមានស្រាប់។ | | | ✓ | | | ✓ |
| | | ធាតុចេញ ១.១.២៖ ពិនិត្យ និងកែសម្រួលឡើងវិញនូវក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលសម្រាប់ការរៀបចំផែនការអាងទន្លេនៅក្នុងប្រទេសទាំងពីរ ដើម្បីឱ្យមានសង្គតិភាពនឹងគ្នា ដែលរួមទាំងលក្ខខណ្ឌតម្រូវ សម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រដែលជាផ្នែកមួយនៃការរៀបចំផែនការ។ | | | ✓ | | ✓ | ✓ |
| | | ធាតុចេញ ១.១.៣៖ ពិនិត្យ និងកែសម្រួលឡើងវិញនូវក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលសម្រាប់ការរៀបចំផែនការរូបវន្ត | | | | | ✓ | ✓ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃឈើរលីង | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | | និងការកំណត់តំបន់គ្រប់គ្រង ដោយមានប្រព័ន្ធការពារ នៅក្នុងទីជម្រាលទាំងមូល និងធានាឱ្យមានឧបករណ៍ និងសមត្ថភាពពាក់ព័ន្ធនៅនឹងកន្លែង។ | | | | | | |
| | | ធាតុចេញ ១.១.៤៖ ពិនិត្យ និងកែសម្រួលក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលសម្រាប់ប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធានាឱ្យមានការវាយតម្លៃហេតុប៉ះពាល់បណ្តុំនៃការអភិវឌ្ឍជាច្រើន (ខ្នាតតូច និងធំ) នៅក្នុងទីជម្រាលជាមួយគ្នា។ | | | | | ✓ | ✓ |
| | លទ្ធផល ១.២ ៖ បានពង្រឹងយន្តការដើម្បីកែលម្អផែនការ | ធាតុចេញ ១.២.១៖ អនុវត្តការវាយតម្លៃភាពងាយរងគ្រោះចំពោះមុខការប្រែប្រួលអាកាសធាតុនៃអាងទន្លេ 9C-9T ឆ្លងដែន និងការរៀបចំផែនការបន្សាំ សម្រាប់ជា | | ✓ | ✓ | | ✓ | |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ជាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | IWRM និងការគ្រប់គ្រងចម្រុះអាងទន្លេ សម្រាប់ទឹកជំនន់ និងគ្រោះរាំងស្ងួត | ជាតុចូលទៅក្នុងដំណើរការរៀបចំផែនការ និងក្នុងផែនការអាងទន្លេ | | | | | | |
| | | ជាតុចេញ ១.២.២៖ បង្កើតគណៈកម្មាធិការអាងទន្លេ 9C កម្ពុជា ដើម្បីបង្កើនការចូលរួមអន្តរវិស័យ និងសហគមន៍ក្នុងការគ្រប់គ្រងអាងទន្លេដោយផ្អែកលើរចនាសម្ព័ន្ធស្ថាប័នអន្តរវិស័យ 9C-9T ដែលមានស្រាប់ សម្រាប់កិច្ចសហប្រតិបត្តិការឆ្លងដែន។ | | | | | | ✓ |
| | | ជាតុចេញ ១.២.៣៖ អនុវត្តការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (SEA) ឆ្លងដែននៃផែនការសកម្មភាពអាង 9C-9T និងកំណត់តំបន់គ្រប់គ្រងទៅតាមគុណតម្លៃនៃការអភិរក្ស និងការប្រើប្រាស់ ដោយផ្សារភ្ជាប់ជាមួយគោលការណ៍ណែនាំសម្រាប់ការស្តារ និងការគ្រប់គ្រងតំបន់ | | | ✓ | ✓ | ✓ | |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | | ទាំងនោះ និងកំណែទម្រង់គោលនយោបាយ និងស្ថាប័នដែលពាក់ព័ន្ធ។ | | | | | | |
| | | ធាតុចេញ ១.២.៤៖ អនុវត្តការវាយតម្លៃហេតុប៉ះពាល់បណ្តុំទូលំទូលាយ និងដោយតម្លាភាពលើហេដ្ឋារចនាសម្ព័ន្ធដែលបានគ្រោងសម្រាប់អាង 9C-9T ដូចជា ទំនប់ស្ទាក់ទឹក ស្រះ អណ្តូង អាងស្តុកទឹក និងទំនប់ទឹក និងប្រព័ន្ធស្រោចស្រព ដែលរួមទាំង ប្រព័ន្ធស្ថានីយ៍បូមទឹក (ឧទាហរណ៍ ហេដ្ឋារចនាសម្ព័ន្ធដែលមានចុះក្នុងបញ្ជីនៅក្នុងផែនការមេធនធានទឹកជាតិនៃប្រទេសថៃ និងផែនការមេអភិវឌ្ឍន៍វិស័យនៃ ក្រសួងធនធានទឹក និងឧតុនិយម) | ✓ | ✓ | ✓ | | | |
| | | ធាតុចេញ ១.២.៥៖ រៀបចំ និងអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពយេនឌ័រ និងសហគមន៍ងាយរងគ្រោះសម្រាប់ | | | ✓ | | | ✓ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | | ការបញ្ជ្រាបទៅក្នុងផែនការ និងវិធានការសម្រាប់វិស័យធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។ | | | | | | |
| | | ធាតុចេញ ១.២.៦៖ ពិនិត្យ រៀបចំ និងអនុម័តផែនការសកម្មភាពសុខុដុម្មនីយកម្មតាមវិស័យ សម្រាប់តំបន់នានាក្នុងអនុអាង 9C និង 9T ដើម្បីកសាងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត (ពោលគឺផែនការរបស់ស្ថាប័នពាក់ព័ន្ធនៃវិស័យនានារបស់រដ្ឋាភិបាលថ្នាក់ជាតិដែលទទួលខុសត្រូវលើវិស័យផ្សេងៗ ដូចជា ការគ្រប់គ្រងទឹក ប្រព័ន្ធធារាសាស្ត្រ ព្រៃឈើ និងកសិកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត និងការគ្រប់គ្រងបរិស្ថាន) | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | ធាតុចេញ ១.២.៧៖ ធ្វើសុខុដុម្មនីយកម្មទម្រង់ប្លង់សម្រាប់ទំនប់ ជាមួយបទ | | ✓ | ✓ | | ✓ | ✓ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | | ប្បញ្ញត្តិ និងគោលការណ៍ណែនាំនានា ដើម្បីធានាឱ្យទទួលបានតុល្យភាពជាផលចំណេញពីស្ថានភាពទីជម្រាល និងជីវចម្រុះ និងការពិចារណាអំពីផលប៉ះពាល់បណ្តុំ។ | | | | | | |
| | លទ្ធផល ១.៣៖ ការផ្តល់ហិរញ្ញប្បទានដោយនិរន្តរភាពសម្រាប់វិធានការបន្សាំតាមប្រព័ន្ធអេកូឡូស៊ីសម្រាប់ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត | ធាតុចេញ ១.៣.១៖ អនុវត្តការវាយតម្លៃសេដ្ឋកិច្ចនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដើម្បីប៉ាន់ប្រមាណអត្ថប្រយោជន៍នៃការបន្សាំនឹងលក្ខខណ្ឌងាយប្រឈមនឹងកត្តាអាកាសធាតុ ការគិតគូរខាងយេនឌ័រ និងដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី សម្រាប់វិធានការធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។ | | | ✓ | | ✓ | ✓ |
| | | ធាតុចេញ ១.៣.២៖ កំណត់ឱកាសដើម្បីចងលក្ខខណ្ឌបង្ការផលប៉ះពាល់សម្រាប់វិធានការកសាងភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតដោយផ្អែកលើប្រព័ន្ធអេ | | | ✓ | | ✓ | ✓ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ជាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | | កូឡូស៊ី ដើម្បីលើកទឹកចិត្តឱ្យមានការ វិនិយោគពីវិស័យឯកជនសម្រាប់ការអនុវត្តផែនការសកម្មភាពអាង 9C-9T។ | | | | | | |
| អាទិភាព ២ . គ្រប់គ្រងទឹកជំនន់ និងគ្រោះ | លទ្ធផល ២.១ ៖ បានពង្រឹងភាពធន់នឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងទីក្រុង តាមរយៈឧបករណ៍ផែនការនវានុវត្តន៍ដែលគិតគូរពីអាកាសធាតុ និងផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងអន្តរាគមន៍បន្សាំ | ជាតុចេញ ២.១.១៖ ធ្វើការវាយតម្លៃភាពងាយរងគ្រោះចំពោះមុខការប្រែប្រួលអាកាសធាតុ និងការរៀបចំផែនការបន្សាំដែលនាំមកនូវផែនការបន្សាំសម្រាប់ទីក្រុងគោលដៅចំនួនពីរ (សងខាងព្រំដែន) | ✓ | | | | ✓ | ✓ |
| | | ជាតុចេញ ២.១.២៖ រៀបចំផែនការគ្រប់គ្រងហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួតនៅមូលដ្ឋាន សម្រាប់តំបន់ទីក្រុងជាគោលដៅចំនួនពីរជាប់ព្រំដែនទាំងសងខាងព្រំដែនកម្ពុជា-ថៃ និងជានា | | | ✓ | | | ✓ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | | ឱ្យមានសង្គតិភាពជាមួយផែនការមេសម្រាប់វិស័យពាក់ព័ន្ធ។ | | | | | | |
| | | ធាតុចេញ ២.១.៣៖ ពិនិត្យ និងកែសម្រួលការកំណត់តំបន់ក្នុងទីក្រុង និងកិច្ចការពារសុវត្ថិភាព និងយន្តការពង្រឹងការអនុវត្ត ដើម្បីបង្កើនភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត ដោយផ្តោតលើផ្លូវទឹកក្នុងទីក្រុង គម្របរុក្ខជាតិក្នុងទីក្រុង និងវិធានការណ៍បៃតង និងការកំណត់ផ្លូវទឹកដែលមានសក្តានុពល និងការកំណត់តំបន់ទឹកជំនន់នៅក្នុងទីក្រុងចំនួនពីរ (មួយនៅក្នុងប្រទេសនីមួយៗ)។[7] | | | ✓ | | ✓ | ✓ |
| | | ធាតុចេញ ២.១.៤៖ អភិវឌ្ឍ និងអនុវត្តហេដ្ឋារចនាសម្ព័ន្ធការពារចម្រុះ (បៃតង | | | ✓ | ✓ | ✓ | |

[7] ត្រូវធ្វើឡើងដោយមានការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយ ADB TA CAM៖ ការគាំទ្របច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំផែនការទីក្រុង - គម្រោងទីប្រឹក្សាអនុវត្ត TA (53199-001)

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | | និងប្រផេះ) ដើម្បីកាត់បន្ថយហានិភ័យទឹកជំនន់ក្នុងទីក្រុង (ដូចជា ការកែលម្អដងស្ទឹងក្នុងទីក្រុង ស្ពៃភាពប្រាំងស្ទឹង និងតំបន់ធម្មជាតិសម្រាប់ស្រូបយកទឹកជំនន់) និងលើកកំពស់គុណភាពទឹកនៅក្នុងទីក្រុងគោលដៅចំនួនពីរ (មួយក្នុងប្រទេសនីមួយៗ)។ | | | | | | |
| | | ធាតុចេញ ២.១.៥៖ បង្កើត និងអនុវត្តវិធានការគ្រប់គ្រងតម្រូវការទឹក ដើម្បីកាត់បន្ថយបរិមាណទឹកដែលប្រើប្រាស់តាមគ្រួសារ វិស័យទីក្រុង និងឧស្សាហកម្ម ដោយផ្តោតលើការកសាងប្រព័ន្ធអេកូឡូស៊ី និងភាពធន់នឹងអាកាសធាតុ។ | | ✓ | ✓ | | | |
| | លទ្ធផល ២.២ ៖ បានពង្រឹងភាពធន់នឹងទឹកជំនន់ និង | ធាតុចេញ ២.២.១៖ បង្កើត និងអនុវត្តវិធានការស្តារទេសភាពជនបទឡើងវិញ ដែលរួមទាំង សកម្មភាពកសិ-រុក្ខកម្ម និងការកែប្រែទម្លាប់អនុវត្តក្នុងកសិកម្ម តាមរ | | ✓ | ✓ | | ✓ | |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | គ្រោះរាំងស្ងួតនៅតាមជនបទ តាមរយៈ ឧបករណ៍កសាងផែនការផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងអន្តរាគមន៍ បន្សាំ | យៈពិពិធកម្មមុខដំណាំ ការប្តូរមុខដំណាំ វិធានការនវានុវត្តក្នុងការស្រោចស្រពដើម្បីសំចៃទឹក និងអនុវត្តអភិក្រមគ្រប់គ្រងតម្រូវការទឹក ការភ្ជួររាស់តិចជាងមុន និងការកែលម្អសមត្ថភាពរក្សាទឹកក្នុងដី និងសម្រូបកាបូន។ | | | | | | |
| | | ធាតុចេញ ២.២.២៖ បង្កើតតំបន់គ្រប់គ្រងរូបវន្ត និងកិច្ចការពារតំបន់ទេសភាពជនបទ ជាពិសេសដែលទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និងថ្មីៗ និងការតម្លើងមធ្យោបាយត្រងយកកំណកល្បាប់ ធ្វើការបូមស្តារដើម្បីរក្សាសមត្ថភាព ការថែទាំដើម្បីទប់ស្កាត់ការទន្ទ្រានយកដីក្នុងអាងទឹកនិងតាមប្រាំងស្ទឹងសម្រាប់ធ្វើកសិកម្ម និងការបង្កើតតំបន់ទ្រនាប់រុក្ខជាតិនៅតាមរបៀងដោះទឹក និងផ្លូវដឹកជញ្ជូន និងនៅ | | ✓ | ✓ | | ✓ | ✓ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃឈើ | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | | តាមកន្លែងដែលបានកំណត់នៅតាមបណ្តោយព្រំដែន។ | | | | | | |
| | | ធាតុចេញ ២.២.៣៖ បង្កើត និងអនុវត្តអន្តរាគមន៍ផ្អែកលើធម្មជាតិនិងចម្រុះយ៉ាងហោចណាស់ប្រាំមួយឈុត (៣ ក្នុងប្រទេសនីមួយៗ) ដើម្បីកាត់បន្ថយហានិភ័យទឹកជំនន់និងគ្រោះរាំងស្ងួតនៅតំបន់ជនបទ ដោយផ្តោតលើដំណោះស្រាយផ្អែកលើធម្មជាតិសម្រាប់ការកែលំអផ្លូវទឹក និងតំបន់ទ្រនាប់រុក្ខជាតិ ការពង្រឹងស្ថេរភាពច្រាំងស្ទឹង និងសម្រាប់ការថែទាំផ្លូវទឹក។ | | | ✓ | | ✓ | |
| | លទ្ធផល ២.៣៖ បានស្តារអាងទន្លេនៅ តំបន់ក្បាលទឹកនិង | ធាតុចេញ ២.៣.១៖ បង្កើត និងអនុវត្តអន្តរាគមន៍យ៉ាងតិចប្រាំមួយ (៣ ក្នុងប្រទេសនីមួយៗ) សម្រាប់ការស្តារឡើងវិញ និងការគ្រប់គ្រងដោយប្រសិទ្ធភាព | | | ✓ | ✓ | ✓ | |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | តំបន់ដីសើមឡើងវិញដើម្បីកែលម្អសន្តិសុខទឹកនិងភាពធន់នឹងអាកាសធាតុ តាមរយៈអន្តរាគមន៍ បន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី | នូវតំបន់ការពារធម្មជាតិ និងទីជម្រាលនៅតំបន់ខ្សែទឹកខាងលើជាប្រភពទឹកនៃអាងទន្លេនេះ - ដើម្បីកែលម្អ និងថែរក្សាសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដោយសង្កត់ធ្ងន់លើកិច្ចការពារជីវចម្រុះដែលមានសារៈសំខាន់ជាអន្តរជាតិនៅតាមព្រំដែន។ | | | | | | |
| | | ធាតុចេញ ២.៣.២៖ បង្កើត និងអនុវត្តអន្តរាគមន៍យ៉ាងហោចណាស់បួន (២ ក្នុងប្រទេសនីមួយៗ) ដើម្បីស្តារ និងគ្រប់គ្រងតំបន់ដីសើមក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាង ដើម្បីពង្រឹងតំបន់ទ្រនាប់នៃ PA និងកែលម្អភាពពេញលេញនៃប្រព័ន្ធអេកូឡូស៊ីសម្រាប់ការផ្តល់សេវាប្រព័ន្ធអេកូឡូស៊ី (ការស្តុកទឹក/ប្រព្រឹត្តកម្មទឹក/ទីជម្រក) | | | ✓ | ✓ | ✓ | |
| | | ធាតុចេញ ២.៣.៣៖ បង្កើនគម្របព្រៃឈើ និងលក្ខខណ្ឌនៅតំបន់ក្បាលទឹក | | | ✓ | | ✓ | |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | | តាមរយៈការដាំដំណាំចម្រុះប្រភេទ ដាំដើមឈើឡើងវិញ និងការស្តារឡើងវិញនូវតំបន់រេចរល ដើម្បីទទួលបានតុល្យភាពជាកំណើនជីវៈចម្រុះ និងការកែលម្អដី និងស្តុកកាបូនព្រៃឈើ ដើម្បីកាត់បន្ថយ និងកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ | | | | | | |
| អាទិភាព ៣ការ . ផ្តោះប្តូរព័ត៌មាន និងចំណេះដឹង | លទ្ធផល ៣.១ ៖ ភាពធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួត និង IWRM ដែលងាយប្រឈមបញ្ហាអាកាសធាតុតាមរយៈការចែករំលែកចំណេះដឹង | ធាតុចេញ ៣.១.១៖ ថែរក្សា និងប្រើប្រាស់សៀវភៅផែនទីជាប្រព័ន្ធគាំទ្រសេចក្តីសម្រេចនៃគម្រោងរួម( DSS )សម្រាប់អាង 9C-9T ដើម្បីជូនដំណឹងដល់ការរៀបចំផែនការ និងការគ្រប់គ្រងអាង និងសម្របសម្រួលការចែករំលែកទិន្នន័យរវាង ONWR និង MOWRAM និងអ្នកពាក់ព័ន្ធផ្សេងទៀត។ | | | | | | ✓ |
| | | ធាតុចេញ ៣.១.២៖ ការអភិវឌ្ឍ និងអនុវត្តប្រព័ន្ធសម្រាប់ប្រាស្រ័យទាក់ទងអន្តរ | | ✓ | ✓ | | | ✓ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ជាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | | កម្មឆ្លងដែនអំពីវត្តមានទឹក និងការសម្របសម្រួលដោយប្រសិទ្ធភាពលើប្រតិបត្តិការអាងស្តុកទឹកដើម្បីសន្តិសុខទឹក។ | | | | | | |
| | | ជាតុចេញ ៣.១.៣៖ បង្កើតប្រព័ន្ធសម្រាប់សហគមន៍រាយការណ៍អំពីទីជម្រាល និងសុខភាពដែនទឹក ជាធាតុចូលដ៏សំខាន់ សម្រាប់ការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងអាង 9C-9T ដែលរួមទាំង ការគាំទ្រនៅថ្នាក់មូលដ្ឋាន ក្នុងការត្រួតពិនិត្យបន្ត ការប្រមូលទិន្នន័យ និងការរៀបចំ របាយការណ៍ តារាងវាយតម្លៃសុខភាពប្រព័ន្ធអេកូឡូស៊ី រួមទាំង ការធ្វើផែនទីអំពីមុខសញ្ញាគ្រោះថ្នាក់ និងការវិភាគអំពីការឆ្លើយតប ដោយសហគមន៍។ | | | | ✓ | ✓ | ✓ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | លទ្ធផល ៣.២ ៖ ពង្រីកការអនុវត្តល្អ និងចែករំលែកមេរៀន ដែលបានពីគម្រោងរួម 9C-9T ក្នុងអាងទន្លេមេគង្គក្រោម | ធាតុចេញ ៣.២.១៖ ពង្រីកការអនុវត្តការងារត្រួតពិនិត្យនិងតាមដាន( M&E) និងវិធានការធន់នឹងទឹកជំនន់ និងគ្រោះរាំងស្ងួតឆ្លងដែន នៅទូទាំងតំបន់មេគង្គ តាមរយៈការចែករំលែកមេរៀនពីគម្រោងដែលបានអនុវត្តនៅកម្ពុជា ថៃ និងតាមរយៈយន្តការការផ្តោះប្តូរត្បូង-ត្បូង។[8] | | | ✓ | | | ✓ |
| | | ធាតុចេញ ៣.២.២៖ បង្កើត និងអនុវត្តយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ដើម្បីចែករំលែកចំណេះដឹង និងមេរៀនពីគម្រោង | | | | | | ✓ |
| អាទិភាព ៤ . ពង្រឹងបណ្តាញជលសាស្ត្រ-ឧតុ | លទ្ធផល ៤.១ ៖បាន ពង្រឹងពិធីសារត្រួតពិនិត្យរួមគ្នា និងការ | ធាតុចេញ ៤.១.១៖ ពិនិត្យ ធ្វើបច្ចុប្បន្នភាព និងពង្រីកបណ្តាញ ឧបករណ៍ និងប្រព័ន្ធត្រួតពិនិត្យរួមគ្នាលើ កម្រិតកំពស់ | | | ✓ | | | ✓ |

[8] ដែលគ្របដណ្តប់៖ i) ការកសាងផែនការ និងការគ្រប់គ្រងអាងទន្លេរួមគ្នា; ii) ការចាត់ចែងប្រកាសផ្តល់ព័ត៌មានអំពីទឹកជំនន់ និងគ្រោះរាំងស្ងួត; និង iii) ការអនុវត្តវិធីសាស្ត្រ និងឧបករណ៍សម្រាប់ EbA ដែលរួមទាំង ការគាំទ្រសម្រាប់ការបង្កើតកិច្ចសហការដើម្បីពង្រីកបទពិសោធន៍នៃ 9C-9T នៅក្នុងអនុអាងទន្លេរួមគ្នាដទៃទៀតនៃតំបន់មេគង្គ។

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| និយម និងការប្រកាសផ្តល់ព័ត៌មានជាមុនអំពីទឹកជំនន់និងគ្រោះរាំងស្ងួត | ប្រកាសផ្តល់ព័ត៌មានជាមុនអំពីជលសាស្ត្រដើម្បីកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ និងគ្រោះរាំងស្ងួត | ទឹកស្ទឹង និងជំនន់តំហុក ដែលរួមទាំងការផ្ទៀងផ្ទាត់ទិន្នន័យពីស្ថានីយ ជាមួយម៉ូដែលអ៊ីដ្រូលិក ការសម្របសម្រួល និងពិធីសារហានិភ័យគ្រោះមហន្តរាយ ដើម្បីបង្កើនប្រសិទ្ធភាព និងការចែករំលែកទិន្នន័យសម្រាប់ការត្រួតពិនិត្យ និង ការប្រកាសផ្តល់ព័ត៌មានជាមុន។ | | | | | | |
| | | ធាតុចេញ ៤.១.២៖ បង្កើតយន្តការរួមគ្នាសម្រាប់ការផ្លោះប្តូរទិន្នន័យត្រួតពិនិត្យជលសាស្ត្រតាមពេលវេលាជាក់ស្តែង និងការប្រកាសផ្តល់ព័ត៌មានជាមុន (ថ្នាក់ជាតិ ខេត្ត និងមូលដ្ឋាននៅតាមសហគមន៍គោលដៅ)។ | ✓ | | ✓ | | | ✓ |
| | | ធាតុចេញ ៤.១.៣៖ ពង្រឹង ពង្រីកឧបករណ៍ប្រាស្រ័យទាក់ទង និងឧបករណ៍គ្រប់គ្រងចំណេះដឹង និងបច្ចេកវិទ្យាដែលមានស្រាប់ សម្រាប់ការប្រកាស | | | ✓ | | | ✓ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ជាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | | ផ្តល់ព័ត៌មានជាមុន ដើម្បីបង្កើនភាពធន់នឹងទឹកជំនន់ នៃសហគមន៍ទីក្រុង។ | | | | | | |
| | | ជាតុចេញ ៤.១.៤៖ ពិនិត្យ ធ្វើបច្ចុប្បន្នភាព និងពង្រីកបណ្តាញ ឧបករណ៍ និងប្រព័ន្ធត្រួតពិនិត្យរួមគ្នា សម្រាប់គ្រោះរាំងស្ងួត រួមទាំង ការព្យាករណ៍តាមរដូវ និងការកំណត់ស្ថានភាព សម្រាប់ការប្រកាសផ្តល់ព័ត៌មានជាមុនអំពីគ្រោះរាំងស្ងួត ដើម្បីកែលម្អប្រសិទ្ធភាព និងការចែករំលែកទិន្នន័យសម្រាប់ការត្រួតពិនិត្យ និងការប្រកាសផ្តល់ព័ត៌មានជាមុន។ | | | ✓ | | | ✓ |
| | | ជាតុចេញ ៤.១.៥៖ បង្កើតនីតិវិធី និងសមត្ថភាពសម្រាប់ការបញ្ចូលជាប្រចាំនូវទិន្នន័យពីផ្កាយរណបទៅក្នុងការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត។ | | | ✓ | | | ✓ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| អាទិភាព ៥ . កសាងសមត្ថភាពក្នុងតំបន់ | លទ្ធផល ៥.១ ៖ បានពង្រឹងសមត្ថភាពសម្រាប់ការស្តារ និងថែទាំអាង តាមរយៈវិធានការណ៍ផ្អែកលើធម្មជាតិនិងចម្រុះ | ធាតុចេញ ៥.១.១៖ ផ្តល់ការបណ្តុះបណ្តាលពិស្តារដែលផ្អែកលើការងារតាមភូមិសាស្ត្រ សម្រាប់វិស្វករ អ្នកគ្រប់គ្រងព្រៃឈើ អ្នកគ្រប់គ្រងទីជម្រាល និងអ្នកឯកទេសដទៃទៀត អំពីវិធានការផ្អែកលើធម្មជាតិ និងចម្រុះ សម្រាប់គ្រប់អន្តរាគមន៍ខាងផ្នែកទឹកជំនន់ និងគ្រោះរាំងស្ងួត។ | | | ✓ | | ✓ | |
| | | ធាតុចេញ ៥.១.២៖ រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាល ដើម្បីកសាងសមត្ថភាពនៃវិស័យនៅតាមមូលដ្ឋាន និងអង្គការអាងទន្លេ សម្រាប់ការរចនាប្លង់លម្អិត ការអនុវត្ត និងការគ្រប់គ្រងវិធានការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់គោលដៅ។ | | ✓ | ✓ | | ✓ | |
| | លទ្ធផល ៥.២ ៖ | ធាតុចេញ ៥.២.១៖ រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលសម្រាប់បុគ្គលិក | | ✓ | ✓ | | ✓ | ✓ |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃឈើរលី | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | បានពង្រឹងសមត្ថភាពសម្រាប់ការរៀបចំផែនការអាងទន្លេ និងការគ្រប់គ្រងអាងទន្លេឆ្លងដែន | ជាន់ខ្ពស់ក្នុងវិស័យសាធារណៈនិងឯកជន ដែលរួមទាំងអំពី SEA នៃផែនការគ្រប់គ្រងអាងទន្លេ ការវាយតម្លៃសេដ្ឋកិច្ចនៃការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងគាំទ្រយន្តការហិរញ្ញវត្ថុ និងការវាយតម្លៃផលប៉ះពាល់បណ្តុំ នៃការអភិវឌ្ឍន៍ដែលមានស្រាប់ និងដែលបានគ្រោងទុក សម្រាប់ទីជម្រាល។ | | | | | | |
| | | ធាតុចេញ ៥.២.២៖ រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលនៅថ្នាក់កណ្តាល និងខេត្ត សម្រាប់ការវាយតម្លៃភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ និងផែនការបន្សាំតាមប្រព័ន្ធអេកូឡូស៊ី ដែលជាផ្នែកមួយនៃការកសាងផែនការអាងទន្លេ។ | | | ✓ | | ✓ | |
| | | ធាតុចេញ ៥.២.៣៖ រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់កណ្តាល និង | | | ✓ | | ✓ | |

| អាទិភាពយុទ្ធសាស្ត្រ | លទ្ធផល | ធាតុចេញ | អាទិភាពយុទ្ធសាស្ត្រជាតិរួមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា និងថៃ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ១. ការគ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ | ២. កសាងសន្តិសុខទឹកក្នុងកសិកម្ម និងឧស្សាហកម្ម | ៣. ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត | ៤. ការគ្រប់គ្រងគុណភាពទឹក និងអភិរក្សធនធានទឹក | ៥. ការស្តារទីជម្រាល និងព្រៃរេចរឹល | ៦. កសាងការគ្រប់គ្រង រដ្ឋបាល និងប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាព |
| | | ខេត្ត សម្រាប់អនុវត្តការងារគ្រប់គ្រងទឹក ដោយយល់ដឹងពីហានិភ័យអាកាសធាតុ ក្នុងតំបន់ទីក្រុងនិងជនបទជាគោលដៅ។ | | | | | | |
| | លទ្ធផល ៥.៣ ៖បាន ពង្រឹងសមត្ថភាពធ្វើម៉ូដែលទឹកជំនន់និងគ្រោះរាំងស្ងួត ការបកស្រាយ និងការប្រាស្រ័យទាក់ទងលទ្ធផល។ | ធាតុចេញ ៥.៣.១៖ អភិវឌ្ឍសមត្ថភាពនៅថ្នាក់តំបន់ និងថ្នាក់ជាតិសម្រាប់ការបង្កើតម៉ូដែលទឹកជំនន់ ការបកស្រាយ និងការប្រាស្រ័យទាក់ទងលទ្ធផល ដោយមានការចូលរួមនៃមជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតនៃ MRC។ | | | ✓ | | | ✓ |
| | | ធាតុចេញ ៥.៣.២៖ អភិវឌ្ឍសមត្ថភាពនៅថ្នាក់តំបន់ និងថ្នាក់ជាតិ សម្រាប់ការបង្កើតម៉ូដែលគ្រោះរាំងស្ងួត ការបកស្រាយ និងការប្រាស្រ័យទាក់ទងលទ្ធផល ដោយមានការចូលរួមនៃមជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតនៃ MRC។ | | | ✓ | | | ✓ |

## ឧបសម្ព័ន្ធ ២ .អត្តសញ្ញាណកម្មទីជម្រាល និងចំណាត់ថ្នាក់

ដើម្បីកំណត់តំបន់ក្ដៅសម្រាប់ជាអាទិភាពនៃការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតក្នុងអាង 9C-9T អាងនេះត្រូវបានបែងចែកទៅជាអាងតូចៗ ដែលនីមួយៗមានលក្ខណៈជីវរូបវិទ្យា និងសេដ្ឋកិច្ចសង្គមខុសៗគ្នា។ ឈ្មោះនីមួយៗនៃអនុអាងទាំង ១៨ ចាប់ផ្ដើមដោយអក្សរ "S" សម្រាប់ "អនុអាង" បន្តដោយលេខចំនួនបួនខ្ទង់ ដែលតំណាងឱ្យទំហំអនុអាងដែលគិតជាគីឡូម៉ែត្រការ៉េ។

## វិធីសាស្ត្រកំណត់អាង

ជាដំបូង យើងប្រើប្រាស់ DEM ទាន់សម័យ និងត្រឹមត្រូវបំផុត និងច្រឹបយកតែវិសាលភាពអាង 9C-9T ជាធាតុចូលសម្រាប់ការកំណត់ព្រំដែននៃអាងដោយប្រើកម្មវិធី ArcSWAT។ វិធីសាស្ត្រកំណត់ផ្លូវ D8 ត្រូវបានយកមកអនុវត្ត ដើម្បីកំណត់ពីរបៀបដែលផ្ទៃទឹក នៅក្នុងក្រឡាមួយនៅលើផែនទី នឹងត្រូវបានបញ្ជូនទៅកាន់ក្រឡាមួយ ក្នុងចំណោមក្រឡានៅជុំវិញចំនួន ៨ ដែលអនុញ្ញាតឱ្យបង្កើតជាកម្រងទិន្នន័យមួយស្ដីពីទិសដៅលំហូរ និងការប្រមូលផ្ដុំទឹក។ តាមរយៈការកំណត់ចំនួនក្រឡាដែលប្រមូលផ្ដុំ ដើម្បីបង្កើតជាចរន្តទឹកស្ទឹង បណ្ដាញចរន្តទឹកស្ទឹងនានាត្រូវបានបង្កើតឡើង និងកំណត់នៅត្រង់ចំណុចប្រសព្វនៃស្ទឹងទាំងនោះ និងនៅត្រង់ច្រកចេញសំខាន់ (ស្ទឹងដែលហូរចេញពីតំបន់ DEM)។ បន្ទាប់មក ត្រូវធ្វើការកែសម្រួលដោយដៃ ចំពោះច្រកចេញនានាម្ដងមួយៗ ដើម្បីបានអនុអាងក្នុងចំនួនតាមការចង់បាន សម្រាប់គោលបំណងនៃការរៀបចំផែនការ និងការគ្រប់គ្រង។ ច្រកចេញទាំងនេះ ត្រូវបានកំណត់នៅត្រង់ច្រកចេញធំៗ ទីតាំងស្ថានីយ៍ជលសាស្ត្រ ចំណុចប្រសព្វ ឬប្រឡាយជារាសាស្ត្រមេធំៗ។ ច្រកចេញខ្លះ ត្រូវបានដាក់នៅតាមព្រំដែនថៃ-កម្ពុជា សម្រាប់អនុអាងថៃ។ នៅទីបំផុត អនុអាងចំនួន ១៨ ត្រូវបានកំណត់ តាមរយៈច្រកចេញដែលជ្រើសយក (រូបភាពទី ១១)។ ឈ្មោះអនុអាងនីមួយៗ ចាប់ផ្ដើមដោយអក្សរ "S" អមដោយលេខចំនួន ៤ខ្ទង់ ដែលតំណាងឱ្យទំហំអនុអាងនោះ គិតជាគីឡូម៉ែត្រការ៉េ។

*រូបភាពទី ១១. អនុអាង នៅក្នុងអាង 9C-9T ។*



## ការវិភាគពហុលក្ខណៈវិនិច្ឆ័យ

រូបភាពទី ១២ បង្ហាញពីដំណើរការ MCA ដែលបានអនុវត្តសម្រាប់ចាត់ថ្នាក់អនុអាង យោងតាមភាពបន្ទាន់សម្រាប់ការគ្រប់គ្រង និងការវិនិយោគទាក់ទងនឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។

*រូបភាពទី ១២. ដំណើរការចាត់ថ្នាក់រួម ដែលនាំទៅដល់ការកំណត់អត្តសញ្ញាណកន្លែងអនុវត្ត*




## លក្ខណៈវិនិច្ឆ័យ និងការជ្រើសរើស

ប៉ារ៉ាម៉ែត្រជាច្រើនមានសារៈសំខាន់ សម្រាប់ដំណើរការចំណាត់ថ្នាក់អនុអាង។ ដូច្នេះ សន្ទស្សន៍សំខាន់ៗចំនួនប្រាំ ដែលបង្កើតឡើងដោយប៉ារ៉ាម៉ែត្រពាក់ព័ន្ធជាច្រើន ត្រូវបានកំណត់ដូចខាងក្រោម៖

១. **ហានិភ័យគ្រោះរាំងស្ងួត៖** ពិន្ទុរួមមួយ ដែលផ្អែកលើសំណុំលក្ខណៈនៃដី និងទឹកនៅក្នុងអនុអាង (វត្តមានទឹក សរុប វត្តមានគម្របរុក្ខជាតិ កម្រិតជម្រាបចេញ កម្រិតរំហួតរំភាយចំហាយទឹក) ភស្តុតាងនៃបាតុភូត និងនិន្នាការគ្រោះរាំងស្ងួតកន្លងមក និងកម្រិតកំពស់ទឹកភ្លៀងដែលបាននិទស្សន៍សម្រាប់រដូវប្រាំង។

២. **ហានិភ័យទឹកជំនន់៖** ពិន្ទុរួមមួយ ដែលផ្អែកលើជម្រៅទឹកជំនន់ជាមធ្យម ផ្ទៃដីជន់លិច និងភស្តុតាងនៃជំនន់គំហុកកន្លងមក។

៣. **ហានិភ័យនៃសំណឹកដី៖** ពិន្ទុរួមមួយ ដែលផ្អែកលើការបាត់បង់ដីដោយសារសំណឹកកន្លងមក និងចំណេះដឹងនៅមូលដ្ឋានអំពីសំណឹកដី។

៤. **ហានិភ័យនៃការបាត់បង់ជីវចម្រុះនិងព្រៃឈើ៖** ពិន្ទុរួមមួយ ដែលផ្អែកលើវិសាលភាពនៃព្រៃឈើ ការបាត់បង់ព្រៃឈើនាពេលថ្មីៗនេះ និងសារៈសំខាន់នៃជីវចម្រុះ (ពោលគឺ តំបន់ការពារធម្មជាតិ តំបន់ប្រើប្រាស់ច្រើនយ៉ាង)។

៥. **សារៈសំខាន់ខាងសេដ្ឋកិច្ចសង្គម៖** ពិន្ទុរួមមួយ ដែលផ្អែកលើដង់ស៊ីតេប្រជាជននិងសារៈសំខាន់ខាងសេដ្ឋកិច្ចនៃតំបន់នោះ។

ការដាក់ពិន្ទុអនុអាងសម្រាប់សន្ទស្សន៍នីមួយៗ បានផ្អែកលើហានិភ័យ ចាប់ពីកម្រិតទាប (១) ដល់ខ្ពស់បំផុត (៥)។

*រូបភាពទី ១៣. ការដាក់ពិន្ទុហានិភ័យគ្រោះរាំងស្ងួតតាមអនុអាង*




*រូបភាពទី ១៤. ការដាក់ពិន្ទុហានិភ័យទឹកជំនន់ តាមអនុអាង*



*រូបភាពទី ១៥. ការដាក់ពិន្ទុហានិភ័យសំណឹកដី តាមអនុអាង*




*រូបភាពទី ១៦. ការដាក់ពិន្ទុហានិភ័យបាត់បង់ជីវៈចម្រុះ និងព្រៃឈើ តាមអនុអាង*



*រូបភាពទី ១៧. ការដាក់ពិន្ទុលើសារៈសំខាន់ខាងសេដ្ឋកិច្ចសង្គម តាមអនុអាង*




# ចំណាត់ថ្នាក់រួមនៃអាង

អនុអាង ត្រូវបានចាត់ថ្នាក់ដោយការគណនាផលបូកនៃពិន្ទុសម្រាប់ប៉ារ៉ាម៉ែត្រ ឬសន្ទស្សន៍ផ្សំទាំងប្រាំ។ ផ្អែកលើលទ្ធផលនេះ អនុអាងចំនួន ១១ ក្នុងចំណោម ១៨ ដែលមានចំណាត់ថ្នាក់ខ្ពស់បំផុត ត្រូវបានកំណត់ជាអាទិភាពសម្រាប់ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត (រូបភាពទី ១៨ និងតារាងទី ៧)។ អនុអាងដែលមានចំណាត់ថ្នាក់ខ្ពស់គឺ S1344, S1443, S2536, S0810, S0624, S0517, S0583, S0908, S0326, S0722, S1017។

ភាគច្រើននៃអនុអាងទាំងនេះ ត្រូវបានកំណត់ថា ជាតំបន់ក្តៅនៃទឹកជំនន់ ឬគ្រោះរាំងស្ងួត ពោលគឺ តំបន់ដែលជួបប្រទះនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរនិងជាញឹកញាប់។ ទោះយ៉ាងណាក៏ដោយ អនុអាងខ្លះស្ថិតនៅតំបន់ខ្សែទឹកខាងលើ និងជាតំបន់ក្បាលទឹក ដែលស្ថានភាពព្រៃឈើរេចរិល កំពុងបង្កើតបញ្ហាទឹកជំនន់ និងគ្រោះរាំងស្ងួតនៅតំបន់ខ្សែទឹកខាងក្រោម។ ការគ្រប់គ្រងតំបន់ទាំងនេះដោយប្រសិទ្ធភាព មានតួនាទីយ៉ាងសំខាន់ក្នុងការបន្ធូរបន្ថយវិសាលភាព និងភាពធ្ងន់ធ្ងរនៃទឹកជំនន់ និងគ្រោះរាំងស្ងួត នៅទូទាំងអាង 9C-9T ។

ឧទាហរណ៍ អនុអាង S0810 មានតំបន់ក្បាលទឹកស្ថិតនៅក្នុងឧទ្យានជាតិតាប្រាយ៉ា នៅចុងខាងកើតនៃជួរភ្នំ Sankamphaeng ដែលតភ្ជាប់មកជួរភ្នំដងរែក ជិតព្រំដែនកម្ពុជា-ថៃ។ អាងនេះ ជួបបញ្ហាសំណឹក និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ ដែលផ្នែកខ្លះនៃបញ្ហាទាំងនេះមានប្រភពដើមនៅក្នុងតំបន់ការពារធម្មជាតិ និងតំបន់ទ្រនាប់ដែលគ្មានគម្របរុក្ខជាតិ។ មួយផ្នែកនៃ S0326 គ្របដណ្តប់តំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត (កម្ពុជា) និងតំបន់ទ្រនាប់នៃ ឧទ្យានជាតិ Khlong Kreua

Wai Chaleum (ប្រទេសថៃ)។ ព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិទាំងនោះ កំពុងរេចរិល ដោយបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់តំបន់ខ្សែទឹកខាងក្រោម។ ព្រៃឈើនៅក្នុងអនុអាង S0722 ក៏រងការរំខានយ៉ាងខ្លាំងផងដែរ ដែលភាគច្រើនត្រូវបានបំប្លែងពីព្រៃឈើទៅជាដីកសិកម្ម ហើយបច្ចុប្បន្នកំពុងប្រឈមបញ្ហាទឹកជំនន់ និងគ្រោះរាំងស្ងួត។ អនុអាង S0517 ក៏ជាប្រភពទឹកដ៏សំខាន់សម្រាប់ការប្រើប្រាស់ និងលក្ខខណ្ឌនៃទឹកនៅតំបន់ខ្សែទឹកខាងក្រោមផងដែរ។ ការបំប្លែងព្រៃឈើភាគច្រើននៅក្នុងតំបន់នេះទៅជាដីកសិកម្ម នាំឱ្យព្រៃឈើដាច់ចេញពីគ្នាដោយដុំ និងបាត់បង់សេវាកម្មប្រព័ន្ធអេកូឡូស៊ី។

ការជ្រើសរើសទីតាំងភូមិសាស្ត្រ ដើម្បីបង្កើតបណ្តាញនៃគម្រោងបង្ហាញអំពីការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតដោយប្រសិទ្ធភាព ត្រូវរួមបញ្ចូលតំបន់ខ្សែទឹកខាងលើ ក៏ដូចជា ខាងក្រោម ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយទឹកជំនន់ និងគ្រោះរាំងស្ងួតផងដែរ។

តារាងទី ៧ម៉ាទ្រីសពិន្ទុ .សម្រាប់អនុអាង អនុ)អាងដែលមានអាទិភាពខ្ពស់សម្រាប់ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតត្រូវបានរំលេចជាពណ៌បៃតង(

| លេខសំគាល់អាង | ពិន្ទុហានិភ័យគ្រោះរាំងស្ងួត | ពិន្ទុហានិភ័យទឹកជំនន់ | ពិន្ទុហានិភ័យសំណឹកដី | ពិន្ទុការអភិរក្សជីវចម្រុះ | ពិន្ទុសេដ្ឋកិច្ចសង្គម | ពិន្ទុសរុប | ចំណាត់ថ្នាក់ |
|---|---|---|---|---|---|---|---|
| **S1344** | ៤ | ៥ | ៤ | ៣ | ៥ | ២១ | ១ |
| **S0810** | ៥ | ៣ | ៥ | ៤ | ៣ | ២០ | ២ |
| **S1443** | ៤ | ៣ | ៤ | ៣ | ៥ | ១៩ | ៣ |
| **S2536** | ៥ | ៥ | ១ | ៤ | ៤ | ១៩ | ៣ |
| **S0624** | ៥ | ៣ | ២ | ២ | ៥ | ១៧ | ៥ |
| **S0517** | ៤ | ១ | ៣ | ៥ | ៣ | ១៦ | ៦ |
| **S0583** | ៥ | ៣ | ៤ | ២ | ២ | ១៦ | ៦ |
| **S0908** | ៤ | ៣ | ៤ | ៣ | ២ | ១៦ | ៦ |
| **S0326** | ២ | ១ | ៣ | ៥ | ៤ | ១៥ | ៩ |
| **S0722** | ៤ | ១ | ៥ | ៣ | ២ | ១៥ | ៩ |
| **S1017** | ៥ | ២ | ៣ | ៤ | ១ | ១៥ | ៩ |
| **S0576** | ៤ | ១ | ២ | ៤ | ៣ | ១៤ | ១២ |
| **S0340** | ៤ | ៣ | ៣ | ១ | ២ | ១៣ | ១៣ |
| **S0569** | ២ | ១ | ២ | ៣ | ៤ | ១៣ | ១៣ |
| **S0795** | ៣ | ៤ | ១ | ២ | ៣ | ១៣ | ១៣ |
| **S1002** | ៥ | ២ | ៣ | ១ | ២ | ១៣ | ១៣ |
| **S0553** | ២ | ១ | ៣ | ៣ | ២ | ១១ | ១៧ |
| **S0293** | ១ | ១ | ៣ | ៤ | ១ | ១០ | ១៨ |

*រូបភាពទី ១៨. ការដាក់ពិន្ទុអនុអាង និងការជ្រើសរើស*




# តំបន់អាទិភាពសម្រាប់គម្រោងបង្ហាញ

នៅក្នុងស្ថានភាពនៃធនធានមានតិចតួច និងមានកិច្ចការចាំបាច់ជាច្រើនដែលត្រូវធ្វើ ដើម្បីស្តារអាង 9C-9T ក្នុងបំណងកាត់បន្ថយហានិភ័យនៃទឹកជំនន់ និងគ្រោះរាំងស្ងួត គេចាំបាច់ត្រូវកំណត់អាទិភាពនៃការវិនិយោគ។ ក្នុងជំហានដំបូង យើងបែងចែកអាងនេះ ជា ១៨ អនុអាង។ បន្ទាប់មក ចាត់ថ្នាក់អនុអាងទាំងនេះ ទៅតាមតម្រូវការស្តារឡើងវិញ។ អនុអាងចំនួន ១១ ត្រូវបានកំណត់ថា មានអាទិភាពខ្ពស់សម្រាប់ការវិនិយោគ លើការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត។

នៅជំហានចុងក្រោយ ទីតាំងជាក់លាក់នៅក្នុងអនុអាងអាទិភាពទាំង ១១ នោះត្រូវបានកំណត់អត្តសញ្ញាណដូចដែលបានបង្ហាញក្នុងរូបភាពទី ១៨ ។ តំបន់ទាំងនេះត្រូវបានជ្រើសរើសដោយផ្អែកលើរូបភាពពី Google Earth ដែលមានកម្រិតច្បាស់ខ្លាំង ដោយមានការគាំទ្រពីព័ត៌មានអង្កេតនៅតាមមូលដ្ឋាន។ តារាងទី ៨ រាយឈ្មោះទីតាំងចំនួន ១៣ នៅក្នុងអនុអាង ដែលបានកំណត់អាទិភាព និងកត្តានានា ដែលនាំឱ្យមានការជ្រើសយកជាកន្លែងអនុវត្តបង្ហាញ ដើម្បីដោះស្រាយបញ្ហាធ្ងន់ធ្ងរដែលពួកគេកំពុងជួបប្រទះ តាមរយៈ ការរួមបញ្ចូលវិធានការផ្អែកលើធម្មជាតិ និងចម្រុះ។

## តារាងទី ៨. ទីតាំងចុះពិនិត្យ នៅក្នុងអនុអាងដែលបានកំណត់ជាអាទិភាព

| គម្រោង សាកល្បង # | ប្រទេស | អនុអាង | ទីតាំងគម្រោង | កត្តាជ្រើសរើសជាក់លាក់ |
|---|---|---|---|---|
| **1** | ថៃ | S0810 | Sampoi, Tuduang និងទីតាំងគម្រោងកែលំអអាងស្តុកទឹក និងស្តារទីជម្រាលនៃអង្គការសហប្រជាជាតិ។ | • វត្តមានទឹកតិចតួចនៅក្នុងដី<br>• សមត្ថភាពទាបនៃជម្រាបចូល/ជម្រាបចេញ<br>• បញ្ហាសំណឹកដី និងកំណកល្បាប់<br>• សក្តានុពលខ្ពស់នៃរំហួតរំភាយចំហាយទឹកពីដំណាំ (ដែលបង្ហាញពីភាពខ្វះទឹក)<br>• គ្រោះរាំងស្ងួតញឹកញាប់<br>• ទឹកភ្លៀងនៅរដូវប្រាំងត្រូវបាននិទស្សន៍ថានឹងថយចុះ<br>• អនុអាង1002 នៅខាងលើ មានពិន្ទុសរុបខ្ពស់ខ្លាំង<br>• អាងស្តុកទឹកស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ |
| **2** | កម្ពុជា | S1017 | ការគ្រប់គ្រងកំណកល្បាប់ និងការស្តារឡើងវិញនូវទីជម្រាលនៅអាងត្រពាំងថ្ម | • សមត្ថភាពទាបនៃជម្រាបចូល/ជម្រាបចេញ<br>• បញ្ហាសំណឹកដី និងកំណកល្បាប់<br>• សក្តានុពលខ្ពស់នៃរំហួតរំភាយចំហាយទឹកពីដំណាំ (ដែលបង្ហាញពីភាពខ្វះទឹក)<br>• រងផលប៉ះពាល់ពីគ្រោះរាំងស្ងួតកាន់តែខ្លាំង<br>• ទឹកភ្លៀងនៅរដូវប្រាំងត្រូវបាននិទស្សន៍ថានឹងថយចុះ<br>• ការប្រែក្លាយដីព្រៃទៅជាដីកសិកម្ម |
| **3** | ថៃ | S0583 | សំណឹក-កំណកល្បាប់ក្នុងស្រុករ៉ាតាណា ណាខន | • វត្តមានទឹកតិចតួចនៅក្នុងដី<br>• សមត្ថភាពទាបនៃជម្រាបចូល/ជម្រាបចេញ<br>• បញ្ហាធ្ងន់ធ្ងរនៃសំណឹកដី និងកំណកល្បាប់<br>• សក្តានុពលខ្ពស់នៃរំហួតរំភាយចំហាយទឹកពីដំណាំ (ដែលបង្ហាញពីភាពខ្វះទឹក)<br>• ភាពញឹកញាប់ខ្លាំងនៃគ្រោះរាំងស្ងួត<br>• ទឹកភ្លៀងនៅរដូវប្រាំងត្រូវបាននិទស្សន៍ថានឹងថយចុះ |
| **4** | ថៃ | S0583 | ការពង្រឹងប្រាំងលើដងស្ទឹង Takhian | |
| **5** | កម្ពុជា និង ថៃ | S1143, S0624 | ការគ្រប់គ្រងទឹកកខ្វក់ឆ្លងដែន តាមរយៈវិធានការណ៍ផ្អែកលើធម្មជាតិ | • បញ្ហាគ្រប់គ្រងសំណល់រាវ<br>• វត្តមានទឹកតិចតួចនៅក្នុងដី<br>• សមត្ថភាពទាបនៃជម្រាបចូល/ជម្រាបចេញ<br>• ទឹកភ្លៀងនៅរដូវប្រាំងត្រូវបាននិទស្សន៍ថានឹងថយចុះ<br>• សមត្ថភាពមធ្យមក្នុងការរក្សាទឹកទុក<br>• ហានិភ័យទឹកជំនន់កម្រិតមធ្យម (និទស្សន៍ថា ទឹកភ្លៀងនៅរដូវវស្សានឹងកើនឡើង)<br>• ភាពញឹកញាប់ខ្លាំងនៃគ្រោះរាំងស្ងួតខ្ពស់<br>• ការប្រែក្លាយដីព្រៃទៅជាដីកសិកម្ម |
| **6** | កម្ពុជា | S0908 | ការរក្សាទុកទឹកជំនន់នៅភូមិកប់ធំ | • តំបន់ជន់លិចជាប្រចាំ<br>• រងការប៉ះពាល់ដោយគ្រោះរាំងស្ងួតកាន់តែខ្លាំង។ ទឹកភ្លៀងនៅរដូវប្រាំងត្រូវបាននិទស្សន៍ថានឹងថយចុះ និងកើនឡើងនៅរដូវវស្សា |

| គម្រោងសាកល្បង # | ប្រទេស | អនុអាង | ទីតាំងគម្រោង | កត្តាជ្រើសរើសជាក់លាក់ |
|---|---|---|---|---|
| | | | | • វត្តមានទឹកតិចតួចនៅក្នុងដី<br>• សក្តានុពលខ្ពស់នៃរំហួតភាយចំហាយទឹកពីដំណាំ (ដែលបង្ហាញពីភាពខ្វះទឹក) |
| **7** | កម្ពុជា | S2536, S1002 | ការគ្រប់គ្រងទឹកជំនន់នៅក្រុងសិរីសោភ័ណ | • តំបន់អាជីវកម្មរ៉ែ<br>• ហានិភ័យនៃការបាក់ដី<br>• ការបំពុលដោយសំណល់រាវក្នុងទីក្រុង |
| **8** | កម្ពុជា | S2536 | ការស្តារព្រៃលិចទឹកនិងតំបន់ដីសើម ក្នុងតំបន់ស្នូលនៃបបនីយជីវមណ្ឌលបឹងទន្លេសាប | • ហានិភ័យខ្ពស់នៃទឹកជំនន់<br>• ការប្រែក្លាយដីព្រៃទៅជាដីកសិកម្ម<br>• ការបាត់បង់តំបន់ដីសើម |
| **10** | កម្ពុជា | S1443, S0722 | បណ្តាញព្រៃឈើជាច់ដោយដុំ សម្រាប់តភ្ជាប់តំបន់ព្រៃឈើដែលនៅសល់ ក្នុងទីជម្រាលសំខាន់ៗ | • បញ្ហាតំបន់ព្រៃឈើដាច់ជាបំណែក<br>• ការបាត់បង់ព្រៃឈើ<br>• បញ្ហាសំណឹកដី និងកំណកល្បាប់<br>• សមត្ថភាពទាបនៃជម្រាបចូល/ជម្រាបចេញ |
| **11** | កម្ពុជា | S1344 | ការគ្រប់គ្រងទីជម្រាល នៅអាងស្តុកទឹកកំពីងពួយ | • វត្តមានទឹកតិចតួចនៅក្នុងដី<br>• សមត្ថភាពទាបនៃជម្រាបចូល/ជម្រាបចេញ<br>• សមត្ថភាពទាបក្នុងការរក្សាទឹកទុក<br>• ហានិភ័យខ្ពស់នៃទឹកជំនន់<br>• គ្រោះរាំងស្ងួតកាន់តែញឹកញាប់ និងខ្លាំង<br>• ការប្រែក្លាយដីព្រៃទៅជាដីកសិកម្ម |
| **12&14** | ថៃ | S0517 | ការអភិរក្សទឹក និងការផ្គត់ផ្គង់ទឹកដល់ចំការកេសកូល<br><br>របៀងព្រៃឈើត្រូវបានបង្កើតឡើងក្នុងទីជម្រាលសំខាន់ៗ | • ទីជម្រាលសំខាន់មួយសម្រាប់ការប្រើប្រាស់ទឹក និងលក្ខខណ្ឌនៃទឹកនៅតំបន់ខ្សែទឹកខាងក្រោម (ការអភិរក្សទឹក និងការផ្គត់ផ្គង់ទឹកដល់ចំការកេសកូលនៅប៉ុងណាមរ៉ុន)<br>• បញ្ហាតំបន់ព្រៃឈើដាច់ជាបំណែក<br>• ការទន្ទ្រានចូលទៅក្នុងតំបន់ការពារធម្មជាតិ |
| **13** | កម្ពុជា និងថៃ | S0326 | ការស្តារឡើងវិញនូវទីជម្រាលក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងសំទ្បូត (កម្ពុជា) និងតំបន់ទ្រនាប់នៃឧទ្យានជាតិ Khlong Kreua Wai Chaleum (ប្រទេសថៃ) | • គ្របដណ្តប់តំបន់ប្រើប្រាស់ច្រើនយ៉ាងសំទ្បូត (កម្ពុជា) និងតំបន់ទ្រនាប់នៃឧទ្យានជាតិ Khlong Kreua Wai Chaleum (ប្រទេសថៃ)<br>• ការទន្ទ្រានចូលទៅក្នុងតំបន់ការពារធម្មជាតិ<br>• ការរេចរិលព្រៃឈើ ដែលប៉ះពាល់ដល់តំបន់ខ្សែទឹកខាងក្រោម |




**Correspondence:**
P.O. Box 6101
184 Fa Ngoum Road Unit 18
Ban Sithane Neua
Sikhottabong District
Vientiane 01000
Lao PDR

Tel: +856 21 263 263
Fax: +856 21 263 264
www.mrcmekong.org



**Supported by:**

german cooperation
DEUTSCHE ZUSAMMENARBEIT

Implemented by giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH